**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍

## ករណីសិក្សា៖ ៖រមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់ (រាជធានីភ្នំពេញ)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ចាន់ ស្រីម៉ុច** | បណ្ឌិត **ហុង វណ្ណៈ** |
| **ជា សុវណ្ណបញ្ញាវត្តី** | |

| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច | ឆ្នាំចូលសិក្សា ២០១៣ |
| ជំនាន់ទី ៣ | ឆ្នាំសរសេរសារណា ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ចាន់ ស្រីម៉ុច និង ជា សុវណ្ណបញ្ញារត្តី ជានិស្សិតឆ្នាំទី៤ ជំនាន់ទី៣ ផ្នែកគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមអោនលំទោនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើត និងធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីចិញ្ចឹមបីបាច់ថែរក្សាដោយផ្តល់ភាពកក់ក្តៅ សេចក្តីស្រលាញ់ មេត្តា ករុណា អប់រំទូន្មានឲ្យប្រព្រឹត្ត ខ្លួនទៅតាមគន្លងធម៌ ព្រមទាំងឧបត្ថម្ភជាំថវិការ សម្ភារៈ ដល់ការសិក្សារៀនសូត្រ ចាប់តាំងពីកម្រិតចំណេះដឹងទូទៅរហូតដល់ឧត្តមសិក្សា។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមសកលវិទ្យាធិការ លោកសកលវិទ្យាធិការរង ប្រធានក្រុមប្រឹក្សាស្រាវជ្រាវ ការិយាល័យសិក្សា និងបុគ្គលិកព្រមទាំងសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំក្នុងការបង្ហាត់បង្ហាញជួយណែនាំដាស់តឿន និងផ្តល់នូវចំណេះដឹងគ្រប់បែបយ៉ាង ដល់ពួកយើងខ្ញុំដោយខិតខំអស់ពីសមត្ថភាពកម្លាំងកាយចិត្ត និងប្រាជ្ញាក្នុងការស្រាវជ្រាវ ស្វែងរកឯកសារមកចងក្រងដើម្បីជាជំនួយដល់ ការសិក្សារៀនសូត្ររបស់នាងខ្ញុំដើម្បីឲ្យក្លាយជាធនធានមនុស្សនៅក្នុងសង្គម។

ជាពិសេស យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកសាស្រ្តាចារ្យបណ្ឌិត ហុង វណ្ណៈ ដែលបានណែនាំបង្ហាត់ក្រុមយើងខ្ញុំ ផ្តល់នូវវិធីសាស្រ្តស្រាវជ្រាវ និងជួយផ្តល់ជាមតិយោបល់ ដ៏មានតម្លៃ និងសារៈប្រយោជន៍ដើម្បីជួយ ក្រុមយើងខ្ញុំរហូតសម្រេចបានសមិទ្ធផលជាសៀវភៅសារណានេះឡើងប្រកបដោយភាពជោគជ័យ។

ជាចុងក្រោយយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដោយស្មោះអស់ពីដួងចិត្ត ចំពោះអាជីវករ ទេសចរ អាជ្ញាធរគ្រប់ជាន់ថ្នាក់ដែលបានជួយសម្រួលក្នុងការស្រាវជ្រាវព្រមឆ្លៀតពេលវេលាដ៏មានតម្លៃក្នុងការផ្តល់បទសម្ភាសន៍ ដើម្បីឲ្យសារណាយើងខ្ញុំមានដំណើរការនិងបញ្ចប់ទៅដោយរលូន។

# អារម្ភកថា

ប្រទេសកម្ពុជា ជាប្រទេសដែលមាន សក្តានុពលខ្លាំងក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ឲ្យមកលំហែកាយ និងសម្រាកកម្សាន្ត។ វិស័យទេសចរណ៍បានចូលរួមចំណែកយ៉ាងធំក្នុងការបង្កើតសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិយ៉ាងសម្បើម ដូចគ្នានេះដែលវិស័យនេះត្រូវបានគេចាត់ទុកថាជាវិស័យដ៏សំខាន់មួយក្នុង ការអភិវឌ្ឍ សេដ្ឋកិច្ចជាតិទាំងមូលក្នុងចំណាមវិស័យធំៗទាំងអស់នៅក្នុងប្រទេសកម្ពុជា ដោយបានចូលរួមចំណែកលើកស្ទួយកម្រិតជីវភាពប្រជាជនក៏ដូចជាបង្កើន ផលិតផលសរុបក្នុងស្រុក។ លើសពីនេះទៅទៀតវិស័យទេសចរណ៍មិនត្រឹមតែជួយលើកតម្កើងកម្រិតជីវភាពប្រជាជននោះទេ ផ្ទុយទៅវិញវាក៏ជាកម្លាំងចលករមួយយ៉ាងសំខាន់ក្នុងការ ផ្សព្វផ្សាយវប្បធម៌ និងមុខមាត់ជាតិនៅលើឆាកអន្តរជាតិផងដែរ។

ជាថ្មីម្តងទៀត ក្នុងនាមយើងខ្ញុំជានិស្សិត ទេសចរណ៍ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលមាន ឱកាសបានធ្វើការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ (ករណីសិក្សារមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់)។ យ៉ាងណាមិញដោយការខិតខំស្រាវជ្រាវប្រធានបទនេះឡើង ក្នុងគោលបំណងឆ្លើយតបទៅនិងស្ថានភាពទេសចរណ៍ នាពេលបច្ចុប្បន្នដែលរាជរដ្ឋាភិបាលកំពុងប្រឹងប្រែងអភិវឌ្ឍវិស័យមួយនេះឲ្យរីកចម្រើនទៅមុខ ក៏ដូចជាសមស្របទៅនឹងគម្រោងនានាដែរអាជ្ញាធររាជធានីកំពុងសម្លឹងឃើញនិងគម្រោងនានាដែលគេកំពុងសិក្សានៅក្នុងតំបន់កោះដាច់ដើម្បីអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព។ ម្យ៉ាងវិញទៀតក្នុងដំណើរការនៃការស្រាវជ្រាវយើងខ្ញុំបានរកឃើញនូវទ្រឹស្តីមួយចំនួនព្រមទាំងបញ្ហានានាដែលតំបន់ទេសចរណ៍កោះដាច់ កំពុងតែប្រឈមដែលជាហេតុនាំឲ្យមានការអភិវឌ្ឍយឺតយ៉ាវ។

នាទីបញ្ចប់យើងខ្ញុំសូមធ្វើការខន្តី អភ័យទោសចំពោះការស្រាវជ្រាវដែលយើងខ្ញុំទាំងអស់ធ្វើការសិក្សាឡើងនៅមានចន្លោះប្រហោង ខ្វះខាតនូវចំនុចណាមួយ ប៉ុន្តែយើងក៏សង្ឃឹមយ៉ាងមុតមាំដែលថា កិច្ចការស្រាវជ្រាវនេះវានឹងក្លាយជាជំនួយដល់និស្សិតដែលមានបំណងធ្វើការស្រាវជ្រាវលើប្រធានបទទាក់ទងនិងការអភិវឌ្ឍ។

ជាចុងក្រោយយើងខ្ញុំ រងចាំការរិះគន់ពីសំណាក់សាស្ត្រាចារ្យ ព្រមទាំងនិស្សិតដែលបានអាននូវប្រធានបទមួយនេះព្រមទាំង សូមអភ័យទោសចំពោះកំហុសក្នុងការប្រើប្រាស់ពាក្យពេជន៍និងអក្ខរាវិរុទ្ធដែលកើតឡើងដោយអចេតនានៅក្នុងសារណារបស់យើងខ្ញុំ។

# មាតិកា

## សេចក្ដីផ្ដើម


១. លំនាំបញ្ហា......១
២. ចំណោទបញ្ហា......២
៣. គោលបំណងនៃការស្រាវជ្រាវ......២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ......២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ......៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ......៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......៥


## ជំពូកទី១

## ទ្រឹស្ដីនៃការអភិវឌ្ឍទេសចរណ៍


១.១ ទ្រឹស្ដីនានាទាក់ទងទេសចរណ៍......៦
១.២ ទ្រឹស្ដីនានាទាក់ទងទេសចរ......៧
១.៣ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព......៨
១.៤ ផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍទេសចរណ៍......១០
១.៥ បទពិសោធន៍បរទេសទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព......១២


## ជំពូកទី២

## ស្ថានភាពទូទៅនៃទេសចរណ៍រាជធានីភ្នំពេញ


២.១ ស្ថានភាពទូទៅរាជធានីភ្នំពេញ......១៦
  ២.១.១ វិស័យនានារាជធានី......១៨
២.២ វិស័យទេសចរណ៍រាជធានីភ្នំពេញ......១៨
  ២.២.១ រមណីយដ្ឋានសំខាន់ៗរាជធានីភ្នំពេញ......២០
  ២.២.២ ទីផ្សារទេសចរណ៍រាជធានី......២៥
២.៣ ស្ថានភាពទូទៅរមណីយដ្ឋានកោះដាច់......២៦
  ២.៣.១ សក្ដានុពលរមណីយដ្ឋានកោះដាច់......២៧
  ២.៣.២ ទីផ្សារទេសចរណ៍រមណីយដ្ឋានកោះដាច់......២៩
  ២.៣.៣ បញ្ហាប្រឈម......៣២

## ជំពូកទី៣

## ទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់

៣.១ ការកែលម្អហេដ្ឋានរចនាសម្ព័ន្ធ ........................................ ៣៤
៣.២ ការកែលម្អបរិស្ថាន ........................................ ៣៦
៣.៣ បង្កើនគុណភាពអាហារ និងភេសជ្ជៈ ........................................ ៣៨
៣.៤ ការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ........................................ ៤២
៣.៥ បង្កើនការផ្សព្វផ្សាយ និងជំរុញទីផ្សារ ........................................ ៤៣
    ៣.៥.១. បង្កើនការផ្សព្វផ្សាយ ........................................ ៤៣
    ៣.៥.២. ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ ........................................ ៤៥
៣.៦ បង្កើតផលិតផលទេសចរណ៍ថ្មីៗ ........................................ ៤៥
៣.៧ កិច្ចសហការ និងការចូលរួមពីអ្នកពាក់ព័ន្ធ ........................................ ៤៧

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន........................................ ៤៩
២. អនុសាសន៍ ........................................ ៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ចក្តីផ្តើម

## ១. លំនាំបញ្ហា

នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថា វិស័យទេចរណ៍ក្នុងប្រទេសកម្ពុជា មានការបោះជំហានទៅមុខជាលំដាប់គួរឲ្យកត់សម្គាល់ជាក់ស្តែង តាមរបាយការណ៍បូកសរុបរបស់ក្រសួងទេសចរណ៍បានបង្ហាញថានៅក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាទទួលបានទេសចរអន្តរជាតិសរុប ១១៨,១៨៣ លានអ្នក គិតដល់ចុងឆ្នាំ ២០១៦ ទេសចរអន្តរជាតិដែលមកដល់ប្រទេសកម្ពុជាមានចំនួន ៥,០១១,៧១២លានអ្នក[1] ។ ទាំងនេះក៏ដោយសារតែកម្ពុជាយើងអំណោយផលពីធម្មជាតិបូករួមទាំងភាពសម្បូរហូរហៀលនូវធនធានវប្បធម៌ ធនធានធម្មជាតិ និងកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រជាច្រើនលើសលប់ពាសពេញផ្ទៃប្រទេស។ ដោយមើលឃើញ ថាវិស័យទេសចរណ៍បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការស្តារនិងអភិវឌ្ឍជាតិ តាមរយៈការរកចំនូលចូលជាតិ ព្រមទាំងផ្តល់ការងារ និងមុខរបរដល់ ប្រជាជនតាមតំបន់ដោយផ្ទាល់ និងប្រយោល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកវិស័យទេសចរណ៍ ជាវិស័យអទិភាពជាតិក្នុងការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យរីកចម្រើនទៅមុខ។លើសពីនេះទៅទៀតវិស័យទេសចរណ៍បានបង្កើតឡើងនូវកាលានុវត្តភាពសម្រាប់ការលូតលា ស់ខាងផ្លូវគំនិតរបស់ប្រជាជនតាមរយៈការបង្កើតនូវការអប់រំ ការយោគយល់គ្នា និងជម្រុញនូវទំនាក់ទំនងរវាងជាតិសាស្ត្រនានា ក៏ដូចជានាំមនុស្សឲ្យស្គាល់នូវអ្វីដែលប្លែកខុសពីអត្តសញ្ញាណរបស់ខ្លួន ក៏ដូចជាការលើកទឹកចិត្តឲ្យមានការគោរពនិងអភិរក្សបរិស្ថានជាតិ ដូចគ្នាទៅនិងការចូលរួមក្នុងការពង្រឹងសន្តិភាព និងការបង្កើតឡើងនូវលក្ខណៈមួយដើម្បីឲ្យប្រជាជាតិ និងវប្បធម៌ចម្រុះបានជួបជុំគ្នា។

ដោយយល់ឃើញ ពីលក្ខណៈពិសេស នៃវិស័យទេសចរណ៍ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ប៉ូលអភិវឌ្ឍន៍ជា ៤សំខាន់ដោយកំណត់តាមប្រភេទផលិតផល និងតាមតំបន់ច្រករបៀងសំខាន់ៗ ដូចជា៖ អង្គរ និងតំបន់ជុំវិញ, ភ្នំពេញនិងតំបន់ជុំវិញ, តំបន់ឆ្នេរ និងចុងក្រោយភូមិភាគឥសាន។ ប៉ូលភ្នំពេញ គឺជារាជធានី បេះដូង និងជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម វប្បធម៌ និងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែក រមណីយដ្ឋានកោះដាច់ គឺជាផ្នែកមួយនៃប៉ូលនេះផងដែរ តំបន់នេះមានសក្តានុពលធម្មជាតិ មិនចាញ់តំបន់នានាឡើយម្យ៉ាងវិញទៀតវា គឺជាតំបន់មួយដែលស្ថិតនៅ តាមដងទន្លេមេគ្គហើយជារមណីយដ្ឋាន

[1]. Tourism Statistic report Year 2016

មួយដែលនៅក្បែររាជធានីភ្នំពេញ មានទន្លេស្រស់ស្អាត ជាតំបន់ដែលអំណាយផលពីធម្មជាតិ អាកាសធាតុត្រជាក់ល្អបរិសុទ្ធ លើសពីនេះទៅទៀតទេសចរដែលទៅកម្សាន្តនៅរមណីយដ្ឋាន មិនបាច់ព្រួយបារម្ភរឿងម្ហូបអាហារនោះទេ ព្រោះនៅក្នុងតំបន់នោះប្រជាពលរដ្ឋបានសង់ជាតូបៗ សម្រាប់ទេសចរអង្គុយងាយស្រួលក្នុងការស្រស់ស្រូបអាហារ។

យោងតាមការអង្កេតផ្ទាល់ក្រុមយើងខ្ញុំមើលឃើញថា តំបន់នេះមានការរៀបចំល្អច្រើន ហើយប៉ុន្តែដោយសារការរៀបចំទាំងអស់នោះ ហាក់នៅមានបញ្ហាមួយ។ មួយវិញទៀតដោយសារ តែនៅតំបន់នោះ យើងខ្ញុំមិនទាន់ឃើញមានការស្រាវជ្រាវណាដែលបានសិក្សាលំអិត ដើម្បី ទាក់ទាញឲ្យទេសចរឲ្យមកទស្សនាជាប្រចាំ នៅតំបន់នោះទេមួយវិញអាស្រ័យហេតុនេះហើយទើប យើងខ្ញុំសម្រេចលើកយកតំបន់រមណីយដ្ឋាននេះមកធ្វើការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទ **"ការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ប្រកបដោយនិរន្តរភាព ករណីសិក្សារមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់"** ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភូមិន្ទនិតីសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ២. ចំណោទបញ្ហា

រមណីយដ្ឋានកោះដាច់ជាតំបន់មួយ ដែលមានសក្តានុពលខ្លាំងក្នុងការទាក់ទាញទេសចរ ជាតិ និងអន្តរជាតិឲ្យមកធ្វើការសម្រាកលំហែលកម្សាន្ត។ ដូច្នេះ តើតំបន់រមណីយដ្ឋានកោះដាច់ មានសភាពលក្ខណៈដូចម្តេចនាពេលបច្ចុប្បន្ន និងមានបញ្ហាប្រឈមអ្វីខ្លះ? តើយើងគួរមានយន្ត ការអ្វីខ្លះ ដើម្បីរៀបចំ និងអភិវឌ្ឍរមណីយដ្ឋានឲ្យកាន់តែល្អឡើងសំដៅទាក់ទាញទេចរជាតិ និងអន្តរជាតិឲ្យមកកម្សាន្ត?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវ គឺដើម្បីផ្តល់នូវទស្សនៈវិស័យថ្មីៗ ក៏ដូចជាស្វែងរកនូវ គន្លឹះសំខាន់នានាដើម្បីយកមកជម្រុញក្នុងការអភិវឌ្ឍ កែលម្អ ឲ្យកាន់តែមានភាពប្រសើរឡើងលើក ការរៀបចំ ព្រមទាំងជម្រុញឲ្យរមណីយដ្ឋានកាន់តែមានភាពទាក់ទាញ ទាំងភ្ញៀវជាតិនិងអន្តរជាតិ បង្ហាញពីទ្រឹស្តីអំពីទេសចរណ៍ សិក្សាអំពីសក្តានុពលនិងស្វែងរកបញ្ហាប្រឈម ដែលចោទខ្លាំងទៅ លើតំបន់ ផល់ជាមតិនានាចំពោះផលប៉ះពាល់ ក៏ដូចជាដំណោះស្រាយនានាក្នុងការអភិវឌ្ឍ។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះវិសាលភាពនៃការសិក្សាស្រាវជ្រាវគឺយើង ផ្តោតលើតែតំបន់រមណីយដ្ឋានឆ្នេរខ្សាច់ កោះដាច់ សហគមន៍ជុំវិញ ក៏ដូចជា តំបន់ក្បែរប៉ុណ្ណោះមានន័យគឺនៅក្នុងចន្លោះសង្កាត់កោះដាច់

ខណ្ឌជ្រោយចង្វារ និងមួយផ្នែកទៀតគឺតំបន់ដែលមានសក្តានុពលផ្សេងដោយគិតចាប់ពីត្រើយខាងកើតស្ពានជ្រោយចង្វារ មកដល់តំបន់ជុំវិញព្រះបរមរាជវាំង។ សម្រាប់ឯកសារដែលលើកយកមកធ្វើការសិក្សា គឺយើងកំណត់ចាប់ពីឆ្នាំ ២០១២ រហូតដល់ ២០១៦ ហើយឯកសារដែកមិនស្ថិតនៅក្នុងឆ្នាំនៃដែនកំណត់ក៏ពួកយើងបានលើកយកមកធ្វើការស្រាវជ្រាវផងដែលដើម្បីជាទុន និងដើម្បីឲ្យកាន់តែមានភាពងាយស្រួលក្នុងការវិភាគទិន្នន័យ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ជាដើមទុននៃការស្រាវជ្រាវ ដើម្បីទទួលបានលទ្ធផលល្អ ពួកយើងបានប្រើវិធីសាស្ត្រជាច្រើនផ្សេងគ្នាដោយយកវាមកប្រើប្រាស់រួមបញ្ចូលគ្នា ដោយមានដូចជាទ្រឹស្តី សៀវភៅបោះពុម្ភ ផែនការអភិវឌ្ឍរបស់ក្រសួងទេសចរណ៍ ការសែត ផ្សេងៗ ។ ដោយយើងបានបែងចែកជាចំណុចៗដូចខាងក្រោម។

### ក. ប្រភព និងប្រភេទទិន្នន័យ

ក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវ ទិន្នន័យដែលយើងយកមកធ្វើការសិក្សាយើងខ្ញុំបានប្រើប្រាស់ទិន្និន័យ២ គឺ ទុតិយាទិន្នន័យ និងបឋមទិន្នន័យ។

ទុតិយាទិន្នន័យ យើងខ្ញុំបានដកស្រង់ចេញពី បណ្ណាល័យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ច ក្រសួងទេសចរណ៍ បណ្ណាគារ ឯកសារដែលពាក់ព័ន្ធផ្សេងទៀតដូចជា កាសែត ឯកសារស្នាដៃ វចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត ព្រមទាំងបណ្តាញអ៊ិនធើណែតនានា តាមរយៈគេហទំព័ររបស់ ក្រសួងទេសចរណ៍ ។

បឋមទិន្នន័យ ដែលយើងយកមកប្រើប្រាស់គឺ យើងខ្ញុំបានធ្វើជាកម្រងសំនួរ សម្រាប់សម្ភាសជាមួយប្រជាពលរដ្ឋ អាជីវករដោយយើងបានចុះអង្កេតផ្ទាល់នឹងតំបន់រមណីយដ្ឋានផ្ទាល់តែម្តង។

### ខ. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យយើងខ្ញុំបានប្រើប្រាស់២របៀបគឺ ទុតិយាតទិន្នន័យ និងបឋមទិន្នន័យ។

ទុតិយាតទិន្នន័យមានដូចជា: សៀវភៅបោះពុម្ភផ្សាយ របាយការណ៍ ផែនការ កាសែតព័ត៌មាន និងបណ្តាញ Internet ។

បឋមទិន្នន័យ: យើងខ្ញុំបានមកពីការចុះសម្ភាស និងអង្កេតស្ថានភាពទូទៅនៃតំបន់ដែលបែងចែកជាជំហានៗដូចខាងក្រោម

-**ការកំណត់គំរូតាង** ក្នុងការកំណត់ និង ធ្វើគំរូតាងពួកយើងបានបានធ្វើការចុះសម្ភាសផ្ទាល់ជាមួយទេសចរណ៍ដោយផ្តោតសំខាន់ទៅលើទេសចរចំនួន១០០នាក់ ដោយគិតចាប់ពីវ័យ២០ឆ្នាំ

រហូតដល់ ៦៥ឆ្នាំ ដោយបូករួមទាំងបុរស និងស្ត្រី អ្នកមានចំនូលមធ្យម និងព្រមជាមួយបងៗ ដែលជាអាជីវករលក់ដូរនៅទីនោះចំនួន២០រូប រួមជាមួយអាជ្ញាធរ១០រូបផងដែរ មួយផ្នែកតូចគឺពួកយើងបានធ្វើការចុះសាកសួរផ្ទាល់ពីសំណាក់ ទេសចរអន្តរជាតិ។

-**ការចុះអង្កេត** យើងខ្ញុំបានធ្វើការចុះពិនិត្យផ្ទាល់ និងទស្សនានៅក្នុងតំបន់នោះដោយយើងធ្វើការអង្កេតទៅលើសក្តានុពលនៃធនធានធម្មជាតិដែលមានស្រាប់ ផលប៉ះពាល់ដែលជាបញ្ហាប្រឈម ចំពោះប្រជាពរដ្ឋ ទេសចរ និងអាជីករដែល ស្ថិតនៅ ភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ។

-**ការសម្ភាស** ដំណើការធ្វើបទសម្ភាស យើងខ្ញុំបានធ្វើការសម្ភាសទៅតាមសំណួរដែលបានកំណត់ យ៉ាងល្អិតល្អិនពីមួយទៅមួយ ដោយធ្វើការសាកសួរតាមអាជីវករ ទេសចរ អាជ្ញាធរ ដើម្បីប្រមូលគំនិត និងចំណាប់អារម្មណ៍។

**គ. ការវិភាគទិន្នន័យ**

ការវិភាគទិន្នន័យត្រូវបានធ្វើឡើងតាមរយៈ ការប្រមូលចម្លើយពីការ សម្ភាសតាមសំណួរដែលបានចងក្រងរួចពីមួយទៅមួយរហូតអស់គំរូដូចដែលបានកំណត់ចំនួនគម្រូតាងទាំង ដោយគិតតែគណនាភាគរយ នៃចម្លើយរបស់គម្រូតាងទាំងអស់ ដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រ Microsoft Excel លើក្រាបផ្លិត(Pie chart) ។ ដូចនេះទាំងចំនួនគម្រូតាង និងការចុះអង្កេតស្ថានភាពតំបន់ផ្ទាល់ គឺអាចយកទៅប្រើការបាន តាមការវិភាគទិន្នន័យបែប បរិមាណវិស័យ(Quantitative) និងគុណវិស័យ (Qualitative)។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទនេះឡើងបានផ្តល់នូវសារៈប្រយោជន៍ដោយផ្តល់នូវទ្រឹស្តី ដោយការចុះប្រមូលនិងសិក្សាផ្ទាល់នៅតំបន់រមណីយដ្ឋានកោះដាច់ មិនតែប៉ុណ្ណោះក៏បានធ្វើការសម្ភាសជាមួយនិងប្រជាពលរដ្ឋ ទេសចរ អាជីវករ ក៏ដូចជាទេសចរដើម្បីទទូលបាននូវទិន្នន័យកាន់តែច្បាស់។ ប្រធានបទមួយនេះផ្តល់នូវសារៈសំខាន់ដូចជា៖

- ផ្តល់នូវគំនិត និងយោបល់ក្នុងការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍតំបន់រមណីយដ្ឋានកោះដាច់
- ជាជំនួយដល់អ្នកសិក្សាគម្រោង ដែលមានបំណងចង់វិនិយោគនៅក្នុងរមណីយដ្ឋានកោះដាច់

- ជាឯកសារជំនួយសម្រាប់អ្នកសិក្សាទេសចរណ៍ អ្នកគ្រប់គ្រងស្ថាប័នទេសចរណ៍ដែលចង់ស្វែងយល់ពីទ្រឹស្តីអភិវឌ្ឍទេសចរណ៍សំដៅឲ្យវិស័យនោះ រីកចម្រើនប្រកបដោយនិរន្តភាព។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានយើងរៀបចំឡើង ដោយបែងចែកវាជា ៥ផ្នែកផ្សេងៗគ្នា៖

**ផ្នែកទី១** សេចក្តីផ្តើម ផ្នែកនេះគឺយើងធ្វើការសិក្សាដោយផ្តោតលើ ៦ចំនុចសំខាន់ៗ ដូចជា លំនាំបញ្ហា ចំនោទបញ្ហា គោលបំណងចំបងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម័ន្ធនៃការស្រាវជ្រាវ។

**ផ្នែកទី២** ខ្លឹមសារ ផ្នែកនេះទៀតសោទគឺជាផ្នែកសំខាន់មួយដែលវាបង្ហាញទៅលើខ្លឹមសារ និង ការអត្ថន័យនៃសារណាទាំងមូល។ លើសពីនេះទៅទៀត យើងបានបែងចែកវាជា ៣ជំពូកដូចខាងក្រោម

**ជំពូក១** ទ្រឹស្តីនៃការអភិវឌ្ឍទេសចរណ៍ ចំនុចនេះគឺជាការរំលឹកឡើងវិញនូវចំនុចសំខាន់មួយចំនួនដែលជាការពន្យល់ន័យនូវពាក្យគន្លឹះ និងរំលឹកនូវទ្រឹស្តីនានាទាក់ទងនិងប្រធានបទដែលមានការបកស្រាយតាមរយៈអ្នកនិពន្ធ ក៏ដូចជាប្រភពផ្សេងគ្នាជាច្រើន ព្រមទាំងមានការលើកយកនូវបទពិសោធន៍នៃការអភិវឌ្ឍរបស់បរទេសយកមកបង្ហាញនៅក្នុងជំពូកនេះផងដែល។

**ជំពូក២** ស្ថានភាពទូទៅរាជធានីភ្នំពេញ ជំពូកនេះគឺជាជំពូកសំខាន់មួយដែលរៀបរាប់ពីទីតាំងភូមិសាស្ត្ររាជធានីក៏ដូចជាស្ថានភាពទូទៅតំបន់រមណីយដ្ឋានក៏ដូចជាសក្តានុពលតំបន់។

**ជំពូក៣** ទស្សនៈទានក្នុងការ ជំពូកនេះជា ជំពូកមួយដែលរៀបរាប់បង្ហាញពីការយល់ឃើញចំពោះបញ្ហាដែលកើតមាន ព្រមទាំងបញ្ហាប្រឈមមួយចំនួននៅក្នុងតំបន់រមណីយដ្ឋាន បូករួមទាំងការរកឃើញនូវគំនិតថ្មីជាគន្លឹះដើម្បីកែកល្អនឹងទប់ស្កាត់នូវបញ្ហាដែលនឹងអាចកើតមានឡើង។

**ផ្នែកទី៣** សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ជាការសរុបសេចក្តី និងធ្វើការបកស្រាយនូវការយល់ឃើញព្រមទាំងផ្តល់នូវគំនិតយោបល់បន្ថែម។

**ផ្នែកទី៤** ឯកសារយោង ជាផ្នែកមួយនៃការសំណើរឯកសារដែលផ្ទុកនូវរាល់ប្រភពឯកសារពាក់ព័ន្ធ និងទិន្នន័យដែលយើងទទួលបាន។

**ផ្នែកទី៥** ឧបសម្ព័ន្ធ សំដៅទៅលើ កម្រងឯកសារស្រាវជ្រាវ រូបភាព កម្រងសំនួរ ដែលមានការពាក់ព័ន្ធនឹងប្រធានបទ។

# ជំពូកទី១
# ទ្រឹស្តីនៃការអភិវឌ្ឍទេសចរណ៍

## ១.១. ទ្រឹស្តីនានាទាក់ទងទេសចរណ៍

និយមន័យរបស់ទេសចរណ៍ ត្រូវបានកំណត់ទៅតាមលក្ខណៈពិសេសនៃសេដ្ឋកិច្ច នយោបាយ និងសង្គមរបស់វា។ តាមការសិក្សា និងការស្រាវជ្រាវពីនិយមន័យទេសចរណ៍ត្រូវបានអ្នកប្រាជ្ញជាច្រើនកំណត់និយមន័យផ្សេងៗគ្នា។

នៅក្នុងច្បាប់ទេសចរណ៍ព្រះរាជាណាចក្រកម្ពុជា "ទេសចរណ៍" សំដៅដល់សកម្មភាពទាំងឡាយណារបស់បុគ្គលដែលធ្វើដំណើរ និងស្នាក់នៅកន្លែងផ្សេងៗ ក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេសម្រាប់រយៈពេលកំណត់មួយ (មិនលើសពីមួយឆ្នាំ មិនតិចជាងមួយថ្ងៃ មួយយប់) ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របតាមច្បាប់ផ្សេងៗទៀត[2]។

យោងទៅតាមវចនានុក្រម Cambridge dictionary គេឲ្យនិយមន័យទេសចរណ៍ថា ជាជំនួញដែលផ្តល់នូវសេវាកម្មដូចជាការដឹកជញ្ជូន កន្លែងស្នាក់នៅ ឬការកម្សាន្ត សំរាប់មនុស្សនៅក្នុងថ្ងៃសម្រាករបស់ពួកគេ[3]។

នៅក្នុងច្បាប់ទេសចរណ៍របស់សាធារណៈរដ្ឋបារាំងបានកំណត់ថា "ទេសចរណ៍" គឺជាការធ្វើដំណើរកក្នុងរយៈពេលមួយរបស់ពលរដ្ឋ ឬមហាជនពីទីកន្លែងស្នាក់នៅជាអចិន្ត្រៃយ៍របស់ខ្លួនទៅកាន់ប្រទេសណាមួយ ឬតំបន់ណាមួយក្នុងប្រទេស ក្នុងពេលទំនេរពីការងារក្នុងគោលបំណងទទួលបានការសប្បាយរីករាយ សម្រាកព្យាបាល ទស្សនកិច្ច ស្វែងយល់ សាសនា ការងារ អាជីវកម្ម តែមិនត្រូវបានអនុញ្ញាតឲ្យបំពេញការងារដែល ទទួលបាននូវទឹកប្រាក់ក្នុងតំបន់ដែលបានទៅដល់[4]។

"ទេសចរណ៍" ជាការធ្វើសកម្មភាពកំសាន្តដែលជះឥទ្ធិពលទៅលើការពង្រឹងសុខភាព ការរីកចម្រើន និងអភិវឌ្ឍន៍កម្លាំងកាយ និងចិត្តរបស់មនុស្សដែលធ្វើចលនា ឬធ្វើរដំណើរចាកចេញពីកន្លែងរស់នៅជាប្រចាំក្នុងពេលរយៈពេលណាមួយ[5]។

---

[2] ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា "ច្បាប់ស្តីពីទេសចរណ៍" (១០ មិថុនា ២០០៩)

[3] http://dictionary.cambridge.org/dictionary/english/tourism (ចូលទស្សនា ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ៩៖១៧នាទី)

[4] ហាង វណ្ណៈ, ឈុន ពហុ, និង សហការី, "លំនាំដើមទេសចរណ៍" ទំព័រ៥៥

[5] សួន រ៉ានី, ឃិន ច័ន្ទសុធី, ទឹម សុធា, ជិន វិចិត្រា, "ទេសចរណ៍ ទ្រឹស្តី និងទស្សនៈ ជាមូលដ្ឋាន" ២០០៦ ទំព័រ៣១

តាមរយៈចរិតលក្ខណៈសេដ្ឋកិច្ច និយមន័យទេសចរណ៍គឺជាការធ្វើដំណើរទៅកាន់តំបន់ណាមួយផ្សេងពីកន្លែងរស់នៅអចិន្ត្រៃយ៍ ស្នាក់នៅនិងស្ថិតនៅតំបន់ដែលទៅដល់លើសពី២៤ម៉ោង ធ្វើសកម្មភាពជាមួយគោលបំណងទេសចរណ៍ស្របច្បាប់ដែលអនុញ្ញាត វិលត្រឡប់ទៅកន្លែងរស់នៅដើមវិញក្រោយបញ្ចប់សកម្មភាព មិនធ្វើការងារដែលទទួលបាននូវប្រាក់កំរៃផ្ទាល់ខ្លួន (ចាយនិងបន្សល់ទុកប្រាក់ក្នុងតំបន់)[6]។

សរុបជារួមទោះបីជាមានការលើកឡើងពីទស្សនៈខុសៗគ្នា ប៉ុន្តែអត្ថន័យគឺមានភាពប្រហាក់ប្រហែលគ្នាដែល ទេសចរណ៍ គឺសំដៅដល់ការសម្រាក លំហែកាយ សកម្មភាពសាសនា ធុរកិច្ច ដើម្បីគេចចេញពីជីវភាពដដែលៗប្រចាំថ្ងៃ ដែលសកម្មភាពទាំងនេះមានរយៈពេលមិនតិចជាងមួយថ្ងៃ និងមិនលើសពីមួយឆ្នាំ ហើយមិនមែនក្នុងគោលបំណងស្វែងរកប្រាក់ចំណូល។

## ១.២. ទ្រឹស្តីនានាទាក់ទងទេសចរ

មកទល់សព្វថ្ងៃនេះពាក្យទេសចរត្រូវបានគេលើកយកមកកំណត់ និងផ្តល់ជានិយមន័យជាច្រើនលើកមកហើយតែពុំទាន់ត្រូវបាន បញ្ចប់ជាស្ថាពរនោះទេព្រោះសកម្មភាពទេសចរណ៍តែងតែវិវត្តន៍ស្របនិងការវិវឌ្ឍន៍នៃសង្គម និងចិត្តគំនិតរបស់ទេសចរ។

នៅក្នុងច្បាប់ទេសចរណ៍ព្រះរាជាណាចក្រកម្ពុជា "ទេសចរ" សំដៅដល់បុគ្គលទាំងឡាយជាជនជាតិកម្ពុជា ឬជនបរទេស ដែលមកដល់តំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ[7]។

នៅក្នុងសម័យប្រជុំរបស់ អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៣៧នាទីក្រុងហ្សឺណែវ និយមន័យដំបូងរបស់ទេសចរណ៍ត្រូវបានគេកំណត់ថា " ទេសចរជាបុគ្គលដែលស្ថិតនៅមិនតិចជាង២៤ម៉ោងក្នុងប្រទេសដែលគាត់មិនបានរស់នៅ [8]។

យោងតាមវចនានុក្រម Oxford Dictionaries បានឲ្យនិយមន័យថា ទេសចរ ជាមនុស្សដែលធ្វើដំណើរ ឬទស្សនាកន្លែងណាមួយដើម្បីភាពសប្បាយរីករាយ[9]។

---

[6] សួន វ៉ានី, យិន ច័ន្ទសុធី, ទឹម សុធា, ជិន វិចិត្រា, "ទេសចរណ៍ ទ្រឹស្តី និងទស្សនៈ ជាមូលដ្ឋាន" ២០០៦ ទំព័រ៣១

[7] ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា "ច្បាប់ស្តីពីទេសចរណ៍" (១០ មិថុនា ២០០៩)

[8] សួន វ៉ានី, យិន ច័ន្ទសុធី, ទឹម សុធា, ជិន វិចិត្រា, "ទេសចរណ៍ ទ្រឹស្តី និងទស្សនៈ ជាមូលដ្ឋាន" ២០០៦ ទំព័រ៤១

[9] https://en.oxforddictionaries.com/definition/tourist (ចូលទស្សនា ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ១០៖៥៨នាទី)

នៅក្នុងវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាតពាក្យ "ទេសចរ" មានន័យថា អ្នកធ្វើដំណើរលំហែកម្សាន្ត[10]។

ចំណែកវចនានុក្រម ទេសចរ ត្រូវបានឲ្យនិយមន័យថា ជានរណាម្នាក់ដែលមកលេងកន្លែងកំសាន្ត ដើម្បីភាពសប្បាយរីករាយ និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ដែលជាទូទៅគឺនៅពេលឈប់សម្រាក[11]។

ទេសចរគឺជាអ្នកដែលទទួលសេវាកម្មពីវិស័យទេសចរណ៍ និងប្រើប្រាស់នូវផលិតផលទេសចរណ៍ ដូចជា កម្មវិធីដំណើរទស្សនកិច្ច សេវាកម្ម ឬទំនិញ[12]។

សរុបជារួមទោះបីជាមានការលើកឡើងពីទស្សនៈខុសៗគ្នា ប៉ុន្តែអត្ថន័យគឺមានភាពប្រហាក់ប្រហែល និងស្រដៀងគ្នាដែល ទេសចរ គឺសំដៅដល់បុគ្គលដែលធ្វើដំណើរមកដល់តំបន់ផ្សេងពីកន្លែងដែលគេរស់នៅ មានរយៈពេលមិនតិចជាង២៤ម៉ោង ដើម្បីភាពសប្បាយរីករាយនៅថ្ងៃសម្រាក។

## ១.៣. ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព

ក្នុងការកសាងប្រទេសមួយឲ្យរីកចម្រើន គឺទាមទារឲ្យមានការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ជាពិសេសគឺផ្តោតសំខាន់ទៅលើវិស័យណាដែលមានអានុភាព និងសក្តានុពលខ្ពស់ជាងគេ។ ដោយឡែកដូចជាយើងកំពុងតែសិក្សាអំពីការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព ដូចនេះ យើងគប្បីស្វែងយល់ឲ្យបានលំអិតអំពីនិយមន័យនៃពាក្យនេះផងដែរ។ មានទស្សនជាច្រើនទាក់ទងនឹងការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព ប៉ុន្តែទស្សនទាំងនោះសុទ្ធតែមានអត្ថន័យប្រហាក់ប្រហែលគ្នា។ មុននិងស្វែងយល់ពីអត្ថន័យនៃឃ្លាខាងលើយើងត្រូវស្គាល់អត្ថន័យនៃពាក្យ អភិវឌ្ឍន៍ និង និរន្តរភាព ជាមុនសិន ដែលមានអត្ថន័យដូចខាងក្រោម :

យោងទៅតាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បានពន្យល់ថា "ការអភិវឌ្ឍ" ជាការចម្រើនក្រៃលែង លូតលាស់ចម្រើន[13]។

[10] https://www.thmeythmey.com/?page=detail&ctype=article&id=22099&lg=kh&paginate=2 (ចូលទស្សនា ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ១១៖១១នាទី)

[11] http://dictionary.cambridge.org/dictionary/english/tourist (ចូលទស្សនា ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ១១៖២៦នាទី)

[12] សួន ព៉ានី, ឃិន ច័ន្ទសុធី, ទឹម សុធា, ជិន វិចិត្រា, "ទេសចរណ៍ ទ្រឹស្តី និងទស្សនៈ ជាមូលដ្ឋាន" ២០០៦ ទំព័រ៤០

[13] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត "ភាគទី២"

ចំណែកសៀវភៅរបស់លោក Jones Charles (2002) បានបញ្ជាក់ថា ការអភិវឌ្ឍគឺជាដំណើរការនៃការរីកចម្រើនក្នុងរយៈពេលវែង និងប្រកបដោយស្ថិរភាព ដែលជាមូលដ្ឋានក្នុងការកែប្រែបរិបទសង្គម សេដ្ឋកិច្ច នយោបាយ វប្បធម៌ ឲ្យកាន់តែមានភាពល្អប្រសើរឡើង[14]។

ក្នុងសៀវភៅ ការអភិវឌ្ឍនិងផែនការទេសចរណ៍ បានពន្យល់ថា ការអភិវឌ្ឍគឺជា ការផ្លាស់ប្តូរពីអ្វីដែលគ្មានទៅជាមាន អ្វីដែលមានស្រាប់ឲ្យមានលក្ខណៈសម្បត្តិកាន់តែល្អប្រសើរឡើងប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព[15]។

ចំណែកពាក្យ និរន្តរភាព មានន័យថាសមត្ថភាពដែលត្រូវបានរក្សានៅអត្រាជាក់លាក់ឬកម្រិតដដែលមួយ ជៀសវាងការកាត់បន្ថយធនធានធម្មជាតិដើម្បីរក្សាតុល្យភាពដើមឲ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើបាន[16]។

យោងទៅតាមវចនានុក្រម Cambridge dictionary គេឲ្យនិយមន័យ និរន្តរភាព ថា ជាគំនិតដែលទំនិញនិងសេវាកម្មគួរតែត្រូវបាន ផលិតតាមរបៀបដោយមិនប្រើប្រាស់ធនធានដែលមិនអាចកើតឡើងវិញបាន និងមិនបំផ្លាញបរិស្ថាន[17]។

នៅក្នុងរបាយការណ៍មួយដែលបោះពុម្ពដោយគណៈកម្មការដើម្បីបរិស្ថាន និងការអភិវឌ្ឍពិភពលោក (The World Commission on Environment and Development) បានកំណត់និយមន័យនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពថាៈ ការអភិវឌ្ឍដែលធ្វើឲ្យសម្រេចបាននូវសេចក្តីត្រូវការនាពេលបច្ចុប្បន្ន ដោយពុំបានធ្វើឲ្យបាត់បង់នូវសមត្ថភាព ហើយអាចផ្តល់ឲ្យអ្នកជំនាន់ក្រោយទទួលបាននូវផលប្រយោជន៍តាមសេចក្តីត្រូវការរបស់គេផងដែរ[18]។

---

[14] ប្រាក់ សុផាន់ណា, ផុត សុផាត, "ការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា," (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១១), ទំព័រ៦

[15] ហុង វណ្ណៈ, ឈឹម ផាន់ណា "ការអភិវឌ្ឍនិងផែនការទេសចរណ៍" ២០១៦, ទំព័រទី១២

[16] http://www.businessdictionary.com/definition/sustainability.html (ចូលទស្សនា ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ៨ៈ១៧នាទី)

[17] http://dictionary.cambridge.org/dictionary/english/sustainability (ចូលទស្សនា ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ៨ៈ៤៦នាទី)

[18] លន់ ពិសិដ្ឋ "ទស្សនទាន និងគោលការណ៍ជាមូលដ្ឋាន ស្តីពីនិរន្តរភាពនៃការអភិវឌ្ឍ" (ក្នុងរបាយការណ៍មួយដែលបោះពុម្ពដោយគណៈកម្មការដើម្បីបរិស្ថាន និងការអភិវឌ្ឍពិភពលោក)

អង្គការទេសចរណ៍ពិភពលោកបានឲ្យនិយមនន័យ "ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព" ថាជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ទេសចរ និងម្ចាស់ស្រុកក្នុងតំបន់នាពេលបច្ចុប្បន្នដោយមានការការពារ និងបង្កើតជាឱកាសសម្រាប់ប្រើប្រាស់នាពេលអនាគត[19]។

អត្ថន័យនៃឃ្លា "ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព" ត្រូវបានបញ្ចូលខ្លឹមសារថាជាការអភិរក្ស ការពារ និងកែលំអរឲ្យបានសមស្របនូវទីកន្លែងដែលមានសម្បត្តិវប្បធម៌ និងធនធានធម្មជាតិដែល ជាមូលដ្ឋានគ្រឹះសម្រាប់វិស័យទេសចរណ៍។ ជាការជំរុញកិច្ចអភិវឌ្ឍទេសចរណ៍ និងធ្វើឲ្យអ្នកពាក់ព័ន្ធ ទទួលផលពីទេសចរណ៍ប្រកបដោយសមធម៌បង្កើនអត្ថប្រយោជន៍ កាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិស័យទេសចរណ៍ មកលើសេដ្ឋកិច្ចសង្គម វប្បធម៌ បរិស្ថាន។ ភាពធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅយកចិត្តទុកដាក់ដោះស្រាយបញ្ហាតម្រូវការ និងការគោរពនូវតម្លៃរបស់សហគមន៍។ វាក៏ជាការចែករំលែកបទពិសោធប្រកបដោយគុណភាពខ្ពស់ដើម្បីបង្កើននូវកម្រិតនៃការពេញចិត្តរបស់ទេសចរក្នុងការទស្សនាកំសាន្ត និងទាក់ទាញឲ្យមានការផ្សព្វផ្សាយបន្ត ព្រមទាំងការវិលត្រឡប់មកវិញជាថ្មីម្តងទៀត។ ហើយក៏ជាការថែរក្សានូវគុណភាពនៃសម្បត្តិ និងធនធានទាំងអស់ទៅតាមវិធីដដែលអាចទ្រទ្រង់ផលិតភាពយូរអង្វែង និងការអភិវឌ្ឍដែលធ្វើឲ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយ[20]។

ឆ្លងតាមការបកស្រាយខាងលើ អត្ថន័យនៃពាក្យនីមួយៗគឺសុទ្ធតែមានអត្ថន័យប្រហាក់ប្រហែលគ្នា ដែលសុទ្ធសឹងតែរួមចំណែកបំពេញអត្ថន័យឲ្យឃ្លាប្រយោគនៃ ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព ដែលយើងអាចសរុបអត្ថន័យជារួមថា "ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព" គឺជាការធ្វើឲ្យវិស័យទេសចរណ៍មានភាពចម្រើនល្អតលាស់ដោយជៀសវាងការកាត់បន្ថយធនធានធម្មជាតិនាពេលបច្ចុប្បន្ន មានការការពារ បង្កើតជាឱកាសសម្រាប់ប្រើប្រាស់នាពេលអនាគត និងអាចទ្រទ្រង់ផលិតភាពយូរអង្វែងដែលធ្វើឲ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយ។

## ១.៤. ផលប៉ះពាល់អវិជ្ជមានចំពោះការអភិវឌ្ឍទេសចរណ៍

ជាទូទៅឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍តែងមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានទៅតាមការអនុវត្តជាក់ស្តែង។ ផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលទាំងនេះអាចមានឥទ្ធិពលតិច ឬច្រើនមកលើការ អភិវឌ្ឍទេសចរណ៍អាស្រ័យទៅលើការយកចិត្តទុកដាក់របស់ដៃគូអភិវឌ្ឍន៍។

[19] ហុង វណ្ណៈ, ឈឹម ដាន់ណា "ការអភិវឌ្ឍនិងផែនការទេសចរណ៍" ២០១៦, ទំព័រទី៧៧

[20] ស៊ូ គឹមព្រឹទ្ធា "គោលនយោបាយជាតិទេសចរណ៍" ២០១៥ ទំព័រទី៨

ដូច្នេះហើយឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍ បានធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម។

ផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ច : ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍មានផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ច។ ការខាតបង់ប្រាក់ចំណេញសេដ្ឋកិច្ចដោយសាររាល់ទំនិញ បរិក្ខារសម្ភារៈ និងរបស់របរប្រើប្រាស់ផ្សេងៗជាច្រើនអាចមានទាំងបន្លែ ត្រី និងសាច់ដែលត្រូវប្រើប្រាស់ក្នុងវិស័យទេសចរណ៍ត្រូវបាននាំចូលមកពីបរទេស។ ភាពគ្មានលំនឹងនៃសេដ្ឋកិច្ច និងអតិផរណារូបិយបណ្ណជាតិដោយការប្រើប្រាស់សេរីនៃរូបិយបណ្ណបរទេស និងដោយគ្មានសណ្តាប់ធ្នាប់។ ការអភិវឌ្ឍទេសចរណ៍មានឥទ្ធិពលចំពោះសេដ្ឋកិច្ចជាអវិជ្ជមាន ដោយសារតែការផ្តល់ឱកាសការងារ និងការលើកទឹកចិត្តច្រើនពេកដល់ ជនបរទេសមកបម្រើការងារដោយមានទាំងអ្នកជំនាញចាំបាច់ និងមិនចាំបាច់ដែលចូលមកក្នុងតំបន់អភិវឌ្ឍន៍។

ផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន : ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍មានផលប៉ះពាល់ជាអវិជ្ជមានចំពោះបរិស្ថាន ពីព្រោះក្នុងតំបន់ទេសចរណ៍មិនមានការគ្រប់គ្រងឱតដល់ដូចជាការចោលសម្រាម គ្មានបន្ទប់អនាម័យ ដោយសារតែគ្មានមធ្យោបាយ និងការគិតគូរត្រឹមត្រូវ។ ភាពខ្វះអនាម័យ ការរស់នៅ ការទទួលទានអាហារ និងសកម្មភាពផ្សេងៗនាំឲ្យមានការបំពុលបរិយាកាស និងកើនឡើងនូវកាកសំណល់រឹងរាវ។ ភាពអាប់អួរបរិយាកាសក្នុងទីប្រជុំជន ឬរមណីយដ្ឋានដោយបណ្តាសេវាកម្មទេសចរណ៍មួយចំនួនរួមមាន សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានជាដើម ពុំមានចំណតរថយន្តគ្រប់គ្រាន់ និងត្រឹមត្រូវធ្វើឲ្យមានភាពអនាធិបតេយ្យនៅតាមដងផ្លូវ និងទីធ្លាសាធារណៈ។

ផលប៉ះពាល់អវិជ្ជមានចំពោះវប្បធម៌ : ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍មានផលប៉ះពាល់ចំពោះវប្បធម៌ពី ព្រោះនៅពេលបរិមាណទេសចរចូលមកទស្សនាមានច្រើនលើសលប់នោះអាចធ្វើឲ្យម្ចាស់ស្រុកឬសហគមន៍មានទង្វើមិនសមរម្យទៅលើពួកគេ។ កត្តាហេតុនេះបានធ្វើឲ្យមានភាពធុញទ្រាន់ និងជិនណាយ។ មានភាពរិចរឹលនូវរម្មណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រ និងវត្ថុបុរាណសំខាន់ៗនានាដែលបង្កឡើងមកពីការប្រើប្រាស់កម្រិតនៃការទស្សនាលើសកម្រិត និងការប៉ះពាល់ផ្សេងៗ។ យុវវ័យងាយនឹងត្រងត្រាប់តាមនូវទំនៀមទំលាប់ ប្រពៃណី វប្បធម៌ អាកប្បកិរិយា និងលក្ខណៈផ្សេងទៀតនៃវប្បធម៌បរទេសដែលធ្វើឲ្យប្រាសចាកពីវប្បធម៌ជាតិរបស់ខ្លួន។

ផលប៉ះពាល់អវិជ្ជមានចំពោះសង្គម : ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍មានផលប៉ះពាល់ចំពោះសង្គម ព្រោះមានការកើតឡើងនូវអំពើឧក្រិដ្ឋកម្មផ្សេងៗដូចជា អំពើឆក់ប្លន់ លួច

ការចាប់ជម្រិត ឆបោក និងការក្លែងបន្លំ។ ការបណ្តោយឲ្យមានការប្រើប្រាស់និងចរាចរណ៍ថ្នាំញៀន ពេស្យាចារ ការជួញដូរស្ត្រី និងកុមារ។ រឿងសំខាន់មួយទៀតគឺការកើតមានជំងឺឆ្លងផ្សេងៗដូចជា ជំងឺអេដស៍ ជំងឺសារស៍ ជំងឺគ្រុនផ្តាសាយបក្សី-ល-។ ជម្លោះដោយសារប្រជាពលរដ្ឋមិនទទួលបាន សិទ្ធសេរីភាពចូលទៅទស្សនា ឬកំសាន្តមិនបង់ប្រាក់ នៅរមណីយដ្ឋានទេសចរណ៍ រមណីយដ្ឋាន អភិវឌ្ឍ ឬទីតាំងកម្សាន្តនានាក្នុងស្រុក។

## ១.៥. បទពិសោធន៍បរទេសទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាព

នាពេលបច្ចុប្បន្នវិស័យទេសចរណ៍សឹងតែគ្រប់ បណ្តាលប្រទេសជុំវិញលោកបានកំពុងតែ រីកចម្រើនព្រមទាំងបោះជំហានទៅមុខយ៉ាងសកម្ម ដោយសារតែវិស័យនេះបានក្លាយទៅជាវិស័យ មួយយ៉ាងសំខាន់ក្នុងការជួយនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិ មិនតែប៉ុណ្ណោះគ្រប់បណ្តាលប្រទេសទាំង ឡាយក៏កំពុងតែខិតខំបង្កើតយុទ្ធសាស្ត្រ ព្រមទាំងធ្វើការរៀបចំកែច្នៃ ព្រមទាំងបង្កើតនូវផលិតផល ថ្មីដែលគួរជាទីទាក់ទាញសម្រាប់ស្រូបយកនូវ កំណើនទេសចរដែលមានទំនោរក្នុងការដើរកំសាន្ត ពីមួយឆ្នាំទៅមួយឆ្នាំ មិនថាប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសអភិវឌ្ឍនោះទេ ពួកគេបានព្យាយាមដាក់ ចេញនូវផែនការនិងកំណត់គោលនយោបាយជាច្រើនក្នុងការអភិវឌ្ឍតំបន់ទេសចរណ៍ប្រកបដោយ និរន្តភាព។

ក្នុងនោះដោយយើងចាប់អារម្មណ៍ឃើញប្រទេស២ គឺប្រទេស កាណាដា និងប្រទេសថៃដែល ពួកគេបានធ្វើការអភិវឌ្ឍតំបន់ទេសចរណ៍របស់ពួកគេបានយ៉ាងស្រស់ស្អាតគួរជាទីទស្សនា ។

**ករណីសិក្សាប្រទេសកាណាដា តំបន់ ហៃ រីវើ** Hay River

ករណីសិក្សានេះយើងបានដកស្រង់ចេញ ពីសារណាបញ្ចប់ការសិក្សាមួយក្រោមប្រធានបទ ការអភិវឌ្ឍតំបន់ហៃ រីវើ ខាងជើងឈាងខាងលិច "Hay River Northwest Territories Tourism Development Plan 2012" នៃសាកលវិទ្យាល័យ Whaterloo ។ Hay River ជាទន្លេធំមួយនៅ ភាគជើងនៃ Alberta ជាតំបន់ដ៏ មានសក្តានុពលទាកទាញសឹងតែគ្រប់រដូវកាល ។ តំបន់នេះមិន ត្រឹមតែផ្តល់ឲ្យទេសចរនៅអារម្មណ៍ល្អពេលទៅដល់នោះទេ ប៉ុន្តែវាគឺជាកន្លែងសម្រាប់ទេសចរ សម្រាកកម្សាន្តដោយសារតែតំបន់នោះក៏មានផ្តល់ជាសេវាស្នាក់នៅជូនដល់ទេសចរផងដែរ មិនតែ ប៉ុណ្ណោះទេសចរក៏អាចអង្គុយស្ទួយត្រី បើសិនជាទេសចរដែលមានចំនូលចិត្តក្នុងការបរបាញ់សត្វ តំបន់នោះគឺជាកន្លែងដែលគួរតែគិតដល់មុនគេ នាពេលរដូវស្លឹកឈើជ្រុះ កាន់តែពិសេសនារដូវ ធ្លាក់ទឹកកកតំបន់នេះក៏សាកសមសម្រាប់ អ្នកដែលមានចំណង់ខាងជិះស្គីទៀតផងទេសចរអាច បន្ថែមពេលវេលាកាន់តែអស្ចារ្យជាមួយក្រុមគ្រួសារ មិត្តភក្តិនិងមនុស្សជាទីស្រឡាញ់។

ដូចដែលយើងបានរៀបរាប់ខាងលើនេះ ហើយទោះបីជាតំបន់នោះមានភាពទាក់ទាញ និងទេសភាពស្អាតយ៉ាងណាក៏ដោយបើសិនជាតំបន់នោះមិនទទួលបាន ការរៀបចំនិងសិក្សាអំពីបញ្ហាប្រឈមក៏ដូចជាកង្វះខាត សេវាសម្រាប់បម្រើដល់ទេសចរទេតំបន់នោះក៏មិនអាចក្លាយជាតំបន់គោលដៅទេសចរណ៍បានទេ។

យ៉ាងណាមិញតាមរយៈការសិក្សាគេបានរកឃើញនិងស្រាវជ្រាវពីបញ្ហា និយមួយចំនួនដែលគួរយកពិចារណានៅក្នុងតំបន់ដែលមានដូចជា៖

**ការអភិវឌ្ឍនិងពិនិត្យគុណភាពទឹក** គុណភាពទឹកគឺជារឿងសំខាន់ណាស់សម្រាប់តំបន់ព្រោះវាគឺជាផ្នែកមួយក្នុងចំណោមភាពទាក់ទាញជាច្រើនទៀតនៅក្នុងតំបន់។ គុណភាពទឹកងាយនិងរងផលប៉ះពាល់បំផុតអវិជ្ជមានបំផុតប្រសិនបើយើងមិនបានថែរក្សា និងការពារវាបានល្អនោះទេ។ ដោយមានការគ្រប់គ្រងកាកសំណល់ឲ្យបានត្រឹមត្រូវជៀសវាងការបង្ហូចូលទន្លេ។ ប្រការសំខាន់ការរៀបចំកាកសំណល់ត្រូវបាន គ្រប់គ្រងដោយប្រើប្រាស់ផ្លាកសញ្ញាក៏ដូចជា ធុងសម្រាប់ផ្ទុកកាកសំណល់សម្រាប់ទេសចរ។

**ការអភិវឌ្ឍកំពង់ផែសម្រាប់ទូកតូច** កន្លែងសម្រាប់ចតទូកតូចៗត្រូវបានរៀបចំ ដើម្បីបង្កើតភាពងាយស្រួលក្នុងការចេញនិងចូល ទូកអាហារនានាគួរតែបង្កើតសម្រាប់ជាផលិតផលថ្មីដល់តំបន់ដោយមិនធ្វើឲ្យតំបន់មានភាពសាំដដែលៗ។ ការបង្កើតនេះគួរតែធ្វើការសហការជាប្រជាជនក្នុងតំបន់ដោយជាហេតុនាំមកនូវការងារថ្មីៗដល់ប្រជាជនផងដែល។

**បង្កើតជាវេទិការណែនាំ** ការបង្កើតវាឡើងគឺក្នុងគោលបំណងបង្ហាញពីតម្លៃនៃទសចរដល់ប្រជាជនក្នុងតំបន់ឲ្យមើលឃើញពីសារប្រយោជន៍ដែលពួកគាត់ទទួលបាន ។ ជាការគួរ គួរតែអញ្ជើញប្រជាជន មន្ត្រីដែលពាក់ពន្ធ័ អាជីវករដើម្បីមកស្តាប់នូវអត្ថប្រយោជន៍ដែលពួកគាត់ទទួលបានពីទេសចរ ហើយគួរធ្វើយ៉ាងណាដើម្បីរក្សា ជនិងអភិវឌ្ឍតំបន់ឲ្យកាន់តែមានភាពទាក់ទាញមិនតែប៉ុណ្ណោះប្រការសំខាន់គួរតែលើកទឹកចិត្តដល់មន្ត្រីដែល ពាក់ព័ន្ធដើម្បីពួកគាត់កាន់តែខិតខំពង្រឹងសន្តិសុខនិងសុវត្ថភាពក្នុងរមណីយដ្ឋាន[21]។

## ករណីសិក្សាប្រទេសថៃ ( ផ្សារទឹក ដាំណឹនសាកដាត Damnoen Saduak )

នៅក្នុងតំបន់អាស៊ីអាគ្នេយ យើងបានមើលឃើញពីវឌ្ឍភាពនៃការរីកចម្រើនលើវិស័យទេសចរណ៍យ៉ាងខ្លាំងនៅក្នុង ប៉ុន្មានទសវត្សចុងក្រោយនេះនៃប្រទេសថៃ។ ក្នុងនាមជាសមាជិកអាស៊ានដូចគ្នាយើងមានការ ចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើសន្ទុះនៃការជឿនលឿនយ៉ាងខ្លាំង

[21] Hay River Tourism Dev elopement 2012

ក្នុងវិស័យទេសចរណ៍នៃប្រទេសមួយនេះ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៦ ប្រទេសថៃទទួលទេសចរអន្តរជាតិប្រមាណ ៣២.៥៩លាននាក់ ដោយកើនឡើង១០ភាគរយធៀបទៅនឹងឆ្នាំ២០១៥ និងរកចំណូលបាន៧១.៤៣ាន់លាន កើនឡើង ១១ភាគរយធៀបទៅនឹងឆ្នាំ២០១៥[22]។

ដោយមើលឃើញថាវិស័យទេចរណ៍ប្រទេសថៃមានកំណើនខ្ពស់បែបនេះហើយទើបយើងខ្ញុំមានបំណងជ្រើសរើសយក តំបន់ទេសចរណ៍មួយដែលស្ថិតនៅចម្ងាយប្រមាណ១០០គីឡូ ពីទីក្រុងបាងកកក មានផ្សារបណ្តែតទឹកមួយឈ្មោះថា "ដាំណិនសាកដាត Damnoen Saduak" ។ ផ្សារមួយនេះត្រូវបានគេចាត់ទុកថាជាផ្សារបណ្តែតទឹកដែលទាក់ទាញ ទេសចរបំផុតរបស់ប្រទេសថៃ ទេសចរបរទេសភាគច្រើន ដែលទៅដើរកំសាន្តប្រទេសថៃភាគច្រើនមិនសូវជារំលងផ្សារមួយនេះទេ។ ការធ្វើដំណើរទៅផ្សារនេះទៀតសោតកាន់តែមានលក្ខណៈងាយស្រួល ព្រោះប្រព័ន្ធដឹកជញ្ជូននៅក្នុងទីក្រុងបាងកកមានសម្បូរហូតហៀរ ក្នុងនោះយើងអាចធ្វើដំណើរទៅដោយប្រើមធ្យាបាយនានាដូចជា Taxi រថយន្តក្រុងជាដើម ហើយមធ្យាបាយដ៏ងាយស្រួលមួយទៀតគឺ នៅពេលទៅដល់ទីក្រុងយើងអាចធ្វើការស្វែងរកក្រុមហ៊ុនទេសចរណ៍ដើម្បីធ្វើការដើរកំសាន្ត ដោយនៅក្នុងនោះកាន់តែពិសេសយើងអាចប្រើប្រាស់ប្រព័ន្ធទូរសព្ទ័ Smart phone ក្នុងការកក់ ដោយតម្លៃយើងអាចជ្រើសរើសបាន[23]។

ចំណុចរសើបដែលយើងចង់បាននោះគឺការអភិវឌ្ឍតំបន់ដែលរដ្ឋាភិបាលប្រទេសថៃមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើះ

ការរៀបចំកន្លែងលក់ដូរសម្រាប់អាជីករ មានការបែងចែកជាតូបតូចៗ សម្រាប់ឲ្យប្រជាពលរដ្ឋលក់ដូរនៅទីនោះហើយក៏អ្នកខ្លះទៀតគឺគេអាចប្រើជាទូកសម្រាប់ជាមធ្យាយបាយដែលពេញនិយមបំផុតនៅក្នុងផ្សារទឹកនោះ។

គុណភាពទឹក នៅក្នុងតំបន់នោះយ៉ាងខ្លាំងដោយសារតែនៅក្នុងតំបន់នោះភាគច្រើននៃអាជីករគឺប្រកបរបស់លក់ដូរជា បន្លែជជជជ ផ្លែឈើ និងគ្រឿងបរិភាគនានា ប៉ុន្តែក៏មានអាជីករខ្លះលក់ជាវត្ថុអនុស្សាវរីយជូនដល់ទេសចរផងដែល[24]។

ផ្ទះសំណាក់ កាន់តែមានភាពងាយស្រួលសម្រាប់ទេសចរដែលមានបំណងចង់ទៅទស្សនានៅទីនោះបានយូរគឺពួកគេអាចទៅដល់ខេត្តតែម្តង ដែលមិនឆ្ងាយប៉ុន្មានពីទីក្រុងនោះទេ ព្រោះនៅក្បែរតំបន់នោះរដ្ឋាភិបាលថៃបានធ្វើការអភិវឌ្ឍនិងជម្រុញលើកស្ទួយនៅសេវាសាធារណៈ ដោយឲ្យ

[22] seattletime.com ចូលទស្សនានៅថ្ងៃទី ៨មិថុនា ២០១៧

[23] Bankok.com

[24] https://bkk.tours/attraction/damnoen-saduak-floating-market/

ប្រជាជនរបស់គេបើជាផ្ទះសំណាក់ និងសណ្ឋាគារជាមូលហេតុនាំឲ្យទេសចរកាន់តែមានភាពងាយស្រួលបន្ថែមទៀត។

ការបង្កើតផលិតផលនៅក្នុងតំបន់ កាន់តែទាក់ទាញជាងនេះទៅទៀតនៅផ្សារទឹកនេះគេមានជាការបង្កើតនូវ ចំការស្ករដូងដែលជាកន្លែងដែលអាចឲ្យយើងចូលសាកនូវរស់ជាតិដ៏ឆ្ងាញ់នៃស្ករដូងព្រមទាំងអាចទិញនូវផលិតផលក្នុងស្រុកដែលផលិតដោយស្ករដូងធម្មជាតិទៀតផង។

មធ្យាយបាយធ្វើដំណើរ និងបដិសណ្ឋារកិច្ច ផ្លូវធ្វើដំណើទៅគឺបង្កជាលក្ខណៈងាយស្រួលដល់ទេចរយ៉ាងខ្លាំង ដោយទេសចរអាចប្រើប្រាស់មធ្យាបាយនានាជាច្រើនដូចជា Taxi កង់បី ឡានក្រុងជាដើម។ ជាងនេះទៅទៀតពេលដល់ទីតាំងគឺមានអ្នកចាំទទួលស្វាគមន៍យើងនៅកន្លែងចំណតទូកដែលយើងចង់ជួលជិះទស្សនាទៀតផង អាជីវករនៅទីនោះភាគច្រើនគឺគេប្រើទឹកដូងសម្រាប់ទទួលទេសចរ មានន័យថាកំឡុងពេលដែលយើងរងចាំទូក គឺពួកគេប្រាស់ប្រើទឹកដូងសម្រាប់ទទួលទេសចរ។ ចំណែកឯការជួលទូកគឺពួកគេបានកំណត់នូវចំនួនទេសចរយ៉ាងច្បាស់ដោយក្នុងមួយទូកគឺ៦នាក់។

ការរៀបចំសន្តប់ធ្នាប់ យើងមើលឃើញថាទោះបីជា ផ្សារនេះសម្បូរកកទៅដោយទូក មានទាំងអាជីវករ ជជជនិងទេសចរក៏ដោយប៉ុន្តែ មើលទៅហាក់ដូចជាមិនមែនជាបញ្ហាចោទនោះទេដោយសារតែ ពួកគេយកចិត្តទុកដាក់ខ្លាំងទៅលើសុវត្ថិភាពរបស់ទេសចរ និងម៉្យាងអ្នកបើកទូកសុទ្ធតែមានជំនាញស្រាប់បើទោះ បីជាទៅដល់តំបន់ដែលកកទៅដោយ ទូកលក់ចំណីអាហារក៏ដោយបន្តែពួកគេនៅតែអាចបញ្ចេសគ្នាបានដោយមិនមានបញ្ហា។ មួយវិញទៀតយើងកត់សម្គាល់ឃើញថា ផ្លូវទៅនិងផ្លូវមកគឺមិនដូចគ្នាទេ ដូចនេះ បញ្ហាបារម្ភចំពោះសុវត្ថិភាពក៏មិនមានជាហានិភ័យនោះទេ។

# ជំពូកទី២

# ស្ថានភាពទូទៅទេសចរណ៍រាជធានីភ្នំពេញ

## ២.១. ស្ថានភាពទូទៅរាជធានីភ្នំពេញ

រាជធានីភ្នំពេញគឺ ជាទីក្រុងនិងបេះដូងនៃរាជាណាក្រកម្ពុជា បើទោះបីជាពុំសូវទទួលបាន កេរ្តិ៍ឈ្មោះ ថាជារាជធានីទំនើបទាន់សម័យដូចជាទីក្រុងនៃប្រទេសដទៃក៏ដោយ ប៉ុន្តែយើងសង្កេត ឃើញថាទីក្រុងភ្នំពេញ មានសក្កានុពលទាក់ទាញទេសចរយ៉ាងខ្លាំងផងដែល តួយ៉ាងរាជធានី ចតុមុខ ការដើរកំសាន្តនាពេលរាត្រី និងការជិះទូកកំសាន្តតាមដងទន្លេ ព្រមទាំងតំបន់ទេសចរណ៍ ជាច្រើនសន្ធឹកសន្ធាប់ទៀត ។ បើនិយាយពីភាពចំណាស់ គេអាចចាក់ទុកបានថា ភ្នំពេញជាទីក្រុង ចំណាស់មួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានប្រវត្តិរឿងរ៉ាវគួរឲ្យចាប់អារម្មណ៍សម្រាប់ទេចរដែល មានទំនោរវប្បធម៌ប្រវត្តិ។ លើសពីនេះទៅទៀត ភ្នំពេញគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់ប្រទេស កម្ពុជាដូចគ្នាដែរ វាក៏ត្រូវបានចាត់ទុកថាជាផ្នែកដ៏ធំនៃសេដ្ឋកិច្ចរបស់កម្ពុជា។ អត្រាកំណើន សេដ្ឋកិច្ច តួលេខបាន កើនឡើងទ្វេដងក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងផុតមកនេះ ដែលធ្វើឲ្យមានសន្ទុះ ឡើងនូវការលូតលាស់សេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅភ្នំពេញ។

រាជធានីភ្នំពេមានផ្ទៃក្រឡា៦៧៨,៤៦[25]គីឡូម៉ែត្រក្រឡាស្ថិតនៅក្នុងតំបន់ខាងត្បូង-កណ្តាល នៃប្រទេសកម្ពុជា នៅចំណុច ប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ។ទន្លេទាំងនេះផ្តល់ នូវ ប្រព័ន្ធអេកូឡូស៊ីទឹកសាប និងទន្លេប្រកបដោយសក្តានុពល ជាធនធានដ៏សំខាន់សម្រាប់ លក្ខខណ្ឌ បរិស្ថានប្រកបដោយចិរភាព សោភ័ណភាព ធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុង ចម្រើនសម្រាប់ប្រជាជននៅរាជធានីភ្នំពេញ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។ភ្នំពេញ ស្ថិត នៅចំពីមុខទន្លេមេគង្គ ដែលជាទន្លេដ៏សំខាន់នៅអាស៊ីមានបណ្តោយប្រវែង ៤.២០០គីឡូម៉ែត្រ។ ប្រភពដើមនៃ ទន្លេនេះ គឺមកពីតំបន់ខ្ពង់រាបទីបេ ប្រទេសចិន ។ ទន្លេនេះហូរកាត់ ប្រទេសកម្ពុជាពី ជើងទៅត្បូង មានបណ្តោយ សរុបប្រវែង ៤៨៦គីឡូម៉ែត្រ ហើយកាត់ភូមិសាស្ត្ររាជធានីភ្នំពេញ ដែលជាចំណុចប្រសព្វទន្លេបួនមុខ បង្កើតបាននូវប្រព័ន្ធអេកូឡូស៊ី និងទឹកសាប ដ៏គួរឲ្យទាក់ទាញ សម្រាប់ រាជធានីភ្នំពេញ ។

យោងតាមអនុក្រិតរបស់រាជរដ្ឋាភិបាល លេខ៥៧៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ខណ្ឌចំនួន៣ត្រូវបានបង្កើតរួមមាន[២៦] ៖ ខណ្ឌច្បារអំពៅ បំបែកចេញពី ខណ្ឌមានជ័យ មាន៨ សង្កាត់ ទីតាំងសាលាខណ្ឌច្បារអំពៅ នៅសាលាខណ្ឌមានជ័យចាស់ ឯសាលាខណ្ឌមានជ័យថ្មី មានទីតាំងនៅសាលាចាក់អង្រែលើ។ ខណ្ឌជ្រោយចង្វារ បំបែកចេញខណ្ឌឬស្សីកែវ ទីតាំង សាលាខណ្ឌជ្រោយចង្វារ ស្ថិតនៅសាលាសង្កាត់ព្រែកលៀប ។ ខណ្ឌព្រែកព្នៅ បំបែកចេញពី

[២៥]phnompenh. gov.kh ចូលទស្សនា ថ្ងៃទី ១៨ មិថុនា ២០១៧

[26] http://www.citynet-ap.org/En/user/resource/docs/241.pdf

ខណ្ឌសែនសុខ និងខណ្ឌពោធិ៍សែនជ័យ ទីតាំងសាលាខណ្ឌគឺនៅក្នុងសង្កាត់គោករការ។ នៅក្នុងនោះខណ្ឌទាំងអស់ចែកចេញជាសង្កាត់ ក្នុងនោះ ខណ្ឌចំការមន មាន១២សង្កាត់ ខណ្ឌដង្កោ មាន១៣សង្កាត់ ខណ្ឌដូនពេញមាន១១សង្កាត់ ខណ្ឌទួលគោកមាន១០សង្កាត់ ខណ្ឌប្រាំពីរមករាមាន៨សង្កាត់ ខណ្ឌពោធិ៍សែនជ័យ មាន១៣សង្កាត់ ខណ្ឌមានជ័យ មាន៨សង្កាត់ ខណ្ឌឬស្សីកែវមាន១១សង្កាត់ ខណ្ឌសែនសុខ មាន៦សង្កាត់ ខណ្ឌច្បារអំពៅ មាន៨សង្កាត់ ខណ្ឌជ្រោយចង្វារ មាន៥សង្កាត់ ខណ្ឌព្រែកព្នៅ មាន៥សង្កាត់។

រាជធានីភ្នំពេញ ស្ថិតនៅក្នុងមណ្ឌលទំនាបកណ្ដាល ហេតុនេះហើយមណ្ឌលនេះមិនទទួលឥទ្ធិពលខ្យល់មូសុងគ្រប់គ្រាន់នោះទេ ដោយសារតែមានជួរភ្នំក្រវាំញជាជញ្ជាំងនៃការជ្រេតចូលខ្យល់មូសសុងវស្សា ដូច្នេះក្រុងភ្នំពេញមានអាកាសធាតុក្ដៅ ពេញមួយឆ្នាំ ដោយគ្រាន់តែមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ[27]។ នៅក្នុងរាជធានី កម្រិត សីតុណ្ហភាពមានចាប់ពី ១៨ អង្សារ ដល់ ៣៨ អង្សារ សេ (៦៤ ដល់ ១០០ អង្សារ ហ្វារិនហាយ) មានរដូវចំនួនពីរ គឺ ៖ រដូវប្រាំង ចាប់ពីខែធ្នូ ដល់ខែឧសភា (រយៈពេល៦ ខែ) រដូវវស្សា ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា (រយៈពេល ៦ ខែ)។

នៅក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្ននេះគេសង្កេតឃើញថា សិប្បកម្មមានការកើនឡើងដុះដាលពាសពេញទីក្រុង ព្រោះតែប្រជាជនខ្មែរយើងបានរក្សាវប្បធម៌ ប្រពៃណីរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន លើសពីនេះសិប្បកម្មខ្មែរមានទំនាក់ទំនងជាមួយវិស័យទេសចរណ៍យ៉ាងជិតស្និត ព្រោះថាសិប្បកម្មនេះ គឺជាប្រភេទផលិតផលខ្មែរដែលធ្វើដោយដៃ មិនតែប៉ុណ្ណោះមានការតុបតែលំអយ៉ាងប្រណិតសម្រាប់ដាក់លក់ជូនទេសចរជាតិនិងអន្តរជាតិ ហើយអាចស្រូបទាញចំណូលបានយ៉ាងងាយស្រួល ។ សិប្បកម្មខ្មែរមានច្រើនទម្រង់ដូចជា៖ សិប្បកម្មគ្រឿងឈើ សិប្បកម្មគ្រឿងថ្ម សិប្បកម្មគ្រឿងស្ពាន់ សិប្បកម្មគ្រឿងចម្លាក់ សិប្បកម្មតម្បាញ សិប្បកម្មធ្វើពីដី និងជាច្រើនទៀត។

ព្រះពុទ្ធសាសនាគឺ ជាសាសនារបស់រដ្ឋ ដូចនេះហើយទើបយើងឃើញថាវត្តអារាមរីកដុះដាលពេញប្រទេសសម្រាប់ពុទ្ធសានិកទៅគោរពបូជា មិនតែប៉ុណ្ណោះវត្តអារាមក៏ជាកន្លែងទាក់ទាញទេសចរអន្តរជាតិយ៉ាងសំខាន់ផងដែលទាំងនេះគឺជា វត្តអារាមដែលមានក្នុងរាជធានី៖ វត្តព្រះធាតុ វត្តលង្ការ ព្រះសក្យមុនីចេតីយ៍ វត្តចន្ទ្រានតាព្រហ្ម វត្តមហាមន្ត្រី វត្តកិទ្ធរង្សី វត្តព្រះពុទ្ធមានបុណ្យ វត្តសារាវន្ត វត្តស្វាយពពែ វត្តទួលទំពូង វត្តព្រះកែវមរកត វត្តបុទម វត្តកោះ វត្តថាន់ វត្តនុមន្នី វត្តភ្នំ វត្តប្រាយុវង្ស វត្តសំពៅមាស វត្តស្រះចក វត្តស្វាយដង្គំ វត្តឧណ្ណាលោម វត្តសុវណ្ណរាសីរតនារាម (សំរោងកណ្ដាល) ។

[27] សាបភ្លិន, ជាន់,យ៉េនសឹន,យិន្ស៊ំ។ "កម្ពុជា ភ្នំពេញ" (ជា ដាណឺម៉ាក)។ ទិន្នន័យអាកាសធាតុ (១៩៣១- ១៩៦០) ។ វិទ្យាស្ថានឧត្តុនិយមវិទ្យា ដាណឺម៉ាក ទំព័រ ៥៥។

### ២.១.១. វិស័យនានារាជធានី

នៅក្នុងព្រះរាជណាចក្រកម្ពុជាមានវិស័យនានាជាច្រើន ប៉ុន្តែយើងសុំលើកយកតែវិស័យដែលកំពុងតែមានឥទ្ធិពលខ្លាំងនៅក្នុងរាជធានីត្រឹមតែ៥ប៉ុណ្ណោះក្នុងនោះមានៈ

**វិស័យទេសចរណ៍** វិស័យទេសចរណ៍ជាវិស័យមួយដ៏សំខាន់ ក្នុងការកសាងសេដ្ឋកិច្ចជាតិ ក្នុងមួយឆ្នាំៗទេសចរមកដល់ទស្សនាប្រទេសកម្ពុជាយ៉ាងសន្ធឹកសន្ធាប់។ រាជរដ្ឋាភិបាលក៏មិនព្រងើយកន្តើយចំពោះការកើនឡើងនៃទេសចរអន្តរជាតិនោះទេ គឺបានខិតខំធ្វើការអភិវឌ្ឍបន្ថែម នឹងរិះរកគ្រប់វិធីសាស្ត្រដើម្បី បង្កើនការទាក់ទាញទេសចរឲ្យ កាន់តែចូលមកបន្តទស្សនាប្រទេសកម្ពុជាជាបន្តផងដែល។ វិស័យនេះត្រូវបានគេចាត់ទុកថាជាវិស័យមួយដែលចូលរួមចំណែកបង្កើតប្រាក់ចំនូលជាតិ និងបង្កើតឱកាសការងារជូនប្រជាពលរដ្ឋខ្មែរទៀតផង។

**វិស័យសាងសង់** នាពេលបច្ចុប្បន្នយើងសង្កេតឃើញថាការសាងសង់នៅរាជធានីកំពុងមានការរីកលូតលាស់គួរឲ្យកត់ សម្គាល់ជាងនេះទៅទៀតក៏ជាកត្តាផ្លាស់ប្តូរមុខមាត់ថ្មីនៃរាជធានីភ្នំពេញទាំងអស់នោះរួមមានអាគារពាណិជ្ជកម្ម លំនៅដ្ឋាន និងសំណង់ អាគារខ្ពស់ៗដែល ត្រូវសាងសង់ឡើងកាន់តែសាង កាន់តែរីកដុះដាល់រួមជាមួយនិងការរចនាម៉ូដ យ៉ាងល្អប្រណិត និងទាន់សម័យ។

**វិស័យធនាគារ និង ហរិញ្ញវត្ថុ** វិស័យនេះមិនត្រឹមតែរក្សាបាននូវស្ថេរភាពជារួម ក្នុងខណៈដែលសកលលោកត្រូវជួបប្រឈមនិងវិបត្តិ កលិយុគហរិញ្ញវត្ថុប៉ុណ្ណោះទេថែមទាំងបង្កើនកម្រិតជីវភាព តាមរយៈការកៀរគរប្រាក់សន្សំ ទាំងក្នុងនិងក្រៅប្រទេស ហើយប្រែក្លាយជាប្រភពហរិញ្ញាប្បទានដ៏សំខាន់ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងបង្កើត ការងារ។

**វិស័យសុខាភិបាល** ជាវិស័យមួយដ៏សំខាន់នៅក្នុង ប្រទេសមាននាទីថែទាំ គាំពារសុខសុវត្ថិភាពប្រជាពលរដ្ឋព្រមទាំងលើសកម្ពស់សុខុមាលភាព និងអាហាររូបត្ថរបស់ប្រជាជន។

**វិស័យអប់រំ** ជាវិស័យដែលមានសារៈប្រយោជន៍ សម្រាប់ប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈដើម្បីទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដោយកសាង និងអភិវឌ្ឍនូវធនធានមនុស្ស ប្រកបដោយគុណភាព សម្ភភាព ឆ្លើយតបទៅនិងសេចក្តីត្រូវការនៃការអភិវឌ្ឍសង្គម។

## ២.២. វិស័យទេសចរណ៍រាជធានីភ្នំពេញ

ក្នុងចំណោម បណ្តាជនជាតិអាស៊ីទាំងក្នុង និងក្រៅប្រទេស រាជធានីភ្នំពេញ គឺទីក្រុងដែលមានកេរ្តិ៍ឈ្មោះល្បីក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរច្រើនជាងគេ នៅក្នុង ប្រទេសកម្ពុជា។ រាជធានីភ្នំពេញ មានទីតាំង ស្ថិតនៅប្រសព្វនៅទន្លេធំ ៣ ជាប់ដៃទន្លេ ៤ នៃទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ នៅផ្នែកខាងស្តាំមុខ ព្រះបរមរាជវាំង។រាជធានី ភ្នំពេញ ជាច្រកចូលមួយដ៏សំខាន់

នៃបណ្តាប្រទេសផ្សេងៗនៅលើពិភពលោក ជាតំបន់បេតិកភណ្ឌ មានសាសនាចំរុះជាងគេនៅលើពិភពលោក ។

ទីក្រុងនេះបានបង្ហាញនូវវប្បធម៌មួយចំនួន និងភាពទាក់ទាញបែបប្រវត្តិសាស្រ្តរួម មានព្រះបរមរាជវាំង វិហារព្រះកែវមរកត និងសារមន្ទីរជាតិ។ មិនត្រឹមប៉ុណ្ណោះ មានសណ្ឋាគារថ្នាក់ផ្កាយប្រាំ ផ្ទះសំណាក់ ភោជនីយដ្ឋាន អន្តរជាតិ ហាងគុយទាវតាមដងផ្លូវ ក្លិបកំសាន្តថ្នាក់ក្នុងស្រុក និងក្លឹបឌីស្កូថ្នាក់អន្តរជាតិ ។

រាជធានី ភ្នំពេញ ជារាជធានីដែលមានកំណើនប្រជាជនផ្លាស់ប្តូរ ដូចបណ្តា ទីក្រុងទេសចរណ៍អាស៊ានដទៃ ទៀតដែរ។ បរិមាណភោជនីយដ្ឋាន និងសណ្ឋាគារ បានរីកពលដាលគួរឲ្យកត់សំគាល់ នៅប៉ុន្មានឆ្នាំកន្លងទៅនេះ មិនត្រឹមតែប៉ុណ្ណោះ កំណើនភ្ញៀវទេសចរណ៍បានកើនឡើងយ៉ាងគំហុក ពីមួយឆ្នាំទៅមួយឆ្នាំ។ ច្រកទ្វារចេញចូល អន្តរជាតិផ្លូវគោកចំនួន ៣ ត្រូវបានចាប់ដំណើរការនៅឆ្នាំ ២០០៨ ហើយសព្វថ្ងៃ យើងអាចធ្វើដំណើរតាមផ្លូវ អាកាសដោយផ្ទាល់ពីរាជធានីភ្នំពេញទៅទីក្រុងអាស៊ានមួយចំនួនផងដែរ។ ប្រព័ន្ធផ្លូវគោកត្រូវបានជួសជុលនិងធ្វើ ឲ្យប្រសើរឡើងបន្តិចម្តងៗ ធ្វើឲ្យការធ្វើដំណើរមានភាពងាយស្រួលរួមទាំងការដឹកជញ្ជូនតាមជើងយន្តហោះក្នុង ស្រុក និងការបំរើសេវាទៀងទាត់តាមរថយន្តក្រុងពីរាជធានីទៅទីក្រុងធំៗដូចជាក្រុងព្រះសីហនុ និងកំពង់ចាមជា ដើម។ ព្រះរាជាណាចក្រកម្ពុជាកំពុងក្លាយជាកន្លែងមានភាពទាក់ទាញ និងងាយស្រួលសម្រាប់ភ្ញៀវទេសចរណ៍មក ទស្សនាជារៀងរាល់ថ្ងៃ ទន្លេមេគង្គដ៏មហិមាជាសរសៃឈាម ដែលហូរកាត់ចំកណ្តាលបេះដូងនៃតំបន់អាស៊ីអគ្នេយ៍។ ដោយមានប្រភពពីខ្ពង់រាបទីបេត៌ប្រទេសចិន ទន្លេនេះបានហូរកាត់ប្រទេសចិន មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម មុនពេលហូរចាក់ទៅសមុទ្រចិនខាងត្បូងវិញ។ នៅពេលទន្លេនេះហូរកាត់កម្ពុជា វាបានហូរចាក់បំពេញទៅបឹងទន្លេសាបរបស់កម្ពុជា ដែលជាបឹងដ៏ធំបំផុតនៅអាស៊ីអាគ្នេយ៍។ នៅពេលទស្សនាកម្ពុជា អ្នកទេសចរអាចធ្វើដំណើរ តាមដងទន្លេមេគង្គនិងគយគន់ទេសភាពដ៏ត្រកាលតាមបណ្តោយច្រាំងទន្លេ។ មានសហគមន៍ជាច្រើន រស់នៅប៉ប្រះនឹងមាត់ទន្លេអស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមកហើយ។ អ្នកទេសចរអាចឈប់សំចតដើម្បីទទួលទានទឹកតែដ៏ឆ្ងាញ់ពិសារ ទស្សនាភូមិតូចៗនៅតាមបណ្តោយច្រាំងទន្លេ គយគន់ប្រាសាទដែលអើតលឹមៗពីចម្ងាយ និងស្រូបយកខ្យល់អាកាសដ៏បរិសុទ្ធ នៅកណ្តាលបឹងធម្មជាតិនេះ។

កាណូតទេសចរណ៍គ្រចប់ធុនរង់ចាំដឹកភ្ញៀវទេសចរនៅតាមបណ្តោយច្រាំងទន្លេ ហើយតាមធម្មតា នៅចន្លោះផ្លូវ១៨៤និង១៣០ និងនៅឯកំពង់ផែអ្នកដំណើរក្បែរផ្លូវ១០៤ ហើយអ្នកអាច

រកកាណូតទេសចរណ៍ និងការផ្សព្វផ្សាយនៅទីនោះបានផងដែរ។ ចាប់ពីម៉ោងប្រហែលជា ៤-៥:៣០នាទីល្ងាច អ្នកអាចជិះកាណូតទេសចរណ៍គយគន់ព្រះអាទិត្យអស្តង្គត ហើយមានតម្លៃពី ៤-៥ដុល្លារក្នុងម្នាក់ៗ។ ប្រសិនបើអ្នកត្រូវការជួល កាណូតឯកជន តម្លៃអាចមានចាប់ពី ១០-១៥ដុល្លារក្នុងរយៈពេលមួយម៉ោង ដោយផ្តល់ជូននូវសេវាកម្មធ្វើដំណើរតាមលក្ខណៈស្តង់ដារ។ នៅពេលល្ងាច ច្រាំងទន្លេនៅតាម បណ្តោយតិរៈស៊ីសុវត្ថិផ្តល់ជូន សេវាកម្មដំណើរកម្សាន្តចុះឡើង តាមដងទន្លេមេគង្គ ព្រមទាំងមានអាហារពេលល្ងាចសម្រាប់ទទួលទៀតផង ដំណើរកម្សាន្តតាមកាណូតនារាត្រីដ៏ត្រកាលនេះ មិនសូវជាអស់ថ្លៃប៉ុន្មាននោះទេ។

ដោយសារកំណើនទេសចរ នៅក្នុងរាជធានីកើនឡើង ធ្វើឲ្យអ្នកវិនិយោគជាតិនិងអន្តរជាតិ មានការចាប់អារម្មណ៍ខ្លាំង ទៅលើសេវាស្នាក់នៅ ហូបចុក នៅក្នុងរាជធានីភ្នំពេញ។ នាពេលបច្ចុប្បន្នយើងសង្កេតឃើញថា ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋានមានការរីកដុះដាលពាសពេញទីក្រុង ដោយបង្កលក្ខណៈងាយស្រួលដល់ទេសចរដែលមានសម្រាកកម្សាន្តនៅរាជធានី។ សណ្ឋាគារជាច្រើនបាន ពង្រីកខ្លួនឲ្យស្របទៅនឹងតម្រូការទេសចរ ក៏ដូចជា តុបតែង កែលំអ សណ្ឋាគារ ភោជនីយដ្ឋានរបស់ខ្លួនឲ្យកាន់តែគួរជាទីទាក់ទាញ ក្នុងន័យប្រកួតប្រជែងដណ្តើមទីផ្សារ។ ភោជនីយដ្ឋាន សណ្ឋាគារ ថ្មីៗបានកំពុងតែខិតខំពង្រឹងនិងពង្រីកខ្លួនដើម្បីជ្រៀតចូលទីផ្សារផងដែល។

### ២.២.១. រមណីយដ្ឋានសំខាន់ៗរាជធានីភ្នំពេញ

នៅទីក្រុងភ្នំពេញមានរមណីយដ្ឋាន សក្តានុពលទាក់ទាញភ្ញៀវទេសចរមកកម្សាន្តជាច្រើនមួយចំនួនដែលយើងខ្ញុំមិនអាចរៀបរាប់អស់បានទេ។ ខាងក្រោមនេះយើងខ្ញុំសូមលើកយកតែរមណីយដ្ឋានល្បីៗ នៃរាជធានីភ្នំពេញ មកបកស្រាយ ដោយសង្ខេប មានដូចជា ៖ វត្តភ្នំ វិមានឯករាជ្យ ព្រះបរមរាជវាំង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ឬ សារមន្ទីរទួលស្លែង សារមន្ទីរជាតិ វិមានឯករាជ្យ សារៈមន្ទីរជាតិ និងព្រះបរមរាជវាំង។

វត្តភ្នំ គឺជាចំណុចកណ្តាល នៃទីក្រុងភ្នំពេញ ដែលផ្តល់ឈ្មោះដល់ទីក្រុងនេះ។ វត្តភ្នំមានកំពស់ ២៧ម៉ែត្រដែល ត្រូវបានស្ថាបនាឡើងនៅឆ្នាំ១៣៧៣ និងជាសំណង់សាសនាដែលមានកំពស់ខ្ពស់ជាងគេក្នុងទីក្រុងភ្នំពេញ។ រមណីយដ្ឋានវត្តភ្នំមានកេរដំណែល និងស្លាកស្នាមប្រវត្តិសាស្ត្រជាច្រើន ដែលបន្សល់ ទុកតាំងពីការកកើតរាជធានីភ្នំពេញដំបូងក្នុងសតវត្សរ៍ទី១៤មកម្ល៉េះ។ ក្នុងចំណោមនោះ រូបសំណាក ព្រះបាទស៊ីសុវត្ថិ ដែលតម្កល់នៅត្រង់ចង្កេះភ្នំដូនពេញផ្នែកខាងត្បូងក៏ជាកេរតំណែល ប្រវត្តិសាស្ត្រមួយដ៏សំខាន់ផងដែរ ក្នុងសម័យកម្ពុជាស្ថិតនៅក្រោម

រាជការអាណាព្យាបាលបារាំង។ ព្រោះថារូបសំណាកនេះ ជានិមិត្តរូបនៃការថ្វាយបូរណភាពទឹកដី នៃ ខេត្តសៀមរាប បាត់ដំបង និងសិរីសោភ័ណ្ឌ ឲ្យមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះមហាក្សត្រខ្មែរវិញ។ នៅខាងក្រោយវត្តមានចេតីយ បុរាណមួយ ដែលតម្កល់អដ្ឋិធាតុព្រះបាទពញាយ៉ាត (ព្រះរាជាដែលបានយាងចោលទីក្រុងអង្គរក្នុងឆ្នាំ ១៤៣១ នៃគ្រិស្តសករាជ) ។ អ្នកទេសចរទាំងឡាយមិនអាចចាកចេញពីទីកន្លែងនេះ ដោយមិនបានទៅលេងស្តូបរំលឹកអនុស្សាវរីយ៍ ដែលធ្វើឲ្យយើងនឹកឃើញឡើងវិញពីដែនដីទាំងនេះ កាលពីអំឡុងសម័យសង្គ្រាមលោកលើកទីពីរនោះឡើយ ។ ស្តូបរំលឹកអនុស្សាវរីយ៍នេះ មានទីតាំងស្ថិតនៅផ្នែកខាងត្បូងនៃជើងភ្នំ។ កូនភ្នំនេះត្រូវបានគ្របដណ្តប់ និងព័ទ្ធជុំវិញដោយដើមឈើតំបន់ត្រូពិចដែលតំណាងឲ្យវិស័យផ្សេងៗ ដែលបានចាក់ឫសនៅពាសពេញប្រទេស ។ ដើមឈើទាំងនេះបានក្លាយជាទីជម្រកសម្រាប់សត្វស្វា និងបក្សីជាច្រើន ជាពិសេសសត្វជ្រឹងធំៗ ដែលកំពុងតោងមែកឈើទាំងឡាយ។

វិមានឯករាជ្យ (Independence Monument) ត្រូវបានកសាងនៅឆ្នាំ១៩៥៨ ក្នុងរាជ្យព្រះបាទនរោត្តម សុរាម្រិត(១៩៥៥-១៩៦០) ជានិមិត្តរូបបញ្ជាក់ថា កម្ពុជាបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣។ វិមានឯករាជ្យមានទីតាំងស្ថិតនៅផ្លូវប្រសព្វគ្នារវាងមហាវិថីព្រះនរោត្តម និងមហាវិថីព្រះសីហនុ ចំកណ្តាលទីក្រុង ភ្នំពេញ។ វិមានឯករាជ្យមានកំពស់ ២០ម៉ែត្រ មាន ៥ជាន់លំអដោយ ក្បាលពស់នាគរាជចំនួន៩០ សង់តាមគំរូរចនាបថរបស់ទអង្គរ រចនាប្លង់ដោយស្ថាបត្យករខ្មែរដ៏ល្បីល្បាញ គឺ លោក វណ្ណ មូលីវណ្ណ (Vann Molyvann)។ នៅចុងឆ្នាំ២០០៧ សាលាក្រុងភ្នំពេញ បានស្ថាបនាកែលំអរវិមានឯករាជ្យឲមានសំរស់កាន់ តែប្រសើរឡើងថែមមួយកំរិតទៀត គួរជាទីទាក់ទាញ ដែលការកែលំអរនេះចំនាយថវិការអស់ប្រហែល៥០០លានរៀល។

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ឬសារមន្ទីរទួលស្លែង គឺជាសារមន្ទីរមួយនៅទីក្រុងភ្នំពេញ សម្រាប់ចងចាំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ទីនេះជាអតីតមន្ទីរសន្តិសុខ២១ (ហៅកាត់ថា «ស.២១») នៃរបបកម្ពុជាប្រជាធិបតេយ្យ ដឹកនាំដោយប៉ុល-ពត (ឈ្មោះដើម សាឡុតស) ពេលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ មន្ទីរស.២១ ជាកន្លែងឃុំឃាំងសួរចម្លើយធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ និង សម្លាប់ក្រោយពេលបានបំពេញ សំណុំឯកសារសេចក្តីសារភាពចប់សព្វគ្រប់។ ថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ បក្សនិងរដ្ឋបានរៀបចំប្រមូល ផ្តុំវត្ថុតាងដែលមាននៅក្នុងមន្ទីរស២១ ដូចជារូបថត ហ្វីល សំណុំឯកសារសេចក្តីសារភាពជនរងគ្រោះសម្ភារៈធ្វើទារុណកម្ម ខ្នោះកងជើងនិងសាកសពជនរងគ្រោះចំនួន១៤នាក់(ក្នុងនោះមានស្ត្រីចំនួន១នាក់) តាំងជាពិពណ៌ជូនភ្ញៀវជាតិនិងអន្តរជាតិទស្សនា។

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានបើកទ្វារនៅថ្ងៃដែលតុលាការប្រជាជនបដិវត្តន៍កម្ពុជាបើកសវនាការកាត់ទោសមេដឹកនាំ កម្ពុជាប្រជាធិបតេយ្យ ប៉ុល-ពត អៀង-សារី និង ខៀវ-សំផន (នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩)។ អតីតមន្ទីរស២១មានទំហំ៦០០មx៤០០ម មានព្រំប្រទល់ខាងជើងទល់នឹងមហាវិថីព្រះនរោត្តមសីហនុ ខាងត្បូងទល់នឹងមហាវិថីម៉ៅសេទុង ខាងកើតទល់នឹងមហាវិថីព្រះមុនីវង្ស ខាងលិចទល់នឹងផ្លូវលេខ១៦៣ហ៊ុំព័ទ្ធដោយរបងស័ង្កសីពីរជាន់រាយលួសបន្លាយ៉ាងស្អេកស្កះពីលើ។ គ្រឹះស្ថានសិក្សាពីរគឺសាលាបឋមសិក្សាទួលស្លែងនិងវិទ្យាល័យទួលស្វាយព្រៃដែលស្ថិតនៅក្នុងតំបន់នៃកា រហ៊ុំព័ទ្ធតំបន់នោះ ពួកវាបានធ្វើរបងស័ង្កសីមានលក្ខណៈដូចគ្នាហ៊ុំព័ទ្ធគ្រឹះស្ថាន ទាំងពីរនេះមួយជាន់ទៀតដែលមានព្រំប្រទល់របងខាងកើតទល់នឹងផ្លូវលេខ១១៣ ខាងលិចទល់នឹងផ្លូវលេខ១៣១ ខាងជើងទល់នឹងផ្លូវលេខ៣២០ ខាងត្បូងទល់នឹងផ្លូវលេខ៣៥០។ការហ៊ុំព័ទ្ធនេះធ្វើនៅក្រោយពេលបណ្តេញប្រជាជនចេញពីភ្នំពេញឲ្យទៅតំបន់ព្រៃភ្នំ ឬ ជនបទដាច់ស្រយាលរស់នៅជាភាពទាសករប្រៀបដូចជា គុកគ្មានជញ្ជាំង។ អគារទាំង៤នៃវិទ្យាល័យដែលមានបន្ទប់ថ្នាក់រៀនត្រូវបានពួកមន្ទីរស២១ ប្រែក្លាយជាបន្ទប់តូចៗដែលមានប្រវែង២មx០.៨០ម សំរាប់ឃុំឃាំងអ្នកទោសម្នាក់ៗ។ ខាងមុខអគារពាសដោយលួសបន្លាជាក្រឡាចក្រត្រង្គដើម្បីការពារកុំឲ្យ ជនរងគ្រោះធ្វើអត្តឃាតដោយលោតពីលើចុះមកក្រោម។ ដោយឡែកនៅឆ្នាំ១៩៧៧-៧៨ អគារ "ក" បានរៀបចំជាបន្ទប់ទំហំ៦មx៤មមានបង្អួចឃាំងដោយចំរឹងដែកយ៉ាងរឹងមាំ និងពាសដោយកញ្ចក់ការពារ កុំឲ្យសំរែកឈឺចាប់នៃជនរងគ្រោះលឺចេញមកក្រៅនៅពេលធ្វើទារុណកម្មម្តងៗ។ អគារ "ក" សំរាប់ឃុំឃាំងកម្មាភិបាលដែលត្រូវបានចោទប្រកាន់ជា អ្នកប្រឆាំង អង្គការបដិវត្តន៍មានរបបគ្រែដេក ភួយខ្មៅ កន្ទេល។ រឹងកេសដែក និង ប៊ីដុងជ័រសម្រាប់ ជនរងគ្រោះប្រើប្រាស់ក្នុងការន្ទោរបង់។ អគារ "ខ គ និង ឃ" ជាន់ខាងក្រោមខណ្ឌជាបន្ទប់តូចៗសង់ពីឥដ្ឋ ជាន់ទី២បន្ទប់អំពីឈើ ជាន់ទី៣បន្ទប់ឃុំឃាំងរួមគ្នា។

សារមន្ទីរជាតិ ត្រូវបានកសាងនៅថ្ងៃ១៥សីហា១៩១៧ តាមរបៀបស្ថាបត្យកម្មប្រពៃណីខ្មែរ ហើយត្រូវបានសម្ពោធក្នុងឆ្នាំ១៩២០ ដោយព្រះបាទស៊ីសុវត្ថិ ។ សារមន្ទីរជាតិត្រូវបានកសាងឡើងនាសម័យអាណានិគមបារាំងមកលើព្រះរាជាណាចក្រកម្ពុជា(១៨៦៣-១៩៥៣) ដែលមានស្ថាបត្យករ ជនជាតិបារាំងឈ្មោះហ្គកប្រ៉ូសលីយេ (George Groslier) ដែលមានបណ្តោយ៥៤ម៉ែត្រ និង ជម្រៅ៦៦ម៉ែត្រ ហើយសង់លើខឿនដែលមានកម្ពស់២ម៉ែត្រកន្លះ។ ពិធីសម្ពោធបានប្រព្រឹត្តិទៅ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩២០ ក្រោមព្រះរាជាធិបតីភាពរបស់ ព្រះករុណា ព្រះបាទស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជា និង ចំពោះមុខលោក ហាង់រី បូឌ្វាំង អ្នកប្រចាំការជាន់ខ្ពស់

បារាំងនៅកម្ពុជា។កាលពីដំបូងឡើយសារមន្ទីរជាតិនេះមានឈ្មោះថា សារមន្ទីរក្រុងកម្ពុជាធិបតី ហើយដើម្បីលើកកិត្តិយសដល់លោក ទេសាភិបាលបារាំងឈ្មោះ អាល់ប៊ែរ សារូត៍ (Albert Sarraut) ទើបប្តូរឈ្មោះជាសារមន្ទីរអាល់ប៊ែរ សារូត។សព្វថ្ងៃមានការតាំងផ្លាកពីរធ្វើអំពីថ្មកែវមួយជា ភាសាខ្មែរ និងមួយទៀតជាភាសាបារាំងដែលគេចារិកតាំងពីជំនាន់នោះ។ ប្លង់សារមន្ទីរត្រូវបានគូរដោយលោក ហ្គកហ្ស៊្រូសលីយេ (George Groslier) សមូហកម្មនៃក្បាច់ចម្លាក់របស់វិមានសុទ្ធសឹងជាស្នាដៃរបស់វិចិត្រករខ្មែរដែលជា គ្រូ និង ជា សិស្សរបស់សាលានេះដែលមានដូចជារឿងនាងកាកី ឬ រៀមកេរ្តិ៍ជាដើម ( កាលពីសម័យ នោះអាគារនោះជាសារមន្ទីរផងនិង ជាសាលាបណ្តុះបណ្តាលផង) ។ អ្នកទាំងនោះបានតុបតែងក្បាច់ចម្លាក់ដ៏រស់រវើកនៅលើបង្អួចទាំងដប់ពីរ និងទៅលើទ្វារធំទាំងបី ដែលបានគូរផ្ទាំងគំនូរផ្សេងៗតាមរឿងព្រេងនិទានខ្មែរបុរាណតាមសន្លឹកបង្អួចជួរខាងលិច (ពីខាងក្នុង)។ ក្រោយពីថ្ងៃសម្ពោធក្នុងឆ្នាំ១៩២០ សារមន្ទីរក្រុងកម្ពុជាធិបតី ត្រូវបានប្តូរឈ្មោះជា: "សារមន្ទីរអាល់ប៊ែរសារូត៍"។ ហើយនៅឆ្នាំ១៩៥៦ បានប្តូរឈ្មោះជា "សារមន្ទីរ ជាតិនៃកម្ពុជា" ។ លុះមកដល់ឆ្នាំ១៩៧៩ សារមន្ទីរ ត្រូវបានប្តូរឈ្មោះជា : "សារមន្ទីរវត្ថុបុរាណ"។ បន្ទាប់មកក្នុងសម័យលោក ពេជ កែវជា អភិរក្សសារមន្ទីរត្រូវបាន ប្រែឈ្មោះថា "សារមន្ទីរជាតិនៃកម្ពុជា" រហូតដល់សព្វថ្ងៃនេះ។

ព្រះបរមរាជវាំង តាំងនៅតាមបណ្តោយមហាវិថីសុធារស ដែលសាងសង់ឡើងក្នុងរជ្ជកាលព្រះបាទនរោត្តម ក្នុងអំឡុងឆ្នាំ ១៨៦៦[28] ត្រូវបានចាត់ទុកជាតំណាងប្រទេសជាតិទាំងមូល ហើយរាល់សំណង់ប្រាសាទ នៅក្នុងព្រះបរមរាជវាំង ត្រូវបានគេលាបលំអ ដោយពណ៌លឿង តំណាងឲ្យព្រះពុទ្ធសាសនា និងពណ៌ស តំណាងឲ្យព្រហ្មញ្ញសាសនា។ នៅក្នុងបរិវេនរាជវាំងមានៈ

- ប្រាសាទចន្ទ័ឆាយា ជាកន្លែងដែល គេហាត់រាំរបាំព្រះរាជទ្រព្យថ្វាយ ព្រះរាជា និង ព្រះញាត្តិវង្សានុវង្ស និងមន្ត្រីជាន់ខ្ពស់។
- ប្រាសាទទេវាវិនិច្ឆ័យ ជាកន្លែងដែលព្រះមហាក្សត្រឡើងគ្រងរាជ្យ
- ប្រាសាទខេមរិន្ទ ជាកន្លែងដែលព្រះមហាក្សត្រគង់នៅ
- ប្រាសាទសម្រានភិរម្យ ជាកន្លែងដែលព្រះមហាក្សត្រឡើងដំរីរាជ្យ
- ហោរបាគូ ឬ ហោព្រះខ័ណ្ឌ ជាកន្លែងតម្កល់វត្ថុសម្ភារៈគ្រងរាជ្យ

- ព្រះវិហារព្រះកែវមរកត ស្ថិតនៅខាងត្បូងនៃព្រះបរមរាជវាំងកសាងឡើងនៅចន្លោះឆ្នាំ១៨៩២ ដល់ឆ្នាំ១៩០២ តាមលំនាំស្ថាបត្យកម្មខ្មែរធ្វើអំពីឈើប្រក់តដ្ឋលុះដល់ឆ្នាំ១៩៦២

[28] ភូមិវិទ្យាទេសចរណ៍ និងវប្បធម៌ បណ្ឌិត ហុង វណ: ទំ.៤១

ព្រះវិហារត្រូវបានរុះរើនិងសាងសងជាថ្មី ឡើងវិញ ដោយរំកិលទីតាំងហើយក្រាលកម្រាលប្រាក់ជាង ៥០០០សន្លឹក និងសសរបិទដោយថ្មកែវដែលនាំចូលពីប្រទេសអ៊ីតាលី។ ដោយព្រះរាជតម្រិះ ព្រះមហាក្សត្រីយានីកុសមៈនារីរ័ត្នក្រោយព្រះរាជកិច្ចដឹកនាំរបស់ព្រះបរមកោដន៍ សម្តេចព្រះនរោត្តមសីហនុ។ កាលពីមុនវិហារនេះមានឈ្មោះថា ឧបោសថរតនារាមព្រោះព្រះមហាក្សត្រខ្មែរនាពេលនោះ បានប្រារព្ធឧបោសថសីលនៅទៅនោះជារាល់ថ្ងៃសីល ប៉ុន្តែវត្តនេះគ្មានព្រះសង្ឃគង់នៅទេ មានតែព្រះករុណា ព្រះបាទនរោត្តម សីហនុព្រះអង្គបានសាងផ្នួសនៅ ទីនោះអស់រយៈពេលមួយវស្សា គឺចាប់ពីថ្ងៃទីថ្ងៃ១៤កើត ខែទុតិយសោធ ឆ្នាំកុរ នព្វស័ក ព.ស ២៤៩០ ត្រូវនឹងថ្ងៃទី៣១ កក្កដា ១៩៤៧។ នៅពេលណាដែលព្រះរាជាទ្រង់ ប្រារព្ធពិធី បុណ្យផ្សេងៗ តាមផ្សេងៗតាមទំនៀមទម្លាប់ព្រះពុទ្ធសាសនា គឺត្រូវនិមន្តព្រះសង្ឃដែលគង់នៅវត្តដទៃក្នុងរាជធានីភ្នំពេញមកកាន់ទីនេះ ដូចជា វត្តឧណ្ណាលោម វត្តបទុមវត្តីជាដើម។ ព្រះវិហារព្រះកែវមរកតហ៊ុមព័ទ្ធដោយថែវរាងខ្ពស់ រួមជាមួយផ្ទាំងគំនូរបុរាណដែលនិទានពីប្រវត្តិរឿងរាមកេរ្តិ៍តាំងពីដើមដល់ចប់។ គំនូរនេះគូរឡើងនៅក្នុងឆ្នាំ១៩០៣-១៩០៤ក្រោមការដឹកនាំរបស់ឧកញ៉ាទេព និមិត្តឆ្លាក់រួមជាមួយវិចិត្រករខ្មែរ៤០នាក់។ សព្វថ្ងៃរូបគំនូរនេះមានសភាពទ្រុឌទ្រោមនិងរលប់បន្តិចម្តងៗដោយសារពេលវេលា និងអាយុកាល អាកាសធាតុ និងស្នាដៃមនុស្ស។ ទីនេះធ្លាប់ជាកន្លែងព្រះសង្ឃសិក្សាបាលីមុនពេលបង្កើតសាលាបាលីនៅរាជធានីភ្នំពេញថ្ងៃទី ១៦ធ្នូ ១៩៣០។ បច្ចុប្បន្នរាជរដ្ឋាភិបាលកំពុងស្វែងរកមធ្យានាយថែទាំង និងជួសជុល បេតិកភណ្ឌវប្បធម៌នេះឡើងវិញ។

នៅមុខព្រះវិហារមានព្រះចេតិយធំពីរ និងរូបសំណាកព្រះនរោត្តមគង់នៅលើសេះស។ ព្រះចេតិយខាងត្បូងតម្កល់ព្រះអដ្ឋធាតុព្រះបាទអង្គឌួង ដែលត្រូវជាព្រះអយ្យកោលួតរបស់ព្រះករុណាសម្តេចព្រះនរោត្តសីហនុ និងព្រះចេតិយខាងជើងតម្កល់អដ្ឋិធាតុព្រះបាទនរោត្តមដែលត្រូវជាព្រះអយ្យកោរទូត។ ចេតិយទាំងពីរកសាងឡើងនៅថ្ងៃសុក្រ ១១កើត ឆ្នាំ មមែ នព្វស័ក ពស. ២៥៥០ ត្រូវនឹងថ្ងៃទី ១១ មិនា ១៩៦០ ។ចំណែករូបសំណាក់ព្រះបាទនរោត្ត គង់លើសេះសជាអំណោយរបស់ព្រះចៅណាប៉ូឡេអុងទី៣ ជាតិបារាំងកសាងឡើង នៅឆ្នាំ ១៩៧៥ ទុកជាអំណោយអនុស្សាវរីយ៍ ដោយតម្កល់ទុកមុខព្រះវិហារនៅឆ្នាំ ១៨៩២។ លុះក្រោយមកនៅឆ្នាំ១៩៥៣ ក្នុង ពេលដែលព្រះ ប្រមុខរដ្ឋរៀបចំបូនីយកិច្ចទាមទារ ឯករាជ្យពីអាណានិគមនិយមបារាំងទ្រង់បានបួងសួងសុំពរជ័យ ចំពោះមុខព្រះបរមរូបនេះ។ បន្ទាប់ពីទទួលបានឯករាជ្យនៅថ្ងៃទី ០៩ វិច្ឆិការ ១៩៥៣ មកទ្រង់ក៏បានចាត់ឲ្យគេសាងសង់ដំបូលប្រក់ពីលើព្រះបរមរូបនេះដើម្បីជាកិច្ច តបស្នងសងគុណ ចំពោះបារមីព្រះបាទសម្តេចព្រះនរោត្តម។

ព្រះវិហារព្រះកែវមរកត មានព្រះពុទ្ធរូបមួយអង្គដែលធ្វើពីត្បូងពណ៌ហ្គិចដ៏មានតម្លៃ ដែលគេសន្មត់ហៅ ថាកែវមរកត។ ជនជាតិអឺរ៉ុបតែងតែនិយមហៅព្រះវិហារនេះថា ព្រះវិហារប្រាក់

ព្រះសម្អាងទៅលើកម្រាលប្រាក់ដែលក្រាលក្នុងព្រះវិហារទាំងអស់ជាង ៥,០០០សន្លឹក ដែលមួយសន្លឹកទំងន់ប្រហែល ១,១២៥ គីឡូក្រាម។ ចំពោះវត្ថុសិល្បៈដែលកគេតាំងនៅក្នុងព្រះវិហារមានចំនួន ១៦៥០ ជ ភាគច្រើនជាព្រះពុទ្ធរូប ដែលសុទ្ធសឹងធ្វើអំពីវត្ថុមានតម្លៃ ដូចជាមាស ប្រាក់ ទង្ហា សម្រិត លង្ហិណព្រមទាំងត្បូងពេជ្រផង។

### ២.២.២. ទីផ្សារទេចរណ៍រាជធានី

ទីផ្សារទេចរណ៍ប្រែប្រួល និងទទួលរងឥទ្ធិពលពីកត្តា សង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ទីផ្សារទេសចរណ៍ត្រូវបានកំណត់ជាទីផ្សារអាទិភាព ទីផ្សារចម្រុះ និងទីផ្សារកំពុងរះឡើងដោយឈរ លើមូលដ្ឋាននៃការកំណត់ប្រាំយ៉ាងគឺៈ ចំនួនប្រជាជន ចំណែកទីផ្សារ អាត្រាប្រជាជនចេញទេសចរណ៍ក្រៅប្រទេស ស្ថានភាពសេដ្ឋកិច្ច សង្គម និងតម្រូវការទីផ្សារ[29]។

យោងតាមរបាយការណ៍សិត្ថិក្រសួងទេសចរណ៍ ខែឧសភាឆ្នាំ២០១៧ ទេសចរអន្តរជាតិមកដល់រាជធានីភ្នំពេញមានចំនួនសរុប ១,១៩១,៩៩៤ លាននាក់ បើធៀបទៅនឹងឆ្នាំ២០១៦មានចំនួន ១,០៥៥,១១៩មានការកើនឡើង ១៣.០% [30] និងមានប្រទេស១០ដែលស្ថិតនៅក្នុងតារាងទេសចរណ៍អន្តរជាតិ មកដល់កម្ពុជាច្រើនជាងគេ ។ខាងក្រោមនេះគឺជាតារាងបង្ហាញ




| | China (RPC) | Vietnam | Lao PDR | Korea (ROK) | Thailand | U.S.A | Japan | U.K | France | Malaysia |
|---|---|---|---|---|---|---|---|---|---|---|
| 2017 | 441,070 | 332,295 | 183,621 | 169,737 | 146,476 | 113,971 | 85,571 | 78,539 | 75,030 | 63,684 |
| 2016 | 325,206 | 382,611 | 98,849 | 171,442 | 144,579 | 107,981 | 80,389 | 73,583 | 67,646 | 57,549 |
| Share (%) | 19.3 | 14.5 | 8.0 | 7.4 | 6.4 | 5.0 | 3.7 | 3.4 | 3.3 | 2.8 |
| Change (%) | 35.6 | -13.2 | 85.8 | -1.0 | 1.3 | 5.5 | 6.4 | 6.7 | 10.9 | 10.7 |

ដោយផ្អែកទៅលើទិន្នន័យខាងលើ ឃើញថា ទីផ្សារជាអទិភាពរបស់រាជធានីភ្នំពេញ គឺប្រទេសចិន ថៃ និងអាមេរិក ព្រោះប្រទេសទាំងបីនេះកំណើនទេសចរដែលចូលមកក្នុងព្រះរាជណាចក្រកម្ពុជាមានការកើនឡើងខ្ពស់ជាងគេ ។កម្ពុជាត្រៀមទទួលភ្ញៀវចិន ប្រមាណ ២លាននាក់ នៅឆ្នាំ ២០២០។ អង្គការ WTO បានមើលឃើញថា លើពិភពលោកនេះចិនគឺជាភ្ញៀវ

[29] ផែនយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ ២០១២- ២០២០ ទំ.២៩

[30] Tourism statistic report May 2017

ទេសចរដើរលេងច្រើនជាងគេបង្អស់។ ឆ្នាំ២០១៦ ចិនដើរលេងលើពិភពលោកមាន ១៣៥ លាននាក់ ហើយភ្ញៀវចិនបានចាយលុយជាង ២៦១ ពាន់លានដុល្លារ[30] ។

ការសិក្សាខាងលើបាន បង្ហាញកាន់តែច្បាស់ថា ទីផ្សារទេសចរណ៍រាជធានីមានការកើនឡើងខ្លាំង នៅកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ពិសេសតាមរបាយការណ៍ខាងលើអាចកំណត់បានប្រភពទេចរ ដែលនឹងធ្វើដំណើរមកទស្សនារាជធានី ដើម្បីដាក់ចេញនូវផែនការ យុទ្ធសាស្ត្រច្បាស់លាស់ក្នុងការទាក់ទាញទេសចរឲ្យមកទស្សនាក្រុងភ្នំពេញក៏ដូចជាតំបន់ជុំវិញកាន់តែច្រើន។

វិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមាសបៃតង និងជាការនាំចេញ នៅនឹងកន្លែងដែលបានចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការបង្កើត ប្រាក់ចំនូលជូនជាតិ បង្កើតការងារ ជុំរុញការវិនិយោគ និងចូលរួមកាត់បន្ថយ ភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ២.៣. ស្ថានភាពទូទៅរមណីយដ្ឋានកោះដាច់

តាមការស្រាវជ្រាវបានបង្ហាញ ឲ្យដឹងថារមណីយដ្ឋានកោះដាច់បានក្លាយជាកន្លែងកម្សាន្តតាំងពីឆ្នាំ ១៩៩៣ ប៉ុន្តែបានផ្ទេរសិទ្ធិវិនិយោគទៅឲ្យអ្នកស្រី ង៉ែត នីន ធ្វើជាម្ចាស់គ្រប់គ្រងនៅឆ្នាំ ២០០៦ ។[31]សង្កាត់កោះដាច់ពីដើមគឺស្ថិតនៅក្នុងដែនដីរដ្ឋបាលស្រុកមុខកំពូល ខេត្តកណ្តាល រហូតដល់ចុងឆ្នាំ២០១០ សង្កាត់នេះត្រូវបានកាត់ចូលក្រោមការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញដែលស្ថិតនៅខណ្ឌជ្រោយចង្វារ។[32]

សង្កាត់កោះដាច់ គឺជាដែនដីកោះដែលហ៊ុមព័ទ្ធដោយទន្លេមេគង្គ ដែលមានផ្ទៃដីសរុប ២.៣០១,៦៩ហិកតា ចែកចេញជា ៥ ភូមិ មាន ភូមិរនះ ភូមិកោះដាច់ ភូមិក្បាលកោះ ភូមិល្វា និងភូមិចុងកោះ មានប្រជាពលរដ្ឋរស់នៅ ១០.៣៩៨នាក់ ស្មើនឹង ៣.០៥០គ្រួសារ ។ប្រជាពលរដ្ឋរស់នៅកោះនេះប្រកបរបរកសិកម្ម ដាំពោត សណ្តែក បន្លែគ្រប់មុខ ធ្វើស្រែប្រាំង ត្បាញ ក្រមា ហូល ផាមួង ហើយប្រជាជនប្រមាណជា៤០%បានចាប់យកការត្បាញ ហូល ផាមួង សុឺង ជាមុខរបរចិញ្ចឹមជីវិត។ សង្កាត់កោះដាច់មានប្រព័ន្ធផ្លូវតូច-ធំ សរុបមានប្រវែង៣៩.៩៥០ម៉ែត្រ មានស្ពាន៥កន្លែង ប្រវែង១៥៧ម៉ែត្រ [33]។

រមណីយដ្ឋានកោះដាច់មានទីតាំងនៅក្នុងភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដែលត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៦អា មានចំងាយប្រហែលជាង១២គីឡូម៉ែត្រពីរង្វង់មូលជ្រោយចង្វារ និងត្រូវឆ្លងតាមកំពង់ចម្លងវត្តក្តីចាស់។ នៅពេលចុះពីកំពង់ចម្លងទៅត្រង់ចំងាយប្រហែល២គីឡូម៉ែត្រនឹងឃើញមានផ្លាកសញ្ញា រមណីយដ្ឋានទេសចរណ៍ឆ្នេរខ្សាច់កោះដាច់ នៅខាងស្តាំដៃ។ ចំពោះភ្ញៀវទេសចរចូលទៅទស្សនាតំបន់រមណីយដ្ឋានកោះដាច់នេះត្រូវ

[31] http://www.khmer24nano.ga/2016/07/dach-is-beautiful-tourist-area-filled.html?m=1
[32] http://kampucheathmey.com/kpt/?p=177665
[33] សាលាសង្កាត់កោះដាច់ ឯកសាររដ្ឋបាលសង្កាត់កោះដាច់ ថ្ងៃទី ២៨ ឧសភា ២០១៧

បង់ថ្លៃម៉ូតូមួយគ្រឿងចំនួន២ពាន់រៀល ចំពោះភ្ញៀវជាតិ និង៤ពាន់រៀលសម្រាប់រថយន្តទេសចរមួយគ្រឿង និងតម្លៃធ្វើយានជំនិះមួយពាន់រៀល។ សម្រាប់តម្លៃកំពង់ចម្លងវិញគឺ កង់១គ្រឿង ២០០រៀល ម៉ូតូ១គ្រឿង៥០០រៀល រថយន្តធុនតូច១គ្រឿង៦.០០០រៀល រថយន្តធុនមធ្យម១គ្រឿង ១០.០០០រៀល និងមនុស្សឆ្លង១នាក់៥០០រៀល។

យ៉ាងណាមិញ តំបន់កោះដាច់ ត្រូវបានរដ្ឋាភិបាលលើកយកមក គិតគូរផងដែរ ដោយសាលារាជធានីភ្នំពេញដែលដឹកនាំដោយ ឯកឧត្តម ប៉ា សុជាតិវង្ស បានលើកឡើង នៅឆ្នាំ២០១៧ ថ្ងៃទី១ ឧសភា អាជ្ញាធររាជធានីដែលនឹងធ្វើការកែលម្អរមណីយដ្ឋានទេសចរណ៍កោះដាច់ឲ្យក្លាយជាតំបន់ទាក់ទាញ និងមានបរិស្ថានល្អ ស្របពេលដែលរមណីយដ្ឋានទេសចរណ៍កោះដាច់មានអំណោយផលល្អពីធម្មជាតិ ប៉ុន្តែយ៉ាងណាក៏ត្រូវមានការកែសម្រួលសោភណ័ភាពឲ្យកាន់តែប្រសើរឡើង ដោយត្រូវរៀបចំទុកដាក់សម្រាមឲ្យបានល្អ ព្រមទាំងរៀបចំគ្រែអង្គុយ ខ្ទសក៏ត្រូវតែរៀបចំកែសម្រួលឲ្យបានស្អាត ដើម្បីទាក់ទាញភ្ញៀវទេសចរឲ្យកាន់តែកើនឡើង លើសពីនេះតាមប្រសាសន៍របស់លោក បានបង្ហើបថា នៅក្នុងតំបន់នេះអាចនឹងមានធ្វើជាផ្ទះសំណាក់ដោយបំពាក់ដោយម៉ាស៊ីនត្រជាក់ទៀតផង [34]។

លើសពីនេះ ឯកឧត្តម ប៉ា សុជាតិវង្សបានបញ្ជាក់ថា អាជ្ញាធររាជធានីភ្នំពេញក៏មានគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេដោយតភ្ជាប់ពីជ្រោយចង្វារមកកោះដាច់ ពីកោះដាច់ទៅអរិយក្សត្រនិងពីអរិយក្សត្រទៅ ផ្លូវជាតិលេខ១ដើម្បីសម្រួលដល់ចរាចរណ៍របស់ បងប្អូនប្រជាពលរដ្ឋ យ៉ាងណាមិញគម្រោងសាងសង់នេះកាន់តែផ្តល់អទិភាពដល់ទេសចរដែលមានបំណងទៅទស្សនាតំបន់ទេសចរកោះដាច់ គួរបញ្ជាក់ផងដែលគម្រោងនេះគឺ កំពុងស្ថិតនៅក្រោមការសិក្សា និងរកប្រភពថវិកានៅឡើយទេ[35] ។

### ២.៣.១. សក្តានុពលរមណីយដ្ឋានកោះដាច់

រមណីយដ្ឋានកោះដាច់មានសក្តានុពលទេសចរណ៍បែបធម្មជាតិសុទ្ធសាធ មិនចាញ់រមណីយដ្ឋានកែច្នៃនៅតាមតំបន់ ផ្សេងៗទៀតនោះទេ ។ រមណីយដ្ឋានកោះដាច់ ជាតំបន់មួយដែលមានសក្តានុពលទាក់ទាញទាំងទេសចរជាតិ និងអន្តរជាតិឲ្យចូលមកសម្រាកលំហែ និងហែលទឹកលេងកម្សាន្ត ដោយសារតែវាមានទីតាំងនៅក្នុងរាជធានីដែលមិនចាំបាច់ចំនាយពេលយូរក្នុងការធ្វើដំណើរនោះទេ។ ជាទូទៅ រមណីយដ្ឋានមួយនេះ បើកឲ្យភ្ញៀវជាតិ អន្តរជាតិចូលលំហែកំសាន្តក្នុងរដូវប្រាំងរយៈពេល៦-៧ខែ ចំណែក ៥-៦ខែ ក្នុងរដូវវស្សាវិញទឹកឡើងច្រើនមិនអាចទៅលេង នៅតាមឆ្នេរខ្សាច់បាននោះទេប៉ុន្តែទេសចរនៅតែអាចទៅកម្សាន្ត និងអង្គុយស្រស់ស្រូបអាហារ នៅក្បែរមាត់ទឹកដដែលដោយសារតែក្រុមអាជីវករបានរំកិលខ្ទសឲ្យមកនៅលើច្រាំងវិញ។

[34] កម្ពុជាថ្មី ថ្ងៃទី២ខែ៥ឆ្នាំ២០១៧

[35] Post news ថ្ងៃទី២ ឧសភា ២០១៧

បើមើលពីចំងាយកោះដាច់មានសម្រស់គួរឲ្យចង់គយគន់ ព្រោះថាមានឆ្នេរទន្លេមេគង្គ មានទឹកពណ៌ថ្លៃមេឃ និងអាចឲ្យភ្ញៀវទេសចរឆ្លងទឹកទៅលេងយ៉ាងសប្បាយរីករាយ កោះដាច់គឺជាតំបន់កម្សាន្តមួយ ដ៏ទាក់ទាញបំផុត សំរាប់ប្រជាពលរដ្ឋខ្មែរនិង បរទេស ដោយសារតែ តំបន់ទេសចរណ៍មួយនេះ សំបូរទៅដោយ ខ្យល់ត្រជាក់បរិសុទ្ធ ឆ្នេរខ្សាច់ និង កន្លែងសំរាកកម្សាន្តជាជួរតាមមាត់ទឹក ដ៏ស្រស់បំព្រង ទេសចរ ចូលចិត្តទៅកម្សាន្តនៅតំបន់នេះមានភាពរីករាយជាមួយនឹងការហែលទឹក ទទួលទានអាហារជុំគ្នា ស្ងួចត្រី និង ជិះទូកគយគន់ទេសភាព ជាដើម។ ដោយសារតែទេសភាពតំបន់ឆ្នេរកោះដាច់ពោរពេញទៅដោយបរិយាកាសគួរឲ្យគយគន់ និងថែមទាំងជាកន្លែងហែលទឹកកម្សាន្តមិនចេះ ជិនណាយបែបនេះហើយ រួមជាមួយនឹងម្ហូបប្រចាំតំបន់ដ៏ឆ្ងាញ់ពិសារទៀតផងនោះទើបធ្វើឲ្យទេសចរមកកម្សាន្តស្ទើរគ្រប់រដូវ ទោះជារដូវទឹកឡើងក៏ដោយ ជាពិសេសពេលសម្រាកពីការងារនិង រដូវបុណ្យទានសំខាន់ៗគឺតែងតែមានមនុស្សម្នាច្រើនកុះករមកលេង ដែលធ្វើឲ្យរមណីយដ្ឋានធម្មជាតិមួយនេះបន្ថែមចំនួនខ្ទូសរហូតដល់មានជាង១.០០០ខ្ទូសក្នុងពេលបច្ចុប្បន្ននេះ។

ក្រៅពីនេះ ទេសចរក៏អាចធ្វើដំណើរទៅទស្សនាការតម្បាញរបស់ប្រជាពលរដ្ឋនៅតាមភូមិផងដែរ ដើម្បីឲ្យពួកគាត់បានស្គាល់ពីឧបករណ៍ និងវិធីតម្បាញរបស់ប្រជាពលរដ្ឋ លើសពីនោះទៅទៀត ទេសចរក៏អាចជាវនូវផលិតផលតម្បាញទាំងនោះពីបងប្អូននៅក្នុងសហគមន៍ផ្ទាល់។

យើងខ្ញុំសង្កេតឃើញថា នៅក្នុងសង្កាត់កោះដាច់ មាន វត្តដល់ទៅប្រាំមាន វត្តឥន្ទពិសី វត្តអម្ពផល វត្តសាមគ្គីក្បាលកោះ វត្តក្រពុំពេជ្រ(វត្តកោះដាច់) និង វត្តចុងកោះ ហេតុនេះហើយទើបធ្វើឲ្យតំបន់ទេសចរណ៍មួយនេះកាន់តែមានភាពទាក់ទាញដល់ទេសចរជាតិ និងអន្តរជាតិ បានចូលមកទស្សនា ចំលាក់ និងសិក្សាស្វែងយល់ពីព្រះពុទ្ធសាសនា រចនាបថរបស់វត្តខ្មែរបន្ថែមទៀត។

បន្ថែមពីនេះទៀត ទេសចរដែលមកកម្សាន្តនៅរមណីដ្ឋានកោះដាច់ក៏អាចធ្វើដំណើរកម្សាន្តបន្តនៅ កោះឧកញ៉ាតី ដែលមានទីតាំងនៅក្បែររមណីយដ្ឋានកោះដាច់ ហើយនៅទីនោះគេអាចឲ្យភ្ញៀវចូលទស្សនាការចិញ្ចឹមដង្កូវនាងដើម្បីធ្វើសូត្រ និងការជិះទាទឹកកម្សាន្តផងដែរ។

ចំការបន្លែនៅតាមផ្ទះរបស់ប្រជាពលរដ្ឋក៏បានក្លាយជាទីចំណាប់អារម្មណ៍របស់ទេសចរដែរ ដោយសារតែទេសចរអន្តរជាតិជា ច្រើនចង់ដឹងពីការដាំដុះបន្លែធម្មជាតិរបស់ប្រជាកសិករខ្មែរយើង ចំណែកទេសចរជាតិវិញ ពួកគាត់ក៏មានចំណាប់អារម្មណ៍ចង់ទិញបន្លែ ផ្លែឈើធម្មជាតិពីកសិករផ្ទាល់ទៅបរិភោគដែរដើម្បីសុខភាពរបស់ពួកគាត់។

ចំណុចពិសេសមួយទៀតដែលអាចេះ ទាក់ទាញទាំងទេសចរជាតិ និងអន្តរជាតិនោះគឺ សាលាដូងដែលត្រូវបានបង្កើតឡើងដោយលោក អ៊ុក វណ្ណដេ សាលារៀនមួយនេះបានបង្កើតឡើងពីការកែច្នៃរបស់ដែលគេបោះចោល ទិដ្ឋភាពរបស់សាលារៀនមួយនេះគឺ ជញ្ជាំងរបស់វាត្រូវបានតុបតែងដោយសម្បកកង់ឡានចាស់ៗ ជាមួយនឹងថ្នាំពណ៌ចំរុះគួរឲ្យទាក់ទាញ ពែងកាហ្វេចាស់ៗដែលប្រើរួច ត្រូវបានគេយកមកតម្រៀបធ្វើជាដំបូល ដ៏ស្រស់ស្អាតមួយ នៅពីលើក្លោងទ្វារចូលរបស់សាលា រីឯដបប្លាស្ទិចដែលគេលាបពណ៌ចំរុះ ត្រូវបានកាត់ចេញជាក្រាហ្វិករាងផ្កាធំៗ

និងតម្រៀបចេញជាក្រាហ្វិករាងទង់ជាតិរបស់កម្ពុជា ដ៏អស្ចារ្យបំផុត មើលទៅពិតជាគួរឲ្យទាក់ភ្នែក សាលារៀននេះក៏បានផ្តល់ ចំណេះដឹងដោយមិនគិតប្រាក់កម្រៃពីសិស្សឡើយ។កាលពីសាលាដំបូង ទើបតែបង្កើតដំបូងបានជួយ ទាក់ទាញទេសចរជាតិឲ្យបានស្គាល់តំបន់កោះដាច់យ៉ាងច្រើនគួរឲ្យកត់សម្គាល់ផងដែរ។

### ២.៣.២. ទីផ្សារទេសចរណ៍រមណីយដ្ឋានកោះដាច់

យើងសង្កេតឃើញថា រមណីយដ្ឋានកោះដាច់បានទាក់ទាញទេសចរឲ្យមកកម្សាន្តជាហូរហែរ ជាពិសេសនៅថ្ងៃឈប់សម្រាក និងចុងសប្តាហ៍ ភ្ញៀវជាតិ និងអន្តរជាតិបានមកកម្សាន្តនៅរមណីយដ្ឋានដែលពោរពេញទៅដោយ សម្រស់ធម្មជាតិមួយនេះយ៉ាងច្រើនកុះករគួរឲ្យកត់សម្គាល់។

យោងតាមលោក ឃ្លាំង ហួត អភិបាលខណ្ឌជ្រោយចង្វារ បានបញ្ជាក់ឲ្យដឹងដែរថា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ២០១៧ នេះតំបន់ទេសចរណ៍កោះដាច់ទទួលបានភ្ញៀវទេសចរជាតិ និងអន្តរជាតិ បានដល់ទៅប្រមាណជាង ១៥.០០០ នាក់ [36]។

យោងទៅតាមការសម្ភាសន៍ផ្ទាល់ ជាមួយទេសចរក្រុមយើងខ្ញុំក៏បានប្រមូលបានពត៌មានសំខាន់ៗមួយចំនួនដូចខាងក្រោម

ក្រាហ្វិកលេខ១ ភេទរបស់ទេសចរដែលមកកម្សាន្តនៅរម្មណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់




[36] https://www.cpp.org.kh ចូលទស្សនា ថ្ងៃទី១៥ មិថុនា ឆ្នាំ២០១៧ ម៉ោង ៨៖១០នាទី

តាមការស្រាវជ្រាវបានបង្ហាញឲ្យឃើញថាទេសចរដែលមកកម្សាន្ត នៅរមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់គឺទាំងភេទប្រុស និង ភេទស្រីគឺមានចំនួនប្រហាក់ប្រហែលគ្នា ដែលអាចឲ្យយើងដឹងបានថាកោះដាច់មានសក្តានុពលទាក់ទាញទេសចរទាំងពីរភេទតែម្តង។

ក្រាហ្វិកលេខ២ អាយុរបស់ទេសចរដែលមកកម្សាន្តនៅរម្មណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់




បើសង្កេតពីវ័យរបស់ទេសចរវិញឃើញថា ទេសចរដែលមកកម្សាន្តច្រើនជាងគេគឺចន្លោះពី២០ដល់៤០ឆ្នាំ ដូចបានបង្ហាញក្នុងក្រាហ្វិកខាងលើនេះ។

ក្រាហ្វិកលេខ៣ ប្រភេទទីផ្សារទេសចរដែលមកកម្សាន្តនៅរម្មណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់



តាមរយៈក្រាហ្វិកខាងលើយើងឃើញថា ទេសចរដែលជាបុគ្គលិកក្រុមហ៊ុនបានមកកម្សាន្តច្រើនជាងគេ បន្ទាប់មកទៀតគឺក្រុមអាជីវករដែលមានចំនួនច្រើនបន្ទាប់។ ដែលបានន័យថាបុគ្គលិកក្រុមហ៊ុនគឺទទួលបានពត៌មានពីរមណីយដ្ឋានតាមការណែនាំមិត្តភក្តិរបស់គាត់។

ក្រាហ្វិកលេខ៤ ចំនួនដងរបស់ទេសចរដែលទៅកម្សាន្តនៅរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់




បើយើងសង្កេតទៅលើចំនួនដងរបស់ទេសចរដែលមកកម្សាន្តវិញ យើងអាចដឹងបានថាទេសចរដែលមកកម្សាន្តជាលើកទីពីរគឺមានចំនួនច្រើនជាងគេ បន្ទាប់មកទៀតគឺទេសចរដែលមកកម្សាន្តជាលើកទីបី។ នេះក៏បានន័យថាតំបន់រមណីយដ្ឋានកោះដាច់នៅខ្វះភាពទាក់ទាញក្នុងការដែលអាចឲ្យទេសចរមកកម្សាន្តលើសពីបីដង។

ក្រាហ្វិកលេខ៥ គោលបំណងរបស់ទេសចរដែលមកកម្សាន្តនៅរម្មណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់



ក្នុងការស្រាវជ្រាវក៏បានបង្ហាញថា គោលបំណងរបស់ទេសចរដែលមកកម្សាន្តនៅទីនេះភាគច្រើនគឺដើម្បីជួបជុំមិត្តភក្តិ គ្រួសារ និងលំហែកម្សាន្ត។ នេះបង្ហាញថាតំបន់ទេចរណ៍មួយនេះគឺមានភាពទាក់ទាញសម្រាប់ជួបជុំគ្នា និងការលំហែកម្សាន្ត។

ជារួមយើងខ្ញុំសង្កេតឃើញថារមណីយដ្ឋានកោះដាច់ទទួលបានចំណាប់អារម្មណ៍ពីទេសចរទាំងពីរភេទប្រហាក់ប្រហែលគ្នា ជាពិសេសគឺទេសចរដែលមានវ័យចន្លោះពី២០ទៅ៤០ឆ្នាំ ដែលមានទាំងបុគ្គលិកក្រុមហ៊ុន អាជីវករ សិស្សនិស្សិត និងមន្ត្រីរាជការផងដែរ។ បន្ថែមពីនេះទៅទៀតពួកគាត់គឺសុទ្ធតែមកកម្សាន្តជាលើកទីពីរ និងទីបីទៅហើយ ដែលភាគច្រើនក្នុងគោលបំណងលំហែកម្សាន្ត និងជួបជុំមិត្តភក្តិ គ្រួសារ។

**២.៣.៣. បញ្ហាប្រឈម**

យើងបានសង្កេតឃើញថាតំបន់រមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់ ជាតំបន់ទេសចរណ៍ធម្មជាតិមួយដែលបានទទួលការអភិវឌ្ឍន៍ និងបានកែប្រែមុខមាត់ទាក់ទាញទេសចរបានយ៉ាងច្រើនគួរឲ្យកត់សំគាល់ក៏ប៉ុន្តែទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមមួយចំនួនចោទឡើងផងដែរ។ ថ្វីត្បិតតែរមណីយដ្ឋានធម្មជាតិដ៏មានសក្តានុពលមួយនេះ កំពុងទទួលបានកំនើនទេសចរយ៉ាងគួរឲ្យភ្ញាក់ផ្អើលព្រមជាមួយនឹងការដាក់ចេញនូវផែនការអភិវឌ្ឍទេសចរណ៍របស់ ក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ភ្នំពេញយ៉ាងណាក្តីក៏ យើងនៅតែមើលឃើញពីភាពខ្វះខាតចន្លោះប្រហោងនិងបញ្ហាប្រឈមមួយចំនួនដែលបានកើតឡើងក្នុងពេលបច្ចុប្បន្ននេះដូចខាងក្រោមៈ

ហេដ្ឋារចនាសម្ព័ន្ធ តាមភាពជាក់ស្តែងយើងមើលឃើញថាផ្លូវចូលទៅកាន់រម្មណីយដ្ឋាននៅមានទំហំតូចដែលធ្វើឲ្យមានការពិបាកបន្តិចបន្តួចសំរាប់រថយន្តពីរជៀសគ្នា ហើយផ្លូវទៀតសោតក៏មានសភាពហុយនៅរដូវប្រាំងដោយសារ តែវាជាផ្លូវលំដីក្រហមដែលបង្កឲ្យមានបញ្ហាខ្លះៗសំរាប់អ្នកធ្វើដំណើរតាមម៉ូតូ។ ប៉ុន្តែនៅពេលឈានចូលដល់រដូវវស្សាវិញផ្លូវមួយខ្សែដដែលនេះមានភាពរអិលខ្លាំង ពោរពេញទៅដោយភក់ជ្រាំដែលធ្វើឲ្យអ្នកធ្វើរដំណើរតាមម៉ូតូសឹងតែធ្វើដំណើរមិនបាន។

សេវាបង្គន់អនាម័យ ក៏បានចោទជាបញ្ហាចំបងផងដែរដោយសារការរៀបចំបន្ទប់ទឹកពុំសូវមានអនាម័យល្អនៅឡើយដែលធ្វើឲ្យទេសចរពិបាកនឹងប្រើប្រាស់។ បន្ទប់ទឹកនៅរម្មណីយដ្ឋានផ្ទាល់ចែកជាពីរផ្នែកគឺផ្នែកខាងលើនិងខាងក្រោម។ បន្ទប់ទឹកនៅផ្នែកខាងលើមានប្រព័ន្ធបង្ហូរកាកសំណល់ប៉ុន្តែគ្មានអនាម័យនិងមានក្លិនមិនល្អ។ ឯបន្ទប់ទឹកនៅផ្នែកខាងក្រោមគឺពុំមានប្រព័ន្ធបង្ហូរនោះទេគឺមានត្រឹមតែបន្ទះក្តារជាប់នឹង ខ្សាច់តែម្តងដែលបន្ទប់ទឹកនេះគេដាក់ឲ្យប្រើប្រាស់តែរដូវប្រាំងប៉ុណ្ណោះ ហើយកត្តានេះបានជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថានតំបន់ផងដែរ បញ្ហានេះអាចនឹងធ្វើឲ្យមានក្លិនមិនល្អនៅពេលណាមួយ។

បញ្ហាបរិស្ថានក៏បានចោទជាបញ្ហាផងដែរនៅតំបន់រមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់ តាមការសង្កេតឃើញជាក់ស្តែងនៅតាមឆ្នេរខ្សាច់ចុះទៅកាន់ខ្ទះអង្គុយលេងបានរងការយាយីពីសំរាមច្រើនប្រភេទដូចជា សំបកកំប៉ុង ដបស្រាបៀរថង់ផ្លាសស្ទិច សំនល់ក្រដាស ជាពិសេសនោះគឺសំបក

លៀសទាំងនៅលើខ្សាច់ និងកប់ក្នុងខ្សាច់ ដែលមានពេលខ្លះអាចធ្វើឲ្យសំរាមហូរចូលក្នុងទឹកទន្លេទៀតផង បញ្ហានេះទៀតសោតក៏ជាចំនោទបញ្ហាដែលរាំងស្ទះនិងធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍តំបន់ផងដែរ។ លើសពីនេះទៅទៀតបញ្ហាមួយនេះធ្វើឲ្យប៉ះពាល់ដល់សុខភាព និងអារម្មណ៍របស់ទេសចរនិង ប្រជាពលរដ្ឋមិនតិចនោះទេដោយសារតែវាបានបំផ្លាញសោភណ្ឌភាពតំបន់ទេសចរណ៍ផងដែរ។

ការចូលរួមពីអ្នកពាក់ព័ន្ធ ក៏ដូចជាទេសចរផ្ទាល់ដើម្បីអភិវឌ្ឍន៍រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់ដោយសារតំបន់រមណីយដ្ឋានកំពុងត្រូវបានរងគ្រោះដោយសំរាម ដែលចំនុចនេះទាមទារឲ្យមានការចូលរួមពីទេសចរ ផ្ទាល់ដោយពួកគាត់ត្រូវរក្សារបៀបរៀបរយក្នុងការចោលកាកសំណល់ផ្សេងៗ។

ម៉្យាងវិញទៀត បញ្ហាម្ហូបអាហារក៏កំពុងតែចោទជាបញ្ហាដល់រមណីយដ្ឋានធម្មជាតិមួយនេះផងដែរ ដោយសារតែមុខម្ហូបនៅរមណីយដ្ឋានកោះដាច់មានតែម្ហូបដដែលៗគ្មានការបន្ថែមថ្មីគួរឲ្យទាក់ទាញអាចធ្វើឲ្យភ្ញៀវដែលមកកម្សាន្តជាច្រើនធុញទ្រាន់ និងមិនអាចមកកម្សាន្តញឹកញាប់បាន។ ម៉្យាងវិញទៀតតម្លៃនៃម្ហូបប្រចាំរមណីយដ្ឋានដែលភ្ញៀវទិញក៏ខុសគ្នាផងដែរ ភ្ញៀវខ្លះយល់ថាមានតម្លៃថ្លៃ តែភ្ញៀវខ្លះទៀតយល់ថាមានតម្លៃសមរម្យ នោះក៏ដោយសារតែអាជីវករខ្លះបានកំណត់តម្លៃថ្លៃហើយនៅពេលដែលភ្ញៀវខ្លះ ចេះតថ្លៃគាត់ក៏ទទួលបានតម្លៃសមរម្យជាងភ្ញៀវដែលមិនចេះតថ្លៃ។ ដូចនេះអាជីវករគួរតែអភិវឌ្ឍន៍ មុខម្ហូបឲ្យមានភាពសម្បូរបែបជាងសព្វថ្ងៃដោយអ្នកភូមិគួរតែទទួលការបង្រៀនពីរបៀបធ្វើម្ហូបឲ្យបានច្រើនមុខ និងជៀសវាងការដាក់តម្លៃថ្លៃកោរអតិថិជន ដើម្បីទាក់ទាញទេសចរឲ្យបានកាន់តែច្រើន។

សេវាស្នាក់នៅក៏ជាបញ្ហាមួយដែរ ដោយសារតែរមណីយដ្ឋានេះមានផ្ទះស្នាក់ទេសចរណ៍ត្រឹមតែ២ប៉ុណ្ណោះ ហើយផ្ទះស្នាក់នេះក៏មិនមែនជាប្រភេទផ្ទះរបស់ប្រជាពលរដ្ឋផ្ទាល់ផងដែរ ទើបធ្វើឲ្យទេសចរដែលទៅស្នាក់នៅមិនទាន់អាចយល់ច្បាស់ពីជីវភាពប្រជាជន និងទទួលនូវអារម្មណ៍របស់ប្រជាសហគមន៍ផ្ទាល់នៅឡើយទេ។

# ជំពូកទី៣

# ទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់

យោងតាមការសិក្សាទ្រឹស្តី ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ការអង្កេត និងចុះសម្ភាសន៍ដោយផ្ទាល់ជាមួយទេសចរ អាជីវករ និងអាជ្ញាធរ យើងឃើញថារមណីយដ្ឋានធម្មជាតិកោះដាច់ទាមទារឲ្យមានការចូលរួមកែលម្អ ដើម្បីឲ្យកាន់តែមានភាពទាក់ទាញចំពោះទេសចរជាតិ និងអន្តរជាតិ។

ឆ្លងតាមការស្រាវជ្រាវ និងចុះអង្កេតដោយផ្ទាល់ ក្រុមយើងខ្ញុំបានសង្កេតឃើញថា រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់កំពុងតែជួបប្រទះ នឹងបញ្ហាមួយចំនួនដែលមិនអាចមើលរំលងបាន។ បញ្ហាប្រឈមទាំងនោះមានដូចជា ហេដ្ឋារចនាសម្ព័ន្ធ សេវាបង្គន់អនាម័យ បញ្ហាអនាម័យ បរិស្ថាន ខ្វះភាពច្នៃប្រឌិត ការផ្គត់ផ្គង់ចំណីអាហារមិនទាន់មានភាពសម្បូរបែប កង្វះខាតក្នុងការផ្សព្វផ្សាយ និង ទាមទារឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធមួយចំនួន។ បញ្ហាទាំងនេះកំពុងទាមទារឲ្យមានចំណាប់អារម្មណ៍ ការយកចិត្តទុកដាក់ រៀបចំ និងស្តារឡើងវិញពីសំណាក់អាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ ប្រជាពលរដ្ឋ និងទេសចរ តាមរយៈការចូលរួមចំណែកដូចខាងក្រោមនេះ

## ៣.១. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ

យោងទៅតាមសម្ភាសន៍ និងអង្កេតបានបង្ហាញឲ្យឃើញថាបញ្ហាប្រឈមចំបងក្នុងការអភិវឌ្ឍរម្មណីយដ្ឋាននោះគឺ ហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកផ្លូវថ្នល់ដែលជាចំណែកមួយយ៉ាងសំខាន់ក្នុងការស្រូបទាញយកទេសចរជាតិ និងអន្តរជាតិ ឲ្យមកកម្សាន្តនៅតំបន់រម្មណីយដ្ឋានមួយ។ យោងតាមការចុះអង្កេតផ្ទាល់បានបង្ហាញថា នៅក្នុងតំបន់រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់នៅមានបញ្ហាខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវចុះឡើងទៅកំពង់ចំលងមានលក្ខណៈចោទ និងរអិលបន្តិច ដែលអាចបង្កការលំបាកបន្តិចដល់អ្នកធ្វើដំណើរតាមទោចក្រយានយន្ត។

ក្រាហ្វិកលេខ៦ មធ្យោបាយក្នុងការធ្វើដំណើររបស់ទេសចរ



យោងទៅតាមការសម្ភាសន៍ជាមួយទេសចរ យើងឃើញថាដោយសារតែចំនួនអ្នកធ្វើដំណើរតាមម៉ូតូច្រើន ដូចនេះបញ្ហាហេដ្ឋារចនាសម្ព័ន្ធមួយទៀតដែលត្រូវគិតគូរនោះគឺទាក់ទងនឹងផ្លូវមួយខ្សែដែលចុះពីកំពង់ចំលងវត្តក្តីចាស់ទៅកាន់ឆ្នេរខ្សាច់នៅក្នុងឃុំកោះដាច់ មានសភាពរអិលខ្លាំងពិបាកក្នុងការធ្វើដំនើរតាមម៉ូតូខ្លាំងមែនទែននៅពេលដែលមានភ្លៀងធ្លាក់ ម៉្យាងវិញទៀតមានសភាពហ៊ុយខ្លាំងក្នុងអឡុងពេលរដូវក្តៅនៅពេលមាន រថយន្តបរកាត់លឿនដែលចោទជាបញ្ហាដល់សុខភាពភ្នែក និងផ្លូវដង្ហើមរបស់ទេសចរ និងប្រជាពលរដ្ឋ ចំណែកទំហំផ្លូវក៏មានសភាពតូចពិបាកក្នុងបើកបរជៀសគ្នារវាងរថយន្តនិងរថយន្ត មួយវិញទៀតចំណែកភាគច្រើននៃផ្លូវចូលទៅកាន់រម្មណីយដ្ឋាននេះគឺមិនទាន់មានការរៀបចំចាក់បេតុងនៅឡើយ ជាហេតុបណ្តាលឲ្យទេសចរពិបាកធ្វើដំណើរ។ បន្ថែមពីនេះទៅទៀតតំបន់កោះដាច់ក៏នៅខ្វះខាតផ្លាកសញ្ញាប្រាប់ផ្លូវផងដែរដែលជាហេតុអាចបង្កការលំបាកដល់ទេសចរក្នុងការធ្វើដំណើរទៅកម្សាន្ត ឬអាចធ្វើឲ្យពួកគាត់ខាតបង់ពេលវេលាទៅលើបញ្ហាវង្វេងផ្លូវ។

តាមរយៈការសម្ភាសន៍ផ្ទាល់ ទេសចរជាច្រើនបានស្នើឲ្យមានការរៀបចំស្ថាបនាកែលម្អផ្លូវលំចូលទៅកាន់រម្មណីយដ្ឋានឲ្យមានសោភ័ណ្ឌភាពស្អាតជាងនេះ ដើម្បីរក្សាសុខុមាលភាពសម្រាប់ប្រជាពលរដ្ឋ និងទេសចរផ្ទាល់ ។ ពួកគាត់បានបញ្ជាក់ថា ផ្លូវដែលចុះពីកំពង់ចម្លងទៅកាន់រមណីយដ្ឋាន ពិបាកធ្វើដំណើរខ្លាំងណាស់ជាពិសេសនៅពេលដែលមានភ្លៀងធ្លាក់ ជាក់ស្តែងគាត់ធ្លាប់បានមកលេងចំពេលមានភ្លៀងធ្លាក់ម្តង ទឹកភ្លៀងបានធ្វើឲ្យដីក្លាយជាដីភក់ល្បាប់មិនអាចបន្តដំណើរទៅដល់តំបន់កម្សាន្តបានទេទើបធ្វើឲ្យគាត់សម្រេចចិត្តបកក្រោយត្រឡប់ទៅផ្ទះវិញ។ ចំណែករដូវក្តៅវិញផ្លូវក៏ហ៊ុយទៀតសឹងតែធ្វើឲ្យគាត់មើលផ្លូវមិនឃើញទៅហើយ ងាកទៅរកទេសចរដទៃទៀតពួកគាត់ក៏មាន យោបល់មិនខុសពីគ្នាប៉ុន្មាននោះដែរ ពួកគាត់ក៏សុំសំនូមពរទៅដល់ក្រសួង និងមន្ទីរដែនដីឲ្យមានការរៀបចំកែលម្អផ្លូវមួយខ្សែនេះឲ្យមានភាពងាយស្រួលក្នុងការធ្វើរដំណើរផង។

មិនត្រឹមតែទេសចរ ដែលមកកម្សាន្តសំណូមពរឲ្យមានការអភិវឌ្ឍផ្នែកផ្លូវថ្នល់នោះទេ សូម្បីតែអាជីវករ និងអាជ្ញាធរប្រចាតំបន់ក៏បានស្នើរឲ្យមានការជួសជុល និងស្តារឡើងវិញនូវផ្លូវថ្នល់ដែលខូចខាត និងខ្វះសោភណ្ឌភាពផងដែរ ដើម្បីឲ្យពួកគាត់ រួមជាមួយប្រជាពលរដ្ឋដទៃទៀតធ្វើដំណើរមានភាពងាយស្រួល និងឆាប់រហ័សជាងពេលបច្ចុប្បន្ននេះ។

យោងតាមការស្រាវជ្រាវ និងការសម្ភាសន៍ជាមួយទេសចរ គ្រប់មន្ទីរ អាជ្ញាធរដែនដីសាលាខេត្ត មន្ទីរសាធារណៈការ និងដឹកជញ្ជូន និងអ្នកដែលពាក់ព័ន្ធទាំងអស់ ត្រូវតែគិតគូរស្តារនិងជួសជុលឡើងវិញនូវផ្លូវដែលខូចខាតមួយចំនួន និងកែលម្អទៅលើផ្លូវដែលមិនទាន់មានសោភ័ណ្ឌភាព ឲ្យមានសភាពល្អស្អាត ដោយអាចចាក់បេតុង មួយវិញទៀតអាជ្ញាធរគួរតែរៀបចំតម្លើងផ្លាកសញ្ញាប្រាប់ផ្លូវឲ្យបានគ្រប់ផ្លូវទាំងអស់ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ទេសចរនិងប្រជាពលរដ្ឋ តាមការស្នើសុំរបស់ពួកគាត់។ បន្ថែមពីនេះទៀតគួរតែធ្វើការពង្រីកផ្លូវឲ្យអស់ពីសមត្ថភាព និងដាក់ភ្លើងបំភ្លឺផ្លូវឲ្យបានច្រើន តាមដងផ្លូវទាំងអស់ដើម្បីសម្រួលដល់ ការធ្វើដំណើរ

នៅពេលមេឃងងឹត បើសិនជាអាចបន្ថែមជាមួយនឹងការដាំដើមផ្កាតូចៗទាបៗ ជារង្វើលនៅតាមដងផ្លូវទៅកាន់រមណីយដ្ឋានគឺកាន់តែល្អ ដើម្បីបង្កើនភាពទាក់ទាញមួយកំរិតទៀត។

## ៣.២. ការគ្រប់គ្រងបរិស្ថាន

តាមការលើកឡើងក្នុងជំពូកមុន និងការចុះអង្កេតដោយផ្ទាល់ ការគ្រប់គ្រងអនាម័យ និងបរិស្ថានពិតជាមានចន្លោះប្រហោងបន្តិចបន្តួចមែន បូកផ្សំជាមួយនឹងកង្វះការសម្អាត និងការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធមួយចំនួនជាពិសេសគឺទេសចរផ្ទាល់តែម្តង ទើបធ្វើឲ្យបរិស្ថាននៅរមណីយដ្ឋានធម្មជាតិកោះដាច់រំលេចឡើងនូវកាកសំណល់ និងសម្រាមដែលភាគច្រើនគឺនៅលើវាលខ្សាច់ដោយសារតែការចោលសម្រាមពាសវាលពាសកាលរបស់ទេសចរ និងប្រជាពលរដ្ឋមួយចំនួន។ ងាកទៅទឹកទន្លេវិញកន្លែងដែលមានជម្រៅទឹករាក់ល្មមដែលអាចលេងបានគឺកន្លែងខ្លះមានទឹកល្អក់ខ្លាំង និងមើលទៅគ្មានផាសុកភាពដោយសារតែឥរិយាបថខ្វះការពិចារណារបស់ទេសចរមួយចំនួនតាមរយៈការបង្ហូរចោលកាកសំណល់រាវទៅក្នុងទឹកទន្លេ ថែមនិងការស្តោះទឹកមាត់ញឹកញាប់ខ្លាំងពេក។ កត្តាទាំងនេះអាចជះឥទ្ធិពលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទេសចរណ៍ក្នុងតំបន់ដោយសារការមើលឃើញ ពីសំណាក់ទេសចរដទៃទៀតនឹងធ្វើឲ្យពួកគេខ្ពើមរអើមមិនហ៊ានចុះលេងទឹក ឬ រាងចាលក្នុងការវិលត្រឡប់មកកម្សាន្តម្តងទៀត។

ក្រាហ្វិកលេខ៩ ការយល់ឃើញរបស់ ទេសចរទៅលើបរិស្ថាន អនាម័យ ក្នុងរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់




យោងទៅតាមការសម្ភាសន៍ជាមួយទេសចរដោយផ្ទាល់បានបង្ហាញថា ការវាយតម្លៃទៅលើបរិស្ថានពីសំណាក់ទេសចរគឺស្ថិតនៅក្នុងកំរិតមួយទាបនៅឡើយ ដែលពិសេសគឺខ្វះសណ្តាប់ធ្នាប់ក្នុងការចោលសម្រាម និងកង្វះខាតធុងសម្រាម។ ទេសចរភាគច្រើនក៏បានសំណូមពរឲ្យបន្ថែមការ

រឹតបន្តឹង យកចិត្តទុកដាក់ផ្នែកបរិស្ថាន និងអនាម័យ ឲ្យបានតឹងរឹងជាងនេះ ព្រោះពួកគាត់យល់ថាវាក៏ជាហេតុផលមួយក្នុងការធ្វើឲ្យមានបញ្ហាដល់សុខភាពដែលអាចបង្កជាជំងឺផ្សេងៗ ប្រសិនបើពួកគាត់ទៅកម្សាន្តនៅតំបន់ដែលមានបរិស្ថានមិនល្អជាញឹកញាប់។

ចំណែកបង្គន់អនាម័យវិញក៏ជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ទេសចរ និងអាជីវករប្រចាំតំបន់ផងដែរ ហើយតាមរយៈការអង្កេតផ្ទាល់យើងឃើញថាបង្គន់អនាម័យក៏នៅមិនទាន់មានផាសុកភាពគ្រប់គ្រាន់សំរាប់ទេសចរនៅឡើយ ជាពិសេសសម្រាប់មនុស្សស្រី និងមនុស្សចាស់ ដោយសារតែវាមិនទាន់មានប្រព័ន្ធបង្ហូរត្រឹមត្រូវនៅឡើយ បូករួមទាំងក្លិនមិនសូវល្អទៀតផង ដែលវាក៏ជាកត្តាមួយដែលអាចធ្វើឲ្យភ្ញៀវទេសចរណ៍រារែកចិត្តក្នុងការមកកម្សាន្តផងដែរ។ បើគិតគូរពីបញ្ហាបរិស្ថានវិញបង្គន់នៅរម្មណីយដ្ឋានកោះដាច់ដែលមាន ត្រឹមតែបន្ទះក្តារដាក់ផ្ទាល់ជាមួយនឹងខ្សាច់ព្រមជាមួយនឹងទឹកមួយធុងនេះ ក៏ផ្តល់ផលប៉ះពាល់អវិជ្ជមានផងដែរដែលអាចនឹងធ្វើឲ្យមានការសាយភាយ ឬជះក្លិនមិនល្អនៅពេលណាមួយ។

ជារួម អាជ្ញាធរ ភូមិ ឃុំ សាលាខេត្ត មន្ទីរបរិស្ថានខេត្ត ត្រូវគិតគូរឡើងវិញពីបញ្ហាអនាម័យ និងបរិស្ថានតាមរយៈការដាក់ចេញនូវយន្តការសមស្របនានាដូចជា បង្កើនចំនួនធុងសម្រាមឲ្យបានគ្រប់គ្រាន់ទាំងនៅតំបន់រមណីយដ្ឋានផ្ទាល់ និងនៅតាមទីសាធារណៈជុំវិញតំបន់ទេសចរណ៍ រួមជាមួយនឹងការព្យាយាមផ្សព្វផ្សាយលើកទឹកចិត្តប្រជាពលរដ្ឋក្នុងតំបន់ និងទេសចរឲ្យចេះស្រលាញ់ ថែរក្សាបរិស្ថាន ជៀសវាងការចោលសម្រាមពាសវាលពាសកាល។ លើសពីនេះគួរតែមានការដាក់ពិន័យទៅដល់ជនណាដែលបានចោលសម្រាមផ្តេសផ្តាស បង្ហូរកាកសំណល់ទៅក្នុងទន្លេ ឬបង្កបញ្ហាផ្សេងៗ ដែលមានផលអវិជ្ជមានទៅ លើបរិស្ថានដើម្បីឲ្យមានភាពរាងចាល និងជាការបង្ហាញគំរូអាក្រក់ទៅដល់ពលរដ្ឋដទៃទៀតផងដែរ។ រាជរដ្ឋាភិបាលគួរតែបង្កើតឲ្យមានការអភិវឌ្ឍ និងពិនិត្យគុណភាពទឹក ជាក់ស្តែងដូចជាករណីសិក្សាប្រទេសថៃ និងកាណាដា ដែលរដ្ឋាភិបាលគេបង្កើតឲ្យមានការត្រួតពិនិត្យគុណភាពទឹកដើម្បីទាក់ទាញ និងរក្សាសុខមាលភាពទេសចរព្រោះថាតំបន់ទេសចរណ៍នោះ គឺជាតំបន់ដែលផ្តោតសំខាន់ទៅលើការកម្សាន្តតាមផ្ទៃទឹកតែម្តង។ បន្ថែមពីលើចំណុចខាងលើនេះ អាជីវករទាំងអស់គួរតែចែកវេនគ្នាជួយធ្វើការសម្អាតបរិស្ថានជុំវិញ រមណីយដ្ឋានឲ្យបានទៀងទាត់ ដើម្បីឲ្យមានបរិស្ថានស្អាតល្អឡើងវិញជារៀងរាល់ថ្ងៃ សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ និងជាផលប្រយោជន៍ចំពោះអាជីវករផ្ទាល់ ដែលអាចចំណេញបានទាំង សុខភាពរាងកាយរឹងមាំល្អ ថែមទាំងទទួលបាន ការទាក់ទាញឲ្យមានកំនើនទេសចរ ដែលជួយបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគាត់។ លើសពីនេះទៅទៀត ប្រសិនបើអាចធ្វើបាន អាជ្ញាធរ គួរតែកែលម្អផ្ទៃទឹកឲ្យមានសភាពស្រស់ស្អាត និងមានសោភ័ណ្ឌភាពឡើង ដោយរៀបចំចាត់ចែងឲ្យមានអ្នកសម្អាតផ្ទៃទឹកឲ្យបានទៀងទាត់ នៅក្នុងពេលវេលាសមរម្យ និងជាក់លាក់ណាមួយ ដែលត្រូវប្រមូល និងស្រង់សម្រាមដែលលិចចូលទៅក្នុងទឹកឲ្យឡើងមកវិញបានស្អាតល្អ។

ទន្ទឹមនឹងនេះ ស្ថាប័នពាក់ព័ន្ធ និងសាលាក្រុងភ្នំពេញ គួរតែរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ផ្សេងៗឲ្យបានត្រឹមត្រូវមានអនាម័យល្អ និ ងសណ្តាប់ធ្នាប់ ដើម្បីជាប្រយោជន៍ដល់សហគមន៍ទាំងមូល។ ចំណែកអ្នកគ្រប់គ្រងសហគមន៍គួរតែរៀបចំតូបលក់នំចំណី អាហារនានាឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយឲ្យមានគុណភាព និងត្រឹមត្រូវតាមស្តង់ដារ។ ចំណែកទីតាំងចតឡានវិញគួរតែមានបន្ថែមការមើលថែរថយន្តដោយប្រើប្រាស់ក្រដាសឡាំង ឬប្រភេទក្រដាសក្រាស់ផ្សេងៗគ្របពីលើកញ្ចក់ខាងមុខរថយន្តការពារកុំឲ្យកម្តៅថ្ងៃជះចូលរថយន្តខ្លាំងពេក ដើម្បីឲ្យភ្ញៀវទេសចរណ៍មកកម្សាន្តពេលថ្ងៃមានអារម្មណ៍ស្ងប់ចិត្ត និងអាចនៅកម្សាន្តបានរយៈពេលយូរដោយមិនមានការបារម្មណ៍ពីបញ្ហាកម្តៅថ្ងៃទៅលើរថយន្តរបស់គាត់។

មន្ទីរទេសចរណ៍ និងអ្នកគ្រប់គ្រងសហគមន៍ក៏គួរតែរៀនចំបង្កន់អនាម័យដែលមានផាសុកភាព រួមជាមួយ នឹងស្តង់ដារខ្ពស់ជាងពេលបច្ចុប្បន្ន និងបន្ថែមនូវការសម្អាតឲ្យបានញឹកញាប់។ មានរៀបចំជាដើមផ្កាតាមផ្លូវចូល កៃលម្អ និងពង្រីកផ្លូវ បន្ថែមផ្លាកសញ្ញាណែនាំផ្លូវផ្សេងៗដើម្បីបង្ហាញផ្លូវ និងបញ្ចៀសបញ្ហាវង្វេងផ្លូវដល់ទេសចរ។ បង្កើត និងរៀបចំឲ្យមានពាក្យស្លោកទាក់ទងនឹងទេសចរណ៍ បរិស្ថាន សម្រាប់ឲ្យទេសចរមានការយល់ដឹងបន្ថែម និងបណ្តុះគំនិតស្រលាញ់បរិស្ថាន។ មានការត្រួតពិនិត្យទៅលើទេសចរដែលមកកម្សាន្តឲ្យមានសណ្តាប់ធ្នាប់ កុំឲ្យពួកគាត់ប្រព្រឹត្តសកម្មភាពណាមួយដែលប៉ះពាល់ដល់បរស្ថាន វប្បធម៌ ប្រពៃណី ជៀសវាងការធ្វើឲ្យមានការខូចខាតទ្រព្យសម្បត្តិណាមួយរបស់ជាតិ ឬបង្កជាភាពចលាចលអសន្តិសុខ និងអំពើហិង្សាផ្សេងៗឲ្យកើតមានឡើងនៅក្នុងតំបន់ទេសចរណ៍នេះ។

ដូច្នេះ ការរៀបចំតាមដាន ទៅលើការគ្រប់គ្រងអនាម័យ និងបរិស្ថាននៅតំបន់រម្មណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់ឲ្យមានលក្ខណៈត្រឹមត្រូវតាមស្តង់ដាររម្មណីតដ្ឋានស្អាត គួរតែអនុវត្តតាមនីតិវិធីដូចបានរៀបរាប់ខាងលើ ដើម្បីទទួលបានជោគជ័យ និងទទួលបានផលប្រយោជន៍ពីតំបន់នោះ។

## ៣.៣. បង្កើនគុណភាពអាហារ និងភេសជ្ជៈ

តាមការសង្កេតមើលការផ្គត់ផ្គង់អាហារនិងភេសជ្ជៈ ក៏ដូចជាបទសម្ភាសន៍ជាមួយទេសចរ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខ្វះខាតនូវគុណភាព រូបមន្ត របៀបចម្អិនអាហារ និងសោភ័ណ្ឌភាពអាហារ។

ទេសចរបានបញ្ចេញមតិថា នៅតំបន់រម្មណីយដ្ឋានកោះដាច់នេះមានមុខម្ហូបតែពីរមុខប៉ុណ្ណោះសម្រាប់ទទួលទានគឺមាន់ដុតជាមួយឆាត្រកួនជាមួយគ្រឿងក្នុងមាន់ និងត្រីបំពងជាមួយស្វាយខ្ចី នោះក៏ដោយសារតែពួកគាត់ចេះរបៀបចម្អិនម្ហូបដែលពេញនិយម និងងាយស្រួលបែបនេះតៗពីគ្នាពីគ្រួសារតែប៉ុណ្ណោះ។

ក្រាហ្វិកលេខ១០ ការរៀនចំអិនម្ហូបអាហាររបស់អាជីវករ




តាមរយៈការជួបសម្ភាសន៍ជាមួយអាជីវករបានឲ្យដឹងថា វិធីធ្វើម្ហូបរបស់ពួកគាត់ភាគច្រើនគឺចេះតៗគ្នាពីគ្រួសារតែប៉ុណ្ណោះដែលជាហេតុនាំឲ្យគុណភាពអាហារនៅមានកម្រិតនៅឡើយ និងមានតែមុខម្ហូបស៊ាំញ៉ាំដែលៗ។ ពួកគាត់ក៏បានសំនូមពរឲ្យមានការចុះបណ្តុះបណ្តាលផ្នែកម្ហូបអាហារបន្ថែមឲ្យពួកគាត់ផងដែរដើម្បី អាចឲ្យពួកគាត់បង្កើនចំណូលក្នុងការលក់អាហារ និងទាក់ទាញទេសចរមកបន្ថែមទៀតផងដែរ។

ក្រាហ្វិកលេខ១១ ការយល់ឃើញរបស់ទេសចរទៅលើគុណភាពអាហារក្នុងរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់



ទេសចរបាន បញ្ជាក់បន្ថែមថាចំណែកគុណភាពអាហារគឺមិនសូវមានគុណភាពស្តង់ដារនោះទេ ព្រោះពេលគាត់មកលេងម្តងៗសាច់មាន់មានគុណភាពខុសគ្នា ពេលខ្លះផុយ ពេលខ្លះឆ្ងាញ់ល្មមនឹងហូប ប៉ុន្តែបើនិយាយ ពីអនាម័យគឺអាចទទួលយកបាន ចានក៏នៅថ្មីប៉ុន្តែមិនសូវមានសោភ័ណ្ឌភាពប៉ុន្មាននោះទេព្រោះវាជាចានសំរាប់ហូបលក្ខណៈគ្រួសារប៉ុណ្ណោះ មិនសាកសមនឹងប្រើសម្រាប់លក់ដូរបម្រើជូនទេសចរនោះទេ។ ទេសចរក៏បានបន្ថែមទៀតថាអាហារផ្សេងក៏មានអ្នកដើរលក់តាមខ្ទះដែរ តែជូនឆ្ងាញ់ ជូនអត់ ហើយមានតែពីរទៅបីមុខប៉ុណ្ណោះដូចជា ឆាខ្យងប្រហិតចៀន ស្លាបមាន់អាំង ជាដើម។ គាត់បានបន្តថា មិនតែប៉ុណ្ណោះអាហារសម្រន់ដែលគេដើរលក់ទាំងនោះជាគ្រឿងសាច់ដែល ភាគច្រើនគឺសុទ្ធតែនាំចូលពីប្រទេសជិតខាងយើងដែលពិតជាធ្វើឲ្យប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរ និងអាចមានបញ្ហាសម្រាប់អ្នកបរិភោគនាពេលអនាគតទើបធ្វើឲ្យគាត់ និងក្រុមគ្រួសារមានការខ្លាចរអារនឹងទទួលទានអាហារទាំងនោះ។

ក្រាហ្វិកលេខ១២ការយល់ឃើញរបស់ទេសចរទៅលើតម្លៃអាហារក្នុងរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់




ចំពោះតម្លៃវិញទេសចរមួយចំនួនយល់ថាមានតម្លៃសមរម្យ ប៉ុន្តែមួយចំនួនទៀតក៏នៅយល់ឃើញថាថ្លៃ ព្រោះតម្លៃមិនសមស្របនឹងបរិមាណ ហើយក៏ដោយសារតែអាជីវករមួយចំនួនបានដាក់បង្កើនតម្លៃឲ្យថ្លៃហើយទេសចរខ្លះគាត់មិនសូវចេះតថ្លៃ ទេសចរមួយចំនួនធំបានស្នើរឲ្យមានការពង្រឹងបន្ថែមទៅលើផ្នែកម្ហូបអាហារនេះផងដែរ ដែលអាចមានការកំណត់តម្លៃជាក់លាក់ជៀសវាងការលក់កោរអតិថិជនបន្តទៀតដែលជាហេតុផលអាចឲ្យគាត់ឈប់មកកម្សាន្តទៀត ពួកគាត់ក៏បានសំនូមពរបន្ថែមឲ្យមានការបង្កើនជម្រើសម្ហូបអាហារ និងអនាម័យ ដើម្បីផ្តល់សេចក្តីទុកចិត្តដល់ពួកគាត់នៅពេលទទួលទាន។

ម្ហូបអាហារ បើក្រៅពីផ្តោតទៅលើគុណភាព សោភណ្ឌភាពហើយនោះ អ្វីដែលសំខាន់ជាងគេនោះគឺរសជាតិ ហើយរសជាតិនៃអាហារគឺបានមកពីថ្វីដៃផ្សំគ្រឿង និងគុណភាពរបស់គ្រឿងផ្សំ។

ក្រាហ្វិកលេខ១៣ ប្រភពគ្រឿងផ្សំធ្វើម្ហូបក្នុងរមណីយដ្ឋានកោះដាច់




តាមរយៈក្រាហ្វិកខាងលើបានបង្ហាញថា ប្រភពគ្រឿងផ្សំភាគច្រើនគឺទទួលបានអ្នកផ្គត់ផ្គង់ប្រចាំរមណីយដ្ឋានផ្ទាល់តែម្តង ចំណែកគ្រឿងផ្សំមួយចំនួនទៀតយើងក៏មើលឃើញថាមានហានិភ័យខ្លះៗដែរ ដោយសារតែគ្រឿងផ្សំទាំងនោះត្រូវបាននាំចូលមកពីបរទេសជាពិសេសនោះគឺប៊ីចេង ស្ករសរ និងម្សៅស៊ុប ដែលវាអាចជាផលិតផលមានគុណភាពទាប។ ចំណែកភេសជ្ជៈវិញគឺសុទ្ធតែជាភេសជ្ជៈកំប៉ុងទាំងទឹកផ្លែឈើ និងស្រាបៀរ។

យោងតាមព័ត៌មានខាងលើនេះ អាជ្ញាធរដែនដី និង មន្ទីរកសិកម្ម គួរតែចុះផ្តល់ការបណ្តុះបណ្តាលផ្នែកជំនាំដាំដុះដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ឲ្យចេះជំនាញក្នុងការដាំដុះបន្លែ ផ្លែឈើ និងចិញ្ចឹមសត្វតាមបែបធម្មជាតិ ដើម្បីបម្រើ ផ្គត់ផ្គង់ដល់វិស័យទេសចរណ៍នៅក្នុងសហគមន៍ជៀសវាងការនាំវត្ថុធាតុដើមមកពីបរទេស និងថែមទាំងអាចលើកកម្ពស់ ទ្រទ្រង់ជីវភាពគ្រួសារបានថែមមួយកម្រិតទៀតផងដែរ។

មន្ទីរទេសចរណ៍ គួរតែរៀបចំផែនការទាក់ទាញដល់ផ្នែកឯកជន ជាពិសេសគឺខាងផ្នែកសាលាបណ្តុះបណ្តាលមុខម្ហូប ភោជនីយដ្ឋាន និងសណ្ឋាគារ ឲ្យចុះមកជួយណែនាំបង្ហាត់បង្រៀន ពីរបៀបរក្សាទុកដាក់សាច់ បន្លែ គ្រឿងទេស បច្ចេកទេស ការរក្សាអនាម័យ និងរបៀបចម្អិនអាហារតាមស្តង់ដារ រួមជាមួយនឹងការបង្ហាញពីរូបមន្ត និងរបៀបចម្អិនមុខម្ហូបថ្មីៗ ទាក់ទាញបន្ថែមផ្សេងៗដល់អាជីវករ ប្រជាពលរដ្ឋក្នុងសហគមន៍ផ្ទាល់តែម្តង។ ជាមួយគ្នាផងដែរក្រុមអ្នកបង្រៀនក៏អាចផ្តល់ចំណេះដឹងផ្នែកសោភ័ណ្ឌភាពអាហារបន្ថែមពីលើនោះផងដែរ ដូចជាការចិតបន្លែផ្លែឈើឲ្យមានភាពស្អាតទាក់ទាញដោយចំណាយពេលខ្លីតាមរយៈការផ្លាស់ប្តូរកាំបិត ទម្លាប់នៃការចិត និងការ

ធ្លាក់ផ្លែឈើ ជាដើម។ មួយវិញទៀតអាជ្ញាធរ គួរតែមានវិធានការណ៍កាត់បន្ថយការដាក់លក់ភេសជ្ជៈដែលនាំចូលពីបរទេស ឬភេសជ្ជៈកំប៉ុងដោយអាចជំនួសមកវិញនូវភេសជ្ជៈធម្មជាតិប្រចាំសហគមន៍រួមមាន ទឹកអំពៅ ទឹកត្នោតជូរ ទឹកត្នោតផ្អែម និងទឹកដូងជាដើម។

## ៣.៤. ការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

យើងបានដឹងរួចមកហើយថា សន្តិសុខ សុវត្ថិភាព បានដើរតួយ៉ាងសំខាន់ ក្នុងការជំរុញទឹកចិត្តរបស់មនុស្សឲ្យទៅកម្សាន្តនៅ តំបន់ទេសចរណ៍ណាមួយ។ កាលណារមណីយមួយមានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ ទេសចរនឹងចង់ទៅកម្សាន្តនៅទីនោះជាក់ជាមិនខាន ព្រោះវានឹងផ្តល់ឲ្យទេសចរនូវសុខភាពផ្លូវចិត្តដ៏រឹងមាំ ថាពួកគេទទួលបានសុវត្ថិភាពជានិច្ចក្នុងអំឡុងពេលនៃដំណើរកម្សាន្តរបស់ពួកគេ។

ក្រាហ្វិកលេខ១៤ ការយល់ឃើញរបស់ទេសចរទៅលើសន្តិសុខ សណ្តាប់ធ្នាប់ក្នុងរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់




ចំណែកតំបន់រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់វិញគឺមានសន្តិសុខល្អ មិនមានបញ្ហាឆក់ ប្លន់ កាប់សម្លាប់ ឬអំពើហិង្សាធ្ងន់ធ្ងរណាមួយកើតឡើងនោះទេ ប៉ុន្តែការរក្សាសុវត្ថិភាពចំពោះភ្ញៀវដែលទៅហែលទឹកលេងកម្សាន្តនោះហាក់នៅមានចំនុចខ្វះខាតនៅឡើយ ដោយសារតែធ្លាប់មានទេសចរលង់ទឹកស្លាប់នៅតំបន់ នោះពីរទៅបីដងរួចមកហើយព្រោះតែជនរងគ្រោះបានហែលហួសចូលក្នុងតំបន់គ្រោះថ្នាក់ ដែលអាជ្ញាធរបានដាក់ខ្សែជាសញ្ញាឲ្យដឹងរួចហើយ។ ដូច្នេះហើយសូមអាជ្ញាធរ មេត្តាពិចារណាឡើងវិញ ក្នុងការដាក់ឲ្យមានអ្នកយាមល្បាតដែលមានជំនាញសង្គ្រោះបន្ទាន់ខ្លះនៅតាមកន្លែងមួយចំនួន ដើម្បីចាំដាស់តឿន ហាមប្រាម ដល់ភ្ញៀវដែលមកកម្សាន្តកុំឲ្យភ្លេចខ្លួនហែលហួសចូលដល់កន្លែងដែលបង្កគ្រោះថ្នាក់ ម្យ៉ាងវិញបើសិនជាកើតមានហេតុការណ៍

គ្រោះថ្នាក់ជាយថាហេតុណាមួយនឹងមានមនុស្សដែលអាចជួយសង្គ្រោះដល់ទេចរ ឬអាជីវករបានទាន់ពេលវេលា។ អាជ្ញាធរគួរតែបង្កើតជាវេទិកាណែនាំបង្ហាញពីតម្លៃនៃទេសចរដល់ប្រជាជនក្នុងតំបន់ ជាក់ស្តែងដូចជាករណីសិក្សាប្រទេសកាណាដា ដែលមានអាជ្ញាធរបានបង្កើតវេទិកាណែនាំដល់ប្រជាជន អាជីវករ និងអ្នកដែលពាក់ព័ន្ធឲ្យមកស្តាប់នូវអត្ថប្រយោជន៍ដែលពួកគាត់ទទួលបានពីទេសចរ ហើយគួរធ្វើយ៉ាងណាដើម្បីរក្សា និងអភិវឌ្ឍតំបន់ឲ្យកាន់តែមានភាពទាក់ទាញដោយខិតខំពង្រឹងសន្តិសុខនិងសុវត្ថិភាពក្នុងរមណីយដ្ឋាន។

បន្ថែមពីនេះទៅទៀតអាជ្ញាធរ និង មន្ទីរសុខាភិបាល គួរតែបង្កើតឲ្យមានពេទ្យព្យាបាលមួយ និងបុគ្គលិកពេទ្យមួយចំនួន ប្រចាំរមណីយដ្ឋានតែម្តងដើម្បីឲ្យមានការសង្គ្រោះបន្ទាន់ឲ្យបានឆាប់រហ័ស និងទាន់ពេលវេលាដល់អ្នកដែលមកកម្សាន្ត ឬប្រជាពលរដ្ឋដែលប្រកបអាជីវកម្ម និងរស់នៅក្បែរនោះ នៅពេលដែលពួកគេមានបញ្ហាសុខភាព ឬត្រូវការ ការសង្គ្រោះបន្ទាន់។

## ៣.៥. បង្កើនការផ្សព្វផ្សាយ និងជំរុញទីផ្សារ

ដើម្បីបង្កើនសក្តានុពលទាក់ទាញទេសចរជាតិ និងអន្តរជាតិ ក្រសួងទេសចរណ៍ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអ្នកដែលពាក់ព័ន្ធ គួរតែគិតគូរជំរុញឲ្យមានការផ្សព្វផ្សាយអំពីរមណីយដ្ឋាន និងរៀបចំឲ្យមាន ព្រឹត្តការណ៍ផ្សេងៗ នៅក្នុងតំបន់រមណីយដ្ឋានធម្មជាតិកោះដាច់បន្ថែមទៀតផងដែរ។

### ៣.៥.១. បង្កើនការផ្សព្វផ្សាយ

បន្ទាប់ពីបានរៀបចំឲ្យមានការអភិវឌ្ឍផ្សេងៗ ដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធ បង្កើនការគ្រប់គ្រងអនាម័យ និងបរិស្ថាន បង្កើនគុណភាពអាហារ និងភេសជ្ជៈ ការបង្កើនកិច្ចសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធ ការពង្រឹងសណ្តាប់ធ្នាប់សាធារណៈ និងរៀបចំផលិតផលទេសចរណ៍ក្នុងតំបន់ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពគួរតែរៀបចំធ្វើការផ្សព្វផ្សាយផ្សេងៗដែលបង្ហាញពីសក្តានុពលដ៏សម្បូរបែបនៅក្នុងរមណីយដ្ឋាន ដើម្បីឲ្យទេសចរបានដឹង និងស្គាល់ពីរមណីយដ្ឋានឲ្យបានច្រើន។

ក្រាហ្វិកលេខ១៥ ទេសចរស្គាល់រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់តាមរយៈ



យោងទៅតាមក្រាហ្វិកខាងលើបានបង្ហាញឲ្យឃើញថា ទេសចរភាគច្រើនបានស្គាល់រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់ គឺតាមរយៈ ប្រព័ន្ធអ៊ីនធឺណេត និងបានដឹងពីមិត្តភក្តិដែលធ្លាប់បានមកលេង។ ដូចនេះហើយ មន្ទីរទេសចរណ៍ និងផ្នែកដែលជាប់ពាក់ព័ន្ធទាំងអស់គួរតែបង្កើនការផ្សព្វផ្សាយឲ្យបានច្រើន និង ទូលំទូលាយជាងមុន ដើម្បីឲ្យមានទេសចរថ្មីៗមកកម្សាន្តនៅរមណីយដ្ឋាននេះ ដែលការផ្សព្វផ្សាយទាំងនោះអាចធ្វើតាមជាច្រើនវិធីដូចជាៈ

-ទូរទស្សន៍ ព្រោះថាគ្រួសារនៅក្នុងប្រទេសកម្ពុជាទាំងអស់សុទ្ធតែមានទូរទស្សន៍ និងមើលជាប្រចាំ ដូច្នេះរដ្ឋាភិបាលគួរតែមានការរៀបចំស្ប៉តពាណិជ្ជកម្មខ្លីតែទាក់ទាញ ដែលផ្សព្វផ្សាយពីសេវាកម្ម និងផលិតផលទេសចរណ៍របស់រម្មណីយដ្ឋានដែលមាន។

-កាសែត ក៏ជាផ្នែកមួយសំខាន់ក្នុងប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសគឺបុរសដែលជាមេគ្រួសារក្នុងវ័យ៥០ឆ្នាំឡើង ដែលកត្តានេះនឹងអាចទាក់ទាញចំពោះមេគ្រួសារឲ្យនាំក្រុមគ្រួសារពួកគាត់មកកម្សាន្តនៅរម្មណីយដ្ឋានកោះដាច់ ។

-ទស្សនាវដ្ដី ការសរសេរសេរជាអត្ថបទខ្លីៗ និង ចុះផ្សាយនូវរូបភាពទាក់ភ្នែករបស់រមណីយដ្ឋានកោះដាច់ក៏ជាការចូលរួមចំណែកទាក់ទាញទេសចរផងដែរសម្រាប់អ្នកដែលចូលចិត្តអានទស្សនាវដ្ដី ជាពិសេសគឺស្ត្រីដែលមានវ័យចាប់ពី៣០ឆ្នាំឡើងទៅ។

-ប្រព័ន្ធអ៊ីនធឺណេត ជាប្រព័ន្ធមួយដែលមនុស្សទូទាំងសកលលោករួមទាំងប្រជាជនកម្ពុជាផងដែរនោះ ប្រើប្រាស់សម្រាប់ផ្សព្វផ្សាយ និងទទួលព័ត៌មាន ជាពិសេសគឺការប្រើប្រាស់បណ្ដាញសង្គមហ្វេសប៊ុក ។ ដូច្នេះគួរតែរៀបចំឲ្យមានការផលិតវីដេអូខ្លីៗដែលបង្ហាញពីសក្ដានុពលទេចរណ៍ក្នុងតំបន់កោះដាច់ ឬថតរូបភាពជាមួយនឹងការពិពណ៌នាខ្លីៗ ហើយធ្វើការបង្ហោះ និងចែកចាយជាសាធារណៈ ដើម្បីឲ្យប្រជាជនទូទាំងប្រទេស និងសកលលោកបានឃើញ បានស្គាល់ឲ្យបានកាន់តែច្រើនពីតំបន់ទេសចរណ៍ដែលយើងចង់ផ្សព្វផ្សាយ។

-សណ្ឋាគារ និងផ្ទះសំណាក់ ជាកន្លែងដែលភ្ញៀវទេសចរណ៍ចេញចូលច្រើន ដូច្នេះខាងមន្ទីរទេសចរណ៍ ឬស្ថាប័នពាក់ព័ន្ធ អាចរៀបចំជាខិតបណ្ណផ្សព្វផ្សាយ ឬសៀវភៅ ដែលនិយាយពីរមណីយដ្ឋានកោះដាច់ ផលិតផល សេវាកម្ម ទុកនៅតាមសណ្ឋាគារ ឬផ្ទះសំណាក់។

-ក្រុមហ៊ុនទេសចរណ៍ ជាកន្លែងដែលលក់កញ្ចប់សេវាកម្មទេសចរណ៍ទៅកាន់ទេសចរទាំងក្នុង និងក្រៅប្រទេស ដូច្នេះខាងមន្ទីតទេសចរណ៍អាចធ្វើការទំនាក់ទំនងជាមួយក្រុមហ៊ុនទេសចរណ៍នានា ឲ្យប្រាប់ពីភាពទាក់ទាញរបស់រម្មណីយដ្ឋានដល់ទេសចរ ឬប្រសិនបើអាចមានការដាក់បញ្ចូលរមណីយដ្ឋាននៅ ក្នុងកញ្ចប់សេវាកម្មទេសចរណ៍របស់ពួកគេទៀតនោះនឹងកាន់តែល្អប្រសើរ។

-ក្រុមហ៊ុនដឹកជញ្ជូន ក៏ជាកន្លែងដែលទេសចរចេញចូលច្រើនមួយដែរបន្ទាប់ពីសណ្ឋាគារ និងផ្ទះសំណាក់ ដូច្នេះរៀបចំឲ្យមានខិតបណ្ណផ្សព្វផ្សាយពីរម្មណីយដ្ឋាននៅតាមក្រុមហ៊ុនដឹកជញ្ជូននានាផងដែរ។

### ៣.៥.២. ការរៀបចំព្រឹត្តការណ៍ទេសចរណ៍

ការរៀបចំឲ្យមាន ព្រឹត្តការណ៍ទេសចរណ៍នៅក្នុងតំបន់ពិតជាសំខាន់ណាស់ក្នុងការជួយទាក់ទាញឲ្យមានកំនើនទេសចរ។ តាមការសង្កេតមើលជាក់ស្តែង នៅរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់គឺនៅមានកង្វះខាតក្នុងការច្នៃប្រឌិត ដោយសារមានការមើលឃើញថាតំបន់នេះនៅអាចមានលទ្ធភាពបង្កើនភាពទាក់ទាញបានជាច្រើនយ៉ាង និងអាចពង្រឹងទៅលើសេវាកម្មដែលមានស្រាប់ឲ្យកាន់តែមានភាពល្អប្រសើរឡើង ដូច្នេះហើយអាជ្ញាធរមូលដ្ឋាន និងមន្ទីរទេសចរណ៍ គួរតែរៀបចំឲ្យតំបន់នេះមានភាពទាក់ទាញ តាមរយៈការរៀបចំបង្កើតឲ្យមានព្រឹត្តការណ៍ទេសចរណ៍នានានៅក្នុងតំបន់រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់ដូចខាងក្រោម៖

ការប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរឲ្យ បានអធឹកអធមនៅក្នុងវត្តអារាមក្នុងសង្កាត់កោះដាច់ ដោយសំណូមពរប្រជាពលរដ្ឋឲ្យមានបន្ថែម ការលេងល្បែងប្រជាប្រិយ ការរាំកម្សាន្ត ជាលក្ខណៈទ្រង់ទ្រាយធំ និងការលេងល្ខោននៅពេលយប់ជាដើម។ លើសពីនោះទៅទៀតអាជ្ញាធរគួរតែបើកឲ្យមានការលេងបាញ់ទឹកក្នុងពេលចូលឆ្នាំដោយរឹតបន្តឹងច្បាប់ និងសណ្តាប់ធ្នាប់ ឲ្យបានត្រឹមត្រូវនៅតាមផ្លូវចូលទៅកាន់រមណីយដ្ឋាន និងនៅក្នុងតំបន់រមណីយដ្ឋានផ្ទាល់តែម្តងដើម្បីបង្កើនបរិយាកាសឲ្យកាន់តែមានភាពសប្បាយរីករាយដល់ទេសចរវ័យក្មេងមួយចំនួនផងដែរ។

ការតាំងពិពណ៌ក្នុងតំបន់រមណីយដ្ឋាន ដែលមានការដាក់បង្ហាញ និងដាក់លក់នូវផលិតផលប្រើប្រាស់ ម្ហូបអាហារប្រចាំតំបន់នៅទូទាំងប្រទេស និងវត្ថុអនុស្សាវរីយ៍ផ្សេងៗដើម្បីឲ្យបងប្អូនប្រជាពលរដ្ឋក្នុងស្រុកបានស្គាល់តំបន់កោះដាច់ឲ្យកាន់តែច្បាស់ ថែមទាំងអាចជួយផ្តល់ ឱកាសឲ្យពលរដ្ឋទាំងអស់បានដាក់បង្ហាញ និងលក់ផលិតផលរបស់ខ្លួនទៀតផង។

រៀបចំឲ្យមានពិធីប្រណាំងទូកខ្នាតតូចប្រចាំឆ្នាំនៅតាមដងទន្លេក្នុងតំបន់កោះដាច់ ដែលទទួលស្វាគមន៍ការចុះ ឈ្មោះពីប្រជាពលរដ្ឋមកពីគ្រប់តំបន់ទូទាំងប្រទេស ដើម្បីជួយឲ្យទេសចរដែលមកកម្សាន្តនៅតំបន់កោះដាច់មានចំណីចក្ខុថ្មីៗរួមជាមួយនឹងភាពរំភើបសប្បាយរីករាយប្លែកៗ។ លើសពីនោះទៅទៀតការស្វាគមន៍ឲ្យ មានការចុះឈ្មោះរបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ផ្សេងៗគឺស្មើនឹងការដែលបានទាក់ទាញ ក្រុមគ្រួសាររបស់ពួកគាត់ឲ្យបានស្គាល់ និងមកកម្សាន្តនៅតំបន់កោះដាច់ដូចគ្នា។

## ៣.៦. បង្កើតផលិតផលទេសចរណ៍ថ្មីៗ

បន្ទាប់ពីបានជំរុញការផ្សព្វផ្សាយ និងបង្កើតព្រឹត្តការណ៍ទេសចរណ៍ដើម្បីទាក់ទាញភ្ញៀវឲ្យមកកម្សាន្តហើយនោះ តំបន់កោះដាច់ក៏គួរតែមានផលិតផលថ្មីៗដើម្បីបង្អូតទេសចរឲ្យកាន់តែជាប់ចិត្តបន្ថែមទៀតដែរដូចជា៖

រៀបចំអភិវឌ្ឍន៍ឲ្យមានផែទេសចរណ៍ ដោយដាក់គោលការណ៍ កំណត់ទំហំទូក ការរក្សាសុវត្ថិភាពជូនទេសចរនៅលើទូក ដើម្បីអាចឲ្យទេសចរជិះ ទូកមកកម្សាន្តដល់រមណីយដ្ឋាន

កោះដាច់តែម្តង ឬអាចទាក់ទាញទេសចរដែលធ្វើដំណើរតាមទូកឆ្លងកាត់កោះដាច់ ឲ្យចុះចតនៅផែមួយនេះ ដើម្បីសម្រាកទទួលទានអាហារជាដើម។

រៀបចំបង្កើតឲ្យមានសិប្បកម្មធ្វើកន្ត្រក ឬសូន្យរូប និងឧបករណ៍ប្រើប្រាស់ផ្សេងៗ ដើម្បីឲ្យមានការដាក់លក់វត្ថុប្រើប្រាស់ និងវត្ថុអនុស្សាវរីយ៍ មានភាពសម្បូរបែប ថែមទាំងអាចឲ្យទេសចរចូលមកធ្វើដោយផ្ទាល់ដៃ ដោយគិតលុយពីពួកគាត់ រួចហើយប្រគល់វត្ថុនោះឲ្យទៅទេសចរទុកជាអនុស្សាវរីយ៍។

បង្កើតផ្ទះស្នាក់ទេសចរណ៍ ដោយសារតែចំនួនផ្ទះស្នាក់ក្នុងតំបន់កោះដាច់នៅមានចំនួនតិចនៅឡើយ អាជ្ញាធរគួរតែពន្យល់ប្រជាពលរដ្ឋឲ្យបង្កើតសហគមន៍ផ្ទះស្នាក់ ដោយមានការរៀបចំផ្ទះស្នាក់សំរាប់ទេសចរស្នាក់នៅ ដែលផ្ទះស្នាក់នេះនឹងអាចជួយឲ្យពួកគាត់មានប្រាក់ចំណូលបន្ថែមថែមទាំងចេះរៀបចំផ្ទះសម្បែងឲ្យបានស្អាតជាងមុនទៀតផង។ មិនតែប៉ុណ្ណោះវាក៏អាចទាក់ទាញទេសចរបរទេសឲ្យមកកម្សាន្តកាន់តែច្រើន និងមានរយៈពេលវែងផងដែរ។

រៀបចំឲ្យមានការជួលកង់នៅក្នុងសហគមន៍ ដើម្បីបន្ថែមសកម្មភាពកម្សាន្តឲ្យទេសចរបានមួយផ្នែកទៀត ដោយទេសចរអាចធ្វើសកម្មភាពកីឡានៅក្នុងដំណើរកម្សាន្តរបស់ពួកគេ ធ្វើឲ្យពួកគេមានការយល់ដឹងបន្ថែមពីជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍ ថែមទាំងអាចឲ្យប្រជាជនរកចំណូលបានបន្ថែមទៀតពីការជួលកង់ឲ្យទេសចរនេះបានមួយចំនួនទៀត។

រៀបចំឲ្យមានការជិះទូកកម្សាន្តដោយអាជ្ញាធរត្រូវកំណត់ដែនសុវត្ថិភាពឲ្យបានត្រឹមត្រូវ និងបន្ថែមសន្តិសុខ ដើម្បីការពារ និងធានាសុវត្ថិភាពជូនទេសចរ។ ការជិះទូកកម្សាន្តនេះក៏អាចចាត់ទុកជាការទាក់ទាញដ៏មានឥទ្ធិពលមួយដែរព្រោះវាជាសកម្មភាពកីឡា និងអាចឲ្យទេសចរទស្សនាសម្រស់កោះដាច់បានកាន់តែច្បាស់ថែមទៀត ម៉្យាងវិញទៀតនៅក្នុងពេលបច្ចុប្បន្ននេះមិនថាទេសចរជាតិ ឬអន្តរជាតិនោះទេគឺសុទ្ធតែងាកមកចាប់អារម្មណ៍ច្រើនទៅលើការជិះទូកទាំងនៅតាមមាត់ទន្លេ ដងស្ទឹង និងដងព្រែកនានា។

ក្រៅពីការជិះទូកកម្សាន្តទៅ អាជ្ញាធរក៏គួរតែរៀបចំឲ្យមានតំបន់សម្រាប់ការកម្សាន្តលើទឹកផ្សេងៗ ដូចជា ការជិះទាទឹក និងម៉ូតូទឹក ដែលស្ថិតនៅក្នុងតំបន់សុវត្ថភាព ជាមួយនឹងការទទួលបានការការពារយ៉ាងកក់ក្តៅពីបុគ្គលិកក្នុងតំបន់។ ប៉ុន្តែដើម្បីឲ្យផលិតផលទេសចរណ៍មួយនេះទទួលបានការគាំទ្រ និងទាក់ទាញទេសចរឲ្យបានច្រើន អាជ្ញាធរគួរតែមានការកំណត់តម្លៃឲ្យបានសមរម្យដែលអាចទទួលយកបានចំពោះទេសចរជាតិ និងអន្តរជាតិ។

ចុងក្រោយនេះ គឺការបង្កើតឲ្យមានមុខម្ហូបពិសេសប្រចាំតំបន់ក៏អាចចូលរួមចំណែកទាក់ទាញទេសចរមិនធម្មតាដែរ ដែលសំខាន់នោះគឺយើងខ្ញុំមើលឃើញថាតំបន់កោះដាច់មានមុខម្ហូបពិសេសដែលមានរសជាតិឆ្ងាញ់ខុសប្លែកពីតំបន់ដទៃនោះគឺមាត់ដុតកោះដាច់ដូចនេះ មន្ទីរកសិកម្ម

គួរតែរៀបចំចាត់ចែងឲ្យមាន ការផ្គត់ផ្គង់សត្វមាន់ពីសំនាក់ប្រជាកសិករនៅក្នុងមូលដ្ឋានឲ្យទៅដល់អាជីវករឲ្យបានគ្រប់គ្រាន់ ដោយរៀបចំឲ្យមានអ្នកបង្ហាត់បង្រៀនវិធីចិញ្ចឹមមាន់ឲ្យ បានល្អ និងច្រើនតាមធម្មជាតិ។ ជាពិសេសខាងអាជ្ញាធរក៏គួរតែណែនាំអាជីវករឲ្យឈប់ទទួលទិញមាន់ដែលគ្មានគុណភាពពីទីផ្សារតទៅទៀតដើម្បីកុំឲ្យបាត់បង់កេរ្តិ៍ឈ្មោះម្ហូបនៅក្នុងតំបន់មួយមុខនេះ។ បើសិនជាអាចរៀបចំកែប្រែចំនុចនេះបាននោះមាន់ដុតកោះដាច់នឹងល្បីឈ្មោះសុះសាយដូចជាម្ហូបប្រចាំតំបន់ផ្សេងទៀតជាំមិនខាន ថែមទាំងអាចឲ្យឈ្មោះកោះដាច់បានឮទៅដល់គ្រប់តំបន់ទូទាំងប្រទេសទៀតផង។

## ៣.៧. កិច្ចសហការ និងការចូលរួមពីអ្នកពាក់ព័ន្ធ

ការបង្កើនកិច្ចសហការ និងការចូលរួមពីអ្នកពាក់ព័ន្ធទាំងឡាយ ពិតជាមានសារៈសំខាន់ណាស់សំរាប់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ដែលការចូលរួមទាំងនោះត្រូវជាទំនួលខុសត្រូវរបស់ រដ្ឋាភិបាលដែលមានតួនាទី រៀបចំចាត់ចែងឲ្យមានការសហការទាំងអស់នោះឡើង ដើម្បីឲ្យផ្នែកឯកជន និងអង្គការរៀបចំអភិវឌ្ឍរមណីយដ្ឋាន ឲ្យមានភាពប្រសើរឡើង។ រាជរដ្ឋាភិបាលគួរតែទាក់ទាញឲ្យមានការវិនិយោគផ្នែកឯកជនទៅលើចំនុចដែលខ្វះខាតដូចជា

ការវិនិយោគទៅលើសេវាកម្មស្នាក់នៅ: យើងសង្កេតឃើញនៅក្នុងតំបន់រមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់មានវត្តមានផ្ទះស្នាក់ត្រឹមតែ២ប៉ុណ្ណោះ និងមិនសូវមានការផ្សព្វផ្សាយឲ្យទេសចរបានដឹងច្រើននៅឡើយទេ ដូចនេះរដ្ឋាភិបាលគួរតែជំរុញឲ្យផ្នែកឯកជនមកវិនិយោគលើផ្នែកនេះដើម្បីឲ្យបន្ថែមកំនើនទេសចរមកកម្សាន្តក្នុងរយៈពេលវែង។

ការវិនិយោគទៅលើបង្គន់អនាម័យ: ដោយសារតែមើលឃើញពីចំណុចកង្វះខាតនៃបង្គន់អនាម័យនៅតំបន់រមណីយដ្ឋាន រដ្ឋាភិបាលគួរតែជំរុញឲ្យផ្នែកឯកជនមានការវិនិយោគទៅលើភាពខ្វះខាតមួយនេះ ដើម្បីសម្រួលដល់ការបន្ទោរបង់របស់ទេសចរឲ្យមានភាពងាយស្រួល និងធ្វើឲ្យមានការអភិវឌ្ឍផ្នែកអនាម័យឲ្យកាន់តែល្អ ដូចជាការកាត់បន្ថយក្លិនអាក្រក់ជាដើម ដើម្បីទាក់ទាញទេសចរឲ្យចង់មកកម្សាន្តម្តងហើយម្តងទៀតជាបន្តបន្ទាប់។

ការបណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ចៈ រដ្ឋាភិបាលគួរតែជំរុញឲ្យមានវគ្គបណ្តុះបណ្តាលអប់រំជំនាញបដិសណ្ឋារកិច្ចពីផ្នែកឯកជន ឬអង្គការណាមួយ ទៅដល់អាជីវករ និងប្រជាពលរដ្ឋទាំងចាស់ទាំងក្មេងនិងយុវជន ឲ្យមានការយល់ដឹងអំពីសារៈប្រយោជន៍ ផលវិជ្ជមានដែលមានមកពីបដិសណ្ឋារកិច្ច ការនិយាយស្តីពិរោះពិសារ ចំពោះអាជីវកម្មរបស់ពួកគាត់ និងវិស័យទេសចរណ៍។ រួមទាំងបង្ហាត់បង្ហាញពួកគាត់អំពីការធ្វើបដិសណ្ឋារកិច្ចល្អទៅកាន់ភ្ញៀវទេសចរណ៍ផងដែរ។

ការបណ្តុះបណ្តាលជំនាញម្ហូបអាហារ: យោងទៅតាមការសាកសួរពីអាជីវករបានឲ្យដឹងថាពួកគាត់ពិតជាចង់ឲ្យមានការបង្ហាត់បង្រៀន ពីរបៀបចម្អិនម្ហូបថ្មីៗជាច្រើនដល់ពួកគាត់ដើម្បីឲ្យ

អាជីវកម្មរបស់គាត់មានភាពរីកចម្រើនជាងពេលបច្ចុប្បន្ន។ ដូចនេះរដ្ឋាភិបាលគួរតែទាក់ទងជាមួយ អង្គការផ្សេងៗ ឬផ្នែកឯកជនតាមសណ្ឋាគារ ភោជនីយដ្ឋាន ឲ្យចុះមកជួយបង្ហាត់បង្រៀនជំនាញចម្អិន រៀបចំសោភ័ណ្ឌភាពម្ហូបអាហារឲ្យមានភាពច្នៃប្រឌិត ទាក់ទាញដែលត្រូវទៅតាមស្តង់ដារ និងប្រកបដោយអនាម័យខ្ពស់ទៅដល់អាជីវករ។

ការបណ្តុះបណ្តាលជំនាញធ្វើវត្ថុអនុស្សាវរីយ៍: យើងឃើញថានៅតំបន់រមណីយដ្ឋាននៅមិនទាន់មានកន្លែងលក់វត្ថុអនុស្សាវរីយ៍នៅឡើយទេ ដូចនេះអជ្ញាធរ អង្គការ និងរដ្ឋាភិបាលគួរតែរៀបចំឲ្យមានកន្លែងលក់វត្ថុអនុស្សាវរីយ៍ និងការបង្រៀនដល់ប្រជាពលរដ្ឋនូវរបៀបបង្កើតវត្ថុអនុស្សាវរីយ៍ផ្សេងៗដែលធ្វើដោយដៃ ដូចជា បន្តោងសោរ មួកចាក់ កន្ត្រក ខ្សែដៃ ចិញ្ចៀន ជាដើម ដូចផលិតផលដែលបានដាក់លក់នៅផ្សាររាត្រីខេត្តសៀមរាប និងការដើរលក់តាមឆ្នេរខ្សាច់ក្នុងក្រុងព្រះសីហានុ និងក្រុងកែបជាដើម។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ បកស្រាយពីប្រធានបទ ការអភិវឌ្ឍរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់ ដោយយោងទៅតាមបទពិសោធន៍ជាក់ស្តែង ការលើកយកទិន្នន័យសំខាន់ៗមួយចំនួនមកវិភាគ និងបង្ហាញកន្លងមកឃើញថា រមណីយដ្ឋានមួយនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើឲ្យវិស័យទេសចរណ៍ ដោយបានទាក់ទាញទេសចរយ៉ាងច្រើនកុះករឲ្យមកកម្សាន្ត។ ដូចនេះហើយវាពិតជាមានសារៈសំខាន់ណាស់ក្នុងការជំរុញឲ្យមានការផ្សព្វផ្សាយ និងការអភិវឌ្ឍរមណីយដ្ឋានកោះដាច់ ដើម្បីជាកត្តាជួយជំរុញឲ្យសេដ្ឋកិច្ចមានភាពប្រសើរឡើងតាមរយៈវិស័យទេសចរណ៍។

យោងតាមការរៀបរាប់ នៅក្នុងជំពូកខាងលើយើងខ្ញុំមើលឃើញថា នាពេលបច្ចុប្បន្ននេះ រមណីយដ្ឋានកោះដាច់កំពុងទាមទារ ឲ្យមានការអភិវឌ្ឍជាច្រើនផ្នែកទៀតដោយសារតែនៅមានចំណុចខ្វះខាតជាច្រើនរួមមាន កង្វះហេដ្ឋារចនាសម្ព័ន្ធ សេវាបង្គន់អនាម័យ មានបញ្ហាបរិស្ថានកង្វះអនាម័យ ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធមួយចំនួន ការផ្តល់សេវាកម្មនៅមានភាពចន្លោះប្រហោង ខ្វះការផ្សព្វផ្សាយ កង្វះការរៀបចំព្រឹត្តការណ៍ទេសចរណ៍ និងការខ្វះខាតភាពច្នៃប្រឌិតក្នុងការរៀបចំផលិតផលទេសចរណ៍ថ្មីៗ។ ដែលជាហេតុនាំយើងត្រូវគិតគូរស្វែងរកយុទ្ធសាស្រ្តថ្មីៗដើម្បីរៀបចំកែលម្អឡើងវិញនូវចំណុចដែលខ្វះខាតខាងលើ។

សរុបជារួមមកក្រុមយើងខ្ញុំមើលឃើញថា ការអភិវឌ្ឍរមណីយដ្ឋានធម្មជាតិឆ្នេរខ្សាច់កោះដាច់ នៅមានកង្វះខាតច្រើន ដូចនេះទើបយើងខ្ញុំក៏បានរៀបចំស្វែងរកយុទ្ធសាស្រ្តខ្លះៗ ជាមួយនឹងដំណោះស្រាយចំពោះរាល់បញ្ហាប្រឈមនានា ដូចបានរៀបរាប់ក្នុងជំពូកទី៣ ដើម្បីឲ្យការអភិវឌ្ឍកាន់តែប្រសើរឡើង។

## ២. អនុសាសន៍

ទោះបីជាតំបន់រមណីយដ្ឋានកោះដាច់មានបញ្ហាប្រឈមមួយចំនួនក៏ដោយ ក៏ប៉ុន្តែបើសិនជាមានការកែលម្អនូវចំនុចខ្វះខាតទាំងនោះ រមណីយដ្ឋានកោះដាច់ប្រាកដជាមានការកែប្រែមុខមាត់ថ្មីក្លាយជាគោលដៅទេសចរណ៍មួយដ៏ទាក់ទាញជាមិនខាន។

ដើម្បីឲ្យមានការអភិវឌ្ឍរមណីយដ្ឋាន ធម្មជាតិឆ្នេរខ្សាច់កោះដាច់ប្រកបដោយនិរន្តរភាព និងក្លាយជាគោលដៅទាក់ទាញទេសចរណ៍ យើងខ្ញុំសូមចូលរួមផ្តល់ជាមតិយោបល់មួយចំនួនបន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងដើម្បីបំពេញបន្ថែមលើចំណុចខ្វះខាតដែលមានដូចជា៖

អាជ្ញាធរគួរតែបង្កើនកិច្ចសហប្រតិបត្តិការណ៍ជាមួយក្រសួង និងមន្ទីរដែនដីនគរូបនីយកម្ម និងសំណង់ ឲ្យមានការរៀបចំជួសជុលផ្លូវដែលមានបញ្ហាឲ្យមានសភាពល្អស្អាត។ ចំណែកផ្លូវមួយខ្សែដែលចុះពីកំពង់ចម្លងវត្តក្តីចាស់គួរតែ ទទួលការកែលម្អថ្មីដោយអាចចាក់បេតុងឲ្យស្អាតដើម្បីសម្រួលដល់ការធ្វើដំណើររបស់ទេសចរ។

អាជ្ញាធរក៏គួរតែរឹតបន្តឹងផ្នែកម្ហូបអាហារ ដើម្បីធានាឲ្យមានរសជាតិពិសេសប្រចាំតំបន់ ការដាក់តម្លៃលក់ឲ្យបានសមរម្យ ជាពិសេសនោះគឺគុណភាពរបស់ចំណីអាហារ ដើម្បីឲ្យទេសចរមានទំនុកចិត្តក្នុងការទទួលទានដោយមិនបារម្ភណ៍ពីបញ្ហាប៉ះពាល់សុខភាព។

កែលម្អបង្គន់អនាម័យសារជាថ្មី ដោយបន្ថែមឲ្យមានប្រព័ន្ធបង្ហូរកាកសំណល់ត្រឹមត្រូវ មានស្តង់ដារអនាម័យល្អ មានឧបករណ៍សម្អាតគ្រប់គ្រាន់ជៀសវាងនូវការជះក្លិនមិនល្អ ដាក់បន្ថែមធុងសម្រាមខ្នាតតូចនៅ តាមបន្ទប់ទឹកនីមួយៗ និងបន្ថែមឲ្យមានបុគ្គលិកសម្អាតជាប្រចាំដើម្បីរក្សាបាននូវអនាម័យល្អ។

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


- ក្រសួងទេសចរណ៍ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ ២០១២- ២០២០*
- ហុង វណ្ណៈ, ឈុន ពហុ, និង សហការី, *"លំនាំដើមទេសចរណ៍"*
- សួន រ៉ានី, ឃិន ច័ន្ទសុធី, ទឹម សុធា, ជិន វិចិត្រា, *"ទេសចរណ៍ ទ្រឹស្តី និងទស្សនៈ ជាមូលដ្ឋាន" ២០០៦*
- ប្រាក់ សុផាន់ណា, ផុត សុផាត, *"ការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា,"* (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១១)
- ហុង វណ្ណៈ, ឈឹម ផាន់ណា *"ការអភិវឌ្ឍនិងផែនការទេសចរណ៍ "* ២០១៦
- លន់ ពិសិដ្ឋ *"ទស្សនទាន និងគោលការណ៍ជាមូលដ្ឋាន ស្តីពីនិរន្តរភាពនៃការអភិវឌ្ឍ"* (ក្នុងរបាយការណ៍មួយដែលបោះពុម្ពដោយគណៈកម្មការដើម្បីបរិស្ថាន និងការអភិវឌ្ឍពិភពលោក)
- ស៊្វ គឹមព្រឹទ្ធា *"គោលនយោបាយជាតិទេសចរណ៍" ២០១៥ ទំព័រទី៨*
- ហុង វណ្ណៈ *ភូមិវិទ្យាទេសចរណ៍ និងវប្បធម៌* ឆ្នាំ២០១៤
- កាសែត កម្ពុជាថ្មី ថ្ងៃទី២ខែ៥ឆ្នាំ២០១៧
- កាសែត Post news ថ្ងៃទី២ ឧសភា ២០១៧


## ឯកសារភាសាបរទេស


- Hay River Tourism Developement 2012
- TourismCambodia.org Tourism Statistic report Year 2016

# ឯកសារពីអ៊ីនធឺណេត


- https://kohsantepheapdaily.com.kh/article/36287.html
- tps://www.rome2rio.com/s/Damnoen-Saduak/Pattaya-Floating-Market?source=adwords&gclid=EAIaIQobChMIt4yYuqOc1QIVHti9Ch2Y6wsuEAAYAiAAEgJ4hfD_BwE
- https://en.wikipedia.org/wiki/Phnom_Pen
- http://tourismcambodia.org/
- http://phnompenh.gov.kh/en/
- http://www.bangkok.com/beyond-the-city/damnoensaduak.htm
- http://dictionary.cambridge.org/dictionary/english/tourism
- https://en.oxforddictionaries.com/definition/tourist
  https://www.thmeythmey.com/?page=detail&ctype=article&id=22099&lg=kh&paginate=2
- http://dictionary.cambridge.org/dictionary/english/tourist
- http://www.businessdictionary.com/definition/sustainability.html
- http://dictionary.cambridge.org/dictionary/english/sustainability
- http://www.khmer24nano.ga/2016/07/dach-is-beautiful-tourist-area-filled.html?m=1
- http://kampucheathmey.com/kpt/?p=17766
- https://www.cpp.org.kh
- https://www.khmerload.com/news/5730

# កម្រងសំនួរ
# ស្តីពី ការអភិវឌ្ឍរមណីយដ្ឋានកោះដាច់

នាងខ្ញុំសូមជំរាបសួរ លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន។ នាងខ្ញុំជានិស្សិត សិក្សាស្រាវជ្រាវផ្នែក គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច ឆ្នាំទី៤ ជំនាន់ទី៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ថ្ងៃនេះនាងខ្ញុំសូមអនុញ្ញាតពីលោក លោកស្រី អ្នកនាងកញ្ញា មេត្តាចំណាយពេលវលាដ៏មានតម្លៃ ដើម្បីឆ្លើយនឹងសំនួររបស់នាងខ្ញុំ ក្នុងគោលបំណងប្រមូលពត៌មានយកមកចងក្រងជាសារណាបញ្ចប់ការសិក្សា។

នាងខ្ញុំសង្ឃឹមថាលោកអ្នកនឹងចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ការចូលរួមឆ្លើយនូវកម្រងសំនួរខាងក្រោមនេះ។

១ សូមគូសសញ្ញានៅក្នុងប្រអប់ ☐ ដែលជាចំលើយរបស់អ្នក

២ សូមបំពេញបន្ថែមនៅត្រង់……………..តាមគំនិតរបស់អ្នក

**I ពត៌មានផ្ទាល់ខ្លួន**

ក. ជនជាតិ………….

ខ. ភេទ ☐ ស្រី ☐ ប្រុស

គ. អាយុ ☐ ក្រោម២០ ☐ ២០-៤០ឆ្នាំ ☐ ៤០-៦០ឆ្នាំ

☐ លើសពី៦០ឆ្នាំ

ឃ មុខរបរ ☐ សិស្ស និស្សិត ☐ មន្ត្រីរាជការ ☐ អាជីវករ

☐ បុគ្គលិកក្រុមហ៊ុនផ្សេងៗ

**II ពត៌មានអំពីទេសចរ**

១ តើលោកអ្នកអញ្ជើញមករមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់នេះប៉ុន្មានដងហើយ?

☐ ១ដង ☐ ២ដង ☐ ៣ដង ☐ លើសពី៣ដង

២ តើលោកអ្នកអញ្ជើញមករមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់នេះក្នុងគោលបំណងអ្វី?

☐ កម្សាន្ត ☐ ជួបជុំមិត្តភក្តិ គ្រួសារ ☐ មុខជំនួញ

☐ ទស្សនកិច្ច ☐ ស្រាវជ្រាវ ☐ ផ្សេងៗ

៣ តើលោកអ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរអ្វីក្នុងការធ្វើដំណើរមកកាន់រម្មណីយដ្ឋាន ឆ្នេរខ្សាច់កោះដាច់នេះ?

☐ រថយន្តផ្ទាល់ខ្លួន ☐ ម៉ូតូ ☐ រថយន្តឈ្នួល ☐ ផ្សេងៗ

៤ តើលោកអ្នកស្គាល់រម្មណីយដ្ឋានឆ្នេរខ្សាច់កោះដាច់នេះតាមរយៈអ្វី?

☐ ទស្សនាវដ្ដី ☐ កាសែត ☐ ទូរទស្សន៍

☐ មិត្តភក្តិ ☐ ប្រព័ន្ធអ៊ីនធឺណេត ☐ ផ្សេងៗ

៥ តើលោកអ្នកយល់ដូចម្ដេចចំពោះបរិស្ថាន និងអនាម័យរម្មណីយដ្ឋានឆ្នេរខ្សាច់កោះដាច់?

☐ ល្អ ☐ ល្អបង្គួរ ☐ មធ្យម ☐ មិនល្អ

៦ តើលោកអ្នកយល់យ៉ាងណាចំពោះគុណភាពអាហារនៅក្នុងតំបន់រម្មណីយដ្ឋានឆ្នេរខ្សាច់ កោះដាច់?

☐ ល្អ ☐ ល្អបង្គួរ ☐ មធ្យម ☐ មិនល្អ

៧ តើលោកអ្នកយល់យ៉ាងណាចំពោះតម្លៃអាហារនៅក្នុងតំបន់រម្មណីយដ្ឋានឆ្នេរខ្សាច់កោះ ដាច់?

☐ ថ្លៃ ☐ សមរម្យ

៨ តើលោកអ្នកយល់យ៉ាងណាចំពោះសន្តិសុខនៅក្នុងតំបន់រម្មណីយដ្ឋានឆ្នេរខ្សាច់កោះ ដាច់?

☐ ល្អ ☐ ល្អបង្គួរ ☐ មធ្យម ☐ មិនល្អ

☐ ត្រូវពង្រឹងបន្ថែម

៩ តើលោកអ្នកមានសំនូមពរអោយមានការអភិវឌ្ឍទៅលើផ្នែកអ្វីខ្លះនៅក្នុងរម្មណីយដ្ឋាន នេះ? (អាចជ្រើសរើសចំលើយបានលើសពីមួយ)

☐ ហេដ្ឋារចនាសម្ព័ន្ធ ☐ សេវាសាធារណៈ ☐ សន្តិសុខ សុខាភិបាល

☐ បរិស្ថាន ☐ ទាំងអស់ខាងលើ

**III ពត៌មានពីអាជីវករ**

១. តើលោកពូ អ្នកមីងប្រកបរបរនេះបានប៉ុន្មានឆ្នាំហើយ?

☐ ១ឆ្នាំ ☐ ២ឆ្នាំ ☐ ៣ឆ្នាំឡើងទៅ

២. ហេតុអ្វីបានជាប្រកបរបរនេះ?

☐ ទទួលបានចំនូលច្រើន ☐ មានពេលវេលាគ្រប់គ្រាន់

៣. តើចំនូលពីការលក់ម្ហូបអាហារទទួលបានកម្រៃដូចម្តេច?

☐ ច្រើនជាងមុន ☐ ច្រើនល្មម

☐ នៅដដែល ☐ តិចជាងមុន

៤. តើចេះធ្វើម្ហូបតាមរយៈអ្នកណា?

☐ គ្រួសារ និងមិត្តភក្តិ ☐ ការបណ្តុះបណ្តាល

៥. តើយកគ្រឿងផ្សំធ្វើម្ហូបមកពីណា?

☐ ទិញពីផ្សារ ☐ ទិញពីក្នុងសហគមន៍ ☐ ផលិតដោយខ្លួនឯង

៧. តើលោកពូ អ្នកមីងចង់អោយមានការអភិវឌ្ឍទៅលើផ្នែកអ្វីខ្លះនៅក្នុងរម្មណីយដ្ឋានកោះដាច់?

☐ ហេដ្ឋារចនាសម្ព័ន្ធ ☐ សេវាសាធារណៈ ☐ បរិស្ថាន

☐ ការបណ្តុះបណ្តាលម្ហូបអាហារ ☐ សន្តិសុខ សុខាភិបាល

☐ ទាំងអស់ខាងលើ

**IV ពត៌មានពីអាជ្ញាធរ**

១. តើលោកអ្នកធ្លាប់បានចូលរួមក្នុងការអភិវឌ្ឍរម្មណីយដ្ឋានកោះដាច់ដែរឬទេ?

☐ ធ្លាប់ ☐ មិនធ្លាប់

២. តើការលក់ដូររបស់អាជីវករសមរម្យដែរឬទេ?

☐ សមរម្យ ☐ មិនសមរម្យ

៣. តើមូលដ្ឋានរបស់លោកអ្នកបានទទួលផលប្រយោជន៍អ្វីខ្លះពីការអភិវឌ្ឍ?

- ☐ ជីវភាពប្រជាជនមានការកើនឡើង
- ☐ ហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន
- ☐ សេវាសាធារណៈប្រសើរជាងមុន
- ☐ សន្តិសុខ សុខាភិបាលល្អជាងមុន
- ☐ បរិស្ថានល្អ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្រ្ត
# អភិវឌ្ឍន៍ទេសចរណ៍
# ២០១២-២០២០

បានទទួលការឯកភាពពីគណៈរដ្ឋមន្រ្តីក្នុង
សម័យប្រជុំពេញអង្គនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២

ក្រសួងទេសចរណ៍

កម្ពុជា

សហគមន៍ទេសចរណ៍ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋានតិជាអាទិភាព។

(៦៧) រាជរដ្ឋាភិបាលយកចិត្តទុកដាក់បង្កលក្ខណៈងាយស្រួលជូនប្រជាជន ដោយជំរុញលើកទឹកចិត្ត បណ្តុះគំនិតផ្តួចផ្តើម បង្កើត ឬច្នៃប្រឌិត បង្កើតឲ្យចេញជាផលិតផលទេសចរណ៍ថ្មីៗឈរលើមូលដ្ឋានធនធានដែលមានស្រាប់ដូចជា៖

- ផលិតនិងចលនាលក់វត្ថុសិប្បកម្ម ជាលក្ខណៈវត្ថុអនុស្សាវរីយ៍ទេសចរណ៍ ដែលបង្ហាញនូវវប្បធម៌និងប្រពៃណីរស់នៅរបស់ប្រជាជនតាមតំបន់ផ្សេងៗគ្នា។
- ការបង្ហាញសិល្បៈ របាំ ចម្រៀងប្រពៃណី ម្ហូបអាហារ ផ្លែឈើ។ល។ ជូនទេសចរនៅតាមសហគមន៍នានា។
- ការបង្ហាញឬការអនុញ្ញាតឲ្យទេសចរចូលរួមសកម្មភាពសមស្រប អំពីជីវភាពរស់នៅពិតៗរបស់ប្រជាជនតាមសហគមន៍រួមមាន៖ ការបង្កបង្កើនផល ការនេសាទត្រី ការប្រារព្ធពិធីបុណ្យទានជំនឿសាសនា។ល។ ដើម្បីឲ្យទេសចរបានស្គាល់និងរីករាយចូលរួម។ ករណីនេះផ្សារភ្ជាប់ជាមួយ " ទេសចរណ៍ជនបទ " ដែលកំពុងទទួលជោគជ័យនៅស្រុកបារាយខេត្តកំពង់ធំ។
- ទេសចរណ៍រួមវិភាគទានដល់ការអភិវឌ្ឍ ដូចជា ការលើកទឹកចិត្តឲ្យទេសចរចូលរួមដាំដើមឈើ "ទេសចរម្នាក់ ដើមឈើមួយដើម" ឬ "ដើមឈើមួយដើម ផ្តើមចេញពីអ្នក" ជីកអណ្តូងទឹក សាងសង់ផ្ទះ សាលារៀន មន្ទីរពេទ្យ ឬការចូលរួមជួយផ្តល់អំណោយមនុស្សធម៌នានា។
- បំផុសចលនាប្រជាជនឲ្យផលិតផលិតផលនានា ដើម្បីលក់បម្រើឲ្យទីផ្សារទេសចរណ៍ ដូចជា បន្លែ ផ្លែឈើ ផ្កា ត្រី សាច់ គ្រឿងសង្ហារិម ដែលតម្រូវការនេះកើនឡើងជាប្រចាំតាមកំណើនទេសចរណ៍ ហើយបច្ចុប្បន្នមួយផ្នែកត្រូវបាននាំចូលពីបរទេស។ ការបង្កើនការផ្គត់ផ្គង់ក្នុងស្រុកគឺកាត់បន្ថយការនាំចូល និងទប់ស្កាត់ការផ្ទេរផ្លាយសេដ្ឋកិច្ច និងជំរុញសកម្មភាពសហគ្រាសធុនតូចនិងមធ្យម(SME)។

(៦៨) សកម្មភាពនិងលទ្ធផលខាងលើនេះ គឺសំខាន់ជំរុញការអភិវឌ្ឍទេសចរណ៍ផង និងការជួយកាត់បន្ថយភាពក្រីក្រតាមរយៈទេសចរណ៍ផង ដែលនេះគឺជាគោលដៅចម្បងរបស់រាជរដ្ឋាភិបាល ដោយស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងគោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា។

## ១.៣. ភ្នំពេញនិងតំបន់ជុំវិញ

(៦៩) រាជធានីភ្នំពេញ គឺជាបេះដូងនិងជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម វប្បធម៌ និងទេសចរណ៍នៃកម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ។ ភ្នំពេញជារាជធានីដ៏ចំណាស់មួយនៅអាស៊ី និងមានទីតាំងជាយុទ្ធសាស្ត្រនៅចំណុចប្រសព្វបួនមុខនៃទន្លេមេគង្គ។ រាជធានីភ្នំពេញដែលទទួលបានមេដៃពិភពលោកបានប្រែក្លាយពីទីក្រុង "សូន្យ" ខ្មោចខ្មាំងដោយសារសង្គ្រាមនិងរបបប្រល័យពូជសាសន៍ ទៅជារាជធានីកំពុងអភិវឌ្ឍលើគ្រប់វិស័យ។ ភ្នំពេញតភ្ជាប់ជាមួយពិភពលោកតាមគ្រប់មធ្យោបាយជិះជញ្ជូនស្ស

ទេសចរណ៍ទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ក្នុងនោះព្រលានយន្តហោះអន្តរជាតិភ្នំពេញកំពុងបំពេញតួនាទីជាស្នូលយ៉ាងសកម្ម ដោយមានសមត្ថភាពទទួលអ្នកដំណើរបានជាងមួយលាននាក់ក្នុងមួយឆ្នាំៗ។

(៧០) រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលប្រមូលផ្តុំនូវរតនសម្បត្តិ បេតិកភណ្ឌវប្បធម៌ជាច្រើនដែលជាប្រភពធនធានដ៏សំខាន់សម្រាប់ការទាក់ទាញទេសចរ ដូចជាសារមន្ទីរជាតិ ព្រះបរមរាជវាំង ទីតាំងប្រវត្តិសាស្ត្រវត្តភ្នំ និងសំណង់ស្ថាបត្យកម្មសម័យអាណានិគម។ល។ ជាងនេះទៅទៀត រាជធានីភ្នំពេញសម័យតេជោ មានការអភិវឌ្ឍបានរំលេចនូវសំណង់អគារថ្មីខ្ពស់ៗ សណ្ឋាគារល្អប្រណីតលំដាប់អន្តរជាតិ និងសេវាកម្មទេសចរណ៍ច្រើនប្រភេទ អមដោយភាពស្រស់ស្អាតនៃការតុបតែងលម្អនានា នាំឲ្យទីក្រុងនេះក្លាយជាគោលដៅទេសចរណ៍ជាទីពេញនិយម។ នៅជុំវិញរាជធានី ក៏មានសក្តានុពលទាក់ទាញទេសចរវប្បធម៌និងធម្មជាតិ ដោយភ្ជាប់ពីលក្ខណៈទេសចរណ៍ "ទីក្រុង" ទៅទេសចរណ៍ "ជនបទ" និងកសិ-ទេសចរណ៍ ពិសេសសម្រាប់អ្នករស់នៅក្នុងទីក្រុងនិងភ្ញៀវបរទេស។ គោលដៅទេសចរណ៍តំបន់ជុំវិញបាននិងកំពុងអភិវឌ្ឍរួមមាន ភ្នំព្រះរាជទ្រព្យ (ភ្នំឧត្តុង្គ) ភ្នំប្រសិទ្ធិ កោះដាច់ តំបន់ភាគខាងកើតរាជធានីភ្នំពេញ និងការតភ្ជាប់ជាមួយតំបន់ផ្សេងៗទៀតនៃខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ដូចជាទន្លេបាទី។ល។ តំបន់កប់ស្រូវគួរត្រូវរៀបចំអភិវឌ្ឍទៅជាតំបន់សម្រាកកម្សាន្ត ដែលនៅក្នុងរាជធានីភ្នំពេញតែម្តង។

(៧១) រាជធានីភ្នំពេញកាន់តែមានកំណើនប្រជាជន និងមធ្យោបាយដឹកជញ្ជូនច្រើនឡើង ដែលរួមមានប្រជាជនប្រមាណ២លាននាក់ ទេសចរជាតិនិងអន្តរជាតិជាង២លាននាក់ក្នុងមួយឆ្នាំ និងមធ្យោបាយដឹកជញ្ជូនជាងមួយលានគ្រឿង។ កត្តានេះបង្កជាចលករ "រុញ" នៃចរន្តទេសចរណ៍ផ្ទៃក្នុងកាន់តែខ្លាំងឡើងៗ។ ដោយសារនិន្នាការនេះ ការជំរុញការអភិវឌ្ឍផលិតផលទេសចរណ៍នៅក្នុងនិងតំបន់ជុំវិញរាជធានីភ្នំពេញ គឺជាការចាំបាច់និងបន្ទាន់ដើម្បីការផ្គត់ផ្គង់តម្រូវការទេសចរផង និងស្រូបយកផលទេសចរណ៍សម្រាប់ប្រជាជនផង។

(៧២) រាជធានីភ្នំពេញនិងតំបន់ជុំវិញនៅមានសក្តានុពលច្រើនសម្រាប់ការអភិវឌ្ឍទេសចរណ៍ ដើម្បីពន្យារការស្នាក់នៅរបស់ភ្ញៀវបានយូរ ដូចជា ការទស្សនាកម្សាន្តតាមនាវាតាមដងទន្លេមេគង្គ(ទន្លេសាប) ការទស្សនាសហគមន៍ប្រជាជននៅតាមដងទន្លេ ភូមិសិប្បកម្មតម្បាញ ចម្លាក់ប្រាក់ តំបន់កសិទេសចរណ៍ និងតំបន់បេតិកភណ្ឌវប្បធម៌ ការកម្សាន្តនៅពេលរាត្រីតាមដងទន្លេចតុមុខ ផ្សាររាត្រី ការរៀបចំតំបន់ទេសចរណ៍ពេលរាត្រីប្រកបដោយសុវត្ថិភាព និងការទស្សនាមណ្ឌលពាណិជ្ជកម្ម និងផ្សារលក់ដូរ។ល។

(៧៣) រាជធានីភ្នំពេញ បច្ចុប្បន្នត្រូវបានពង្រីកវិសាលភាពយ៉ាងធំធេង ដែលសក្តិសមជារាជធានីសម័យតេជោដោយរួមមាន ទីក្រុងរណបលំដាប់ពិភពលោកជាច្រើនកំពុងត្រូវបានស្ថាបនាឡើង តភ្ជាប់ដោយប្រព័ន្ធសមស្រប។ ទីក្រុងរណបទាំងនេះក្លាយជាលំនៅឋានផង និងជាផលិតផលទេសចរណ៍សម្រាប់រាជធានីផង។ ក្រៅពីនេះ តំបន់ជាយរាជធានីភ្នំពេញ ដូចជាតំបន់កប់ស្រូវនិងតាមដងទន្លេមានសក្តានុពលទាក់ទាញបែបអេកូទេសចរណ៍ អាចរៀបចំជាតំបន់សម្រាកលំហែកម្សាន្ត សម្រាប់ទាំងភ្ញៀវនិងអ្នករស់នៅក្នុងរាជធានីដែលកាន់តែច្រើនឡើងៗ។ម្យ៉ាងទៀត ផលិតផលផ្នែកសេវាកម្សាន្ត

ទេសចរណ៍ត្រូវយកចិត្តទុកដាក់ពង្រឹងនិងពង្រីកឲ្យបានកាន់តែប្រសើរ សមស្រប ដើម្បីលើកកម្ពស់រាជធានីភ្នំពេញឲ្យក្លាយជារាជធានីមានសកម្មភាពរស់រវើក ស្របតាមស្តង់ដាទីក្រុងស្អាត សំដៅទាក់ទាញទេសចរណ៍ផង និងបង្កើនការងារទេសចរណ៍ផង។

(៧៤) ទោះជាយ៉ាងណាក៏ដោយ ក៏ភ្នំពេញត្រូវអភិវឌ្ឍស្របតាមប្លង់មេនៃការអភិវឌ្ឍទីក្រុងយ៉ាងពិតប្រាកដ ដោយប្រែក្លាយទៅជា "គង់" មួយនៅអាស៊ី ទាំងភាពស្អាត ទាំងភាពបៃតង និងទាំងសណ្តាប់ធ្នាប់របៀបរៀបរយ។ ភ្នំពេញត្រៀមលក្ខណសម្បត្តិគ្រប់យ៉ាងដើម្បីធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំវេទិកា និងសន្និសីទ កម្រិតអន្តរជាតិជាច្រើន ហើយនិងត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណបីលាននាក់ក្នុងមួយឆ្នាំៗ ចាប់ពី២០១៣ ដោយមិនទាន់គិតភ្ញៀវទេសចរក្នុងស្រុកជាច្រើនលាននាក់ចូលមករាជធានីជារៀងរាល់ឆ្នាំ។ ភ្នំពេញ ទាមទារនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្បទាទេសចរណ៍ជាច្រើនទៀតដើម្បីស្រូបយកកំណើននេះ ពិសេសផ្លូវព្រលានយន្តហោះ ការផ្គត់ផ្គង់ទឹកស្អាត និងថាមពលអគ្គិសនី។ រាជធានីភ្នំពេញចាំបាច់ត្រូវមានព្រលានយន្តហោះខ្នាតធំកម្រិតអន្តរជាតិ ដើម្បីធ្វើជាស្នូលក្នុងការតភ្ជាប់ពិភពលោក។ ព្រលានយន្តហោះខ្នាតធំ ដែលមានសមត្ថភាពផ្ទុកប្រមាណ១០លាននាក់ក្នុងមួយឆ្នាំ នឹងដើរតួនាទីជាគន្លឹះក្នុងការរំដោះកម្ពុជាចេញពីភាពជា "គោលដៅទេសចរណ៍រណប" ដូចដែលធ្លាប់បាន និងកំពុងជួបប្រទះកន្លងមកនិងពេលបច្ចុប្បន្នទៅជាគោលដៅទេសចរណ៍ទី១សម្រាប់ពិភពលោក។ ដូច្នេះ ការរៀបចំផែនការសិក្សាអំពីព្រលានយន្តហោះនេះ ត្រូវចាប់ផ្តើមពីពេលនេះទៅ ហើយបើខកខាននោះកម្ពុជានឹងបាត់បង់ឱកាសបន្តទៀត។

### ១.៤. ការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរ

(៧៥) តំបន់ឆ្នេរដែលស្ថិតក្នុងច្រករបៀងទេសចរណ៍ភាគខាងត្បូង ជាតារាៈនាទិសនិវត្តិរួមបញ្ចូល ខេត្ត៥គឺ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលបាននិងកំពុងក្លាយជាប៉ូលដ៏សំខាន់សម្រាប់ស្រូបទាញទេសចរជាតិនិងអន្តរជាតិ។ ឆ្នេរសមុទ្រកម្ពុជាត្រូវបានក្លាយជាសមាជិកនៃក្លឹបឆ្នេរសមុទ្រដ៏ស្អាតបំផុតលើសកលលោក ហើយកិត្តិនាមនេះកំពុងលើកតម្កើងកិត្យានុភាពឆ្នេរកម្ពុជាលើឆាកអន្តរជាតិ។

(៧៦) តំបន់ឆ្នេរកម្ពុជាមានធនធានចម្រុះ សម្បូរ និងច្រើនប្រភេទសម្រាប់ការអភិវឌ្ឍទេសចរណ៍ ហើយធនធានទាំងនេះនៅថ្មី និងមានភាពទាក់ទាញយ៉ាងខ្លាំង។ តំបន់ឆ្នេរស្ថិតក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការនៃច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ដែលភ្ជាប់ប្រទេសវៀតណាម និងប្រទេសថៃ ដោយគមនាគមន៍ផ្លូវគោក(ផ្លូវលេខ៣៣ ផ្លូវលេខ៣ និងផ្លូវលេខ៤៨) និងផ្លូវទឹកយ៉ាងល្អប្រសើរក្នុងពេលបច្ចុប្បន្ន ហើយអនាគតនឹងមានការតភ្ជាប់តាមផ្លូវអាកាសជាលក្ខណៈអន្តរជាតិ។ តំបន់នេះស្ថិតនៅមិនឆ្ងាយពីប៉ូលអង្គរដ៏ខ្លាំង ដែលមានទេសចរប្រមាណជាង២លាននាក់ក្នុងមួយឆ្នាំនិងនៅជិតរាជធានីភ្នំពេញ ដែលមានទាំងទេសចរ ទាំងប្រជាជនដែលរស់នៅប្រមាណជិតបីលាននាក់ រួមទាំងធុរជននិងបុគ្គលិកបម្រើតាមស្ថាប័នអង្គការ អន្តរជាតិនានា។ តំបន់ឆ្នេរក៏ភ្ជាប់ជាមួយរាជធានីភ្នំពេញដោយបណ្តាញផ្លូវដែក ដែលនឹងក្លាយជាមធ្យោបាយដឹកជញ្ជូនទេសចរដ៏សំខាន់មួយក្នុងថ្ងៃអនាគត។

# Hay River,

# Northwest Territories

# *Tourism Development Plan*

# *2012*




**Prepared by:**

**Matt Kerswill & Heather Mair**

**University of Waterloo**

**Waterloo, ON**

**June, 2012**

## The community view: What we heard from members of the Hay River community

### Conversations

Alongside market data and exit surveys, it is important to consider the views of those who live in Hay River. Often those who live in a town, whether they are directly connected to the development of tourism or not, have strong and well-founded views that can help shape a successful vision of tourism. Our analysis of interviews and focus groups with members of the Hay River community revealed the following 5 major points. These points are revisited in the key findings sections as well as the recommendations provided in the five-year plan.

### 1) Develop the water- focus on lakes, waterfalls and rivers

The need to further develop water-related activities was a major point in many of the discussions. Participants felt Hay River has much potential as a result of its location on the river and Great Slave Lake. Existing features such as great fishing on the lake, Alexander Falls, the beach, canoeing and kayaking and the NTCL synchro-lift were all identified as major selling points for potential visitors.

Boat tours, cultural walking tours, and fishing tours are already taking place in Hay River, but these are typically occurring on a small scale insofar as a tourist would need to search for a phone number while in town and try to set up a tour. Although this approach may be adequate for tourists who are already in Hay River, participants felt it missed potential visitors who may be in the Territory and who are looking for water related activities.

Many participants described a lack of consistency regarding the provision of these water-related activities and felt that they needed to be better promoted and more organized to expand their appeal. Examples of better organization included the development of a website (for example, "Alexander Falls Tours") that clearly advertises the Falls and gives directions for how to get to the site. Additionally, it needs to be made clear when the tours are occurring. For example "tours of up to 8 people will be held from Thursday-Sunday from June-October and leave every hour on the hour from 9 am- 5pm." Participants had many suggestions in this regard and described a need for a much higher level of organization in order to draw tourists to these types of attractions. Additional reflections on coordinating activities and better organization the current tourism offerings are provided in the key finding and in the recommendations throughout the five year plan.

### 2) Marina Development

In addition to developing the waterfront and water-related tourism activities, one of the major points that came up throughout the discussions with participants was a need to develop a marina. It was noted that it is currently very difficult to get in and out of the water and that a new boat launch should be installed. In addition to the marina,

participants suggested official drop off points and parking lots to help both locals and tourists. Participants also noted that a marina was key to capturing the boaters from Yellowknife. Additionally, having a floatplane dock was mentioned, as this would allow another entry point for visitors to Hay River. In order for the marina development to be successful, participants explained that it should be developed as a collaborative effort with the First Nations community.

**3) Community Buy-in**

During the focus groups and interviews, many participants expressed a concern regarding the need to build community buy-in in terms of support for tourism. Although the Trade and Tourism Advisory Committee and some other members of the community were seen as understanding the *value* of tourism, it was noted that this sentiment might not be shared throughout the entire town. In order to facilitate this support for tourism, participants suggested hosting a town hall meeting to which community members could be invited and shown the potential benefits of tourism in Hay River. In addition to showing the potential benefits, this town hall meeting could also address issues like "how to be a good host" which would encourage members of the community to be welcoming and informed. Participants felt community members could do more to share what they know about life in Hay River with tourists. However, some participants explained that it is difficult to get community members to buy-in to tourism as it has not been successful in the past, and in order to become successful, money and effort will need to be invested.

**4) Packaging Products**

Participants argued Hay River has so much to offer tourists, but the presentation of these tourism products in the form of packages is essential in order to better share these offerings with tourists. There were a number of suggestions made by participants as to what they thought these packages could look like. Ideas for packages were anchored around the appeal of Buffalo Airways, the aurora borealis, fishing, and cultural experiences. Many participants felt that packaging existing tourism products together would allow visitors to spend more than one day in the community. Other participants explained that an official staging area or meeting place for all tourism operators should be developed. This would be a building where all the operators have kiosks and transportation to their activity.

Importantly, it was noted that the recent FAM tours from Yellowknife proved people want to come to Hay River, but tourism packages still need to be created to capture the largest potential audience. Participants explained that since the bus route no longer extends to Hay River, rubber tire traffic and passengers arriving by air should be the main areas of focus for marketing these products.




ផែនទីរាជធានី



រូបទី១ ផ្លាកសញ្ញាបង្ហាញផ្លូវចូលទៅកាន់រមណីយដ្ឋានកោះដាច់



រូបទី២ ផ្លូវចូលទៅកាន់រមណីយដ្ឋានកោះដាច់ក្រោយពេលមានភ្លៀងធ្លាក់



រូបទី៣ ផ្លូវចូលទៅកាន់រមណីយដ្ឋានកោះដាច់



រូបទី៤ ចំណតរថយន្តរបស់រមណីយដ្ឋាន



រូបទី៥ ទិដ្ឋភាពរមណីយដ្ឋានកោះដាច់



រូបទី៦ កាកសំណល់នៅលើឆ្នេរខ្សាច់



រូបទី៧ ខ្ទុះអង្គុយលេងនៅឆ្នេរខ្សាច់កោះដាច់



រូបទី៨ សកម្មភាពទេសចរនៅរមណីយដ្ឋាន



រូបទី៩ សកម្មភាពតម្បាញរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់កោះដាច់



រូបទី១០ ផ្ទះស្នាក់ទេសចរណ៍នៅក្នុងតំបន់កោះដាច់